**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងធនធានព្រៃឈើ
# តំបន់ចម្ការពូជឈើក្រញូងរបស់
# សង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្លារក្រៅ

កម្មសិក្សាពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នា ២០១៩

ករណីសិក្សា៖ **សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្លារក្រៅ ស្រុកបន្ទាយស្រី ខេត្តសៀមរាប**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ណាត ឧត្តម**

**សន សារុន**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៣

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេររបាយការណ៍ ២០១៩

## **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ណាត ឧត្តម** និង **សន សារុន** ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី០៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០១៩។

## **សូមធ្វើគារវកិច្ច និង កតញ្ញូតាធម៌ចំពោះ**

លោកឪពុកឈ្មោះ **ផុន ណាត** និង អ្នកម្តាយឈ្មោះ **យ៉ែម និមល** ដែលមានគុណយ៉ាងធំធេងមិនអាចកាត់ថ្លៃបានចំពោះរូបកូនដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូន **ណាត ឧត្តម** ដោយព្រហ្មវិហារធម៌ និងបានបញ្ជូនកូនឲ្យទៅសាលារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹង ដើម្បីរស់នៅប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ។

លោកឪពុកឈ្មោះ **សន សារឹន** និងអ្នកម្តាយឈ្មោះ **ថៃ ចាន់ធឿន** ដែលមានគុណយ៉ាងធំធេងមិនអាចកាត់ថ្លៃបានចំពោះរូបកូនដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សារូបកូន **សន សារុន** ដោយព្រហ្មវិហារធម៌ និងបានបញ្ជូនកូនឲ្យទៅសាលារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹង ដើម្បីរស់នៅប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ។

លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** សាស្ត្រាចារ្យណែនាំសារណានេះ និងជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជា **អភិវឌ្ឍន៍ជនបទ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយពន្យល់ណែនាំ និងផ្តល់អនុសាសន៍ដ៏ល្អៗជាច្រើនលើសារណាមួយនេះ។

សូមធ្វើការដឹងគុណចំពោះលោកសាស្ត្រាចារ្យទាំងអស់ ដែលបានបង្ហាត់បង្រៀនទូន្មានប្រៀនប្រដៅ បង្ហាញទិសដៅ និងផ្តល់ជាអនុសាសន៍ល្អៗពន្យល់ខ្ញុំបាទ អស់ពីកម្លាំងកាយចិត្តអស់ពីកម្លាំងពីសមត្ថភាព មិនគិតអំពីការនឿយហត់ក្នុងការអប់រំគ្រប់បែបយ៉ាងមិនថាចំណេះដឹង និងសីលធម៌តាំងពីថ្នាក់បឋមសិក្សា រហូតមកដល់ថ្នាក់ក្រោយឧត្តមសិក្សានេះ។ គុណូបការៈដ៏ថ្លៃថ្លាទាំងនេះធ្វើឲ្យខ្ញុំបាទដឹងគុណ និងចងចាំជានិច្ចមិនអាចបំភ្លេចបាន និងសូមប្រសិទ្ធិពរជ័យ សូមលោកសាស្ត្រាចារ្យបានជួបប្រទះតែគុណបុណ្យព្រះរតនៈត្រ័យ ដែលជាវត្ថុសក្តិសិទ្ធិក្នុងលោកមានពុទ្ធរតនៈ ធម្មរតនៈ និងសង្ឃរតនៈ ជាទីពឹងគ្រប់ពេលវេលា ព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតអំពីយើងខ្ញុំ។

# អារម្ភកថា

ក្រោមការខិតខំព្យាយាម និងចំណាយពេលវេលាអស់រយៈជិតបីខែកន្លងមកនេះ ព្រមទាំងមានការជួយណែនាំកែតំរូវពីសំណាក់លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** យើងខ្ញុំទាំងអស់គ្នាជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី៣នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានទទួលការអនុញ្ញាតពីសំណាក់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ បានចុះធ្វើកម្មសិក្សាដើម្បីរៀបចំជាសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "ការគ្រប់គ្រងធនធានព្រៃឈើតំបន់ចម្ការពូជឈើគ្រញូងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ"។

ការសម្រេចជ្រើសរើសយកប្រធានបទខាងលើនេះ គឺយើងខ្ញុំមានបំណងចង់ដឹងពីរបៀបនៃការគ្រប់គ្រងធនធានព្រៃឈើរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅកន្លងមករហូតដល់បច្ចុប្បន្ន ក៏ដូចជាចង់ស្វែងយល់អំពីយុទ្ធសាស្ត្រ សកម្មភាពក្នុងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់សង្កាត់រដ្ឋបាលព្រៃឈើនេះទៅអនាគតផងដែរ។

សារណាមួយច្បាប់នេះបានប្រសូតឡើង ដោយមានការរៀបរៀងនូវខ្លឹមសារមួយចំនួនទាក់ទងទៅនឹងប្រធានបទខាងលើចែកចេញជាបីជំពូកដូចជា ការរំលឹកទ្រឹស្តី ការសិក្សាស្ថានភាពរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ការវិភាគទិន្នន័យ និងរបកគំហើញ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។ នេះជាជំហានទីមួយរបស់យើងខ្ញុំក្នុងការសិក្សាស្រាវជ្រាវ ដើម្បីចងក្រងបានជាសារណានេះឡើងដែលយើងខ្ញុំទាំងអស់គ្នាចាត់ទុកថា វាជាភស្តុតាងមួយនៃការបញ្ចប់កំរិតសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ និងជាឯកសារសម្រាប់បម្រើសេចក្តីត្រូវការផ្នែកស្រាវជ្រាវនៃបណ្តាយុវនិស្សិតជំនាន់ក្រោយៗទៀត ព្រមទាំងជាប្រភពពត៌មានមួយសម្រាប់សង្កាត់រដ្ឋបាលផងដែរ។

ថ្វីត្បិតតែក្រុមយើងខ្ញុំបានបញ្ចប់ការសរសេរសារណាដោយជោគជ័យនិងប្រកបដោយសុទិដ្ឋិនិយមក៏ដោយ ក៏សារណារបស់ក្រុមយើងខ្ញុំពិតជាពុំទាន់មានលក្ខណៈល្អឥតខ្ចោះស្របតាមស្តង់ដាដែលសាកលវិទ្យាល័យបានកំណត់ឡើយ។ ដូច្នេះយើងខ្ញុំនៅមានជំនឿជាក់ថា ប្រាកដនៅមានចំណុចខ្វះខាតខ្លះៗទាំងរូបភាព ខ្លឹមសារ និងអក្ខរាវិរុទ្ធជាដើម។ ហេតុនេះហើយយើងខ្ញុំទាំងអស់គ្នានឹងរង់ចាំនូវការរិះគន់កែលំអ និងការផ្តល់គំនិតយោបល់ប្រកបដោយន័យស្ថាបនាពីសំណាក់ប្រិយមិត្រអ្នកអាន អ្នកស្រាវជ្រាវ និស្សិតរៀមច្បង លោកសាស្ត្រាចារ្យ និងសាធារណៈជនពីគ្រប់មជ្ឈដ្ឋាន។ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយចំពោះការទិតៀនកែលំអទាំងអស់ និងចាត់ទុកថាជាវិភាគទានដ៏សំខាន់ក្នុងការពង្រីកសមត្ថភាពចំណេះដឹងរបស់យើងខ្ញុំទៅថ្ងៃអនាគត ។

# មាតិកា

**ទំព័រ**


បញ្ជីអក្សរកាត់ ........ vi

បញ្ជីតារាង ........ vii

បញ្ជីរូបភាព ........ viii

បញ្ជីក្រាហ្វិក ........ ix

បញ្ជីឧបសម្ព័ន្ធ ........ x


## សេចក្ដីផ្ដើម


១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្ត្រស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធស្រាវជ្រាវ ........ ៤


## ជំពូកទី១

## ការសិក្សាលើទ្រឹស្ដីការគ្រប់គ្រងធនធានព្រៃឈើ


១.១ និយមន័យ ........ ៥

១.១.១ ការគ្រប់គ្រងព្រៃឈើ ........ ៥

១.១.២ ការគ្រប់គ្រងព្រៃឈើFAO ........ ៥

១.១.៣ ការគ្រប់គ្រងព្រៃឈើ SAKASOV ........ ៥

១.១.៤ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ........ ៦

១.២ ក្របខណ្ឌនយោបាយព្រៃឈើ ........ ៦

១.២.១ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព ៧

១.២.២ ការការពារព្រៃឈើ ........ ៧

១.២.៣ សម្បត្តិព្រៃឈើ អចិន្ត្រៃយ៍ ........ ៨

១.២.៤ ការគ្រប់គ្រងព្រៃសម្បទាន ........ ៩

១.២.៥ ការធ្វើផែនការគ្រប់គ្រង ........ ៩
១.២.៦ ផែនការគ្រប់គ្រងព្រៃឈើកំរិតអនុតំបន់ ........ ១០
១.៣ គោលដៅនៃការគ្រប់គ្រងព្រៃឈើ ........ ១០
១.៣.១ គោលនយោបាយវិស័យព្រៃឈើ ........ ១០
១.៣.២ ច្បាប់ក្រឹត អនុក្រឹត និងលិខិតបទដ្ឋានក្រោមច្បាប់ដែលពាក់ព័ន្ធ និងវិស័យព្រៃឈើ...... ១១
១.៣.៣ បច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា ........ ១៥
១.៣.៤ ការគាំទ្រតាមប្រព័ន្ធច្បាប់ ........ ១៥
១.៤ គោលដៅ និងគោលបំណងនៃការការពារគ្រប់គ្រងព្រៃឈើ ........ ១៦
១.៥ រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ........ ១៧
១.៥.១ ខណ្ឌរដ្ឋបាលព្រៃឈើមានតួនាទី និងភារកិច្ច........ ១៧
១.៥.២ ផ្នែករដ្ឋបាលព្រៃឈើមានតួនាទី និងភារកិច្ច........ ១៨
១.៥.៣ សង្កាត់រដ្ឋបាលព្រៃឈើមានតួនាទី និងភារកិច្ច ........ ១៨
១.៦ សារៈប្រយោជន៍របស់ព្រៃឈើ ........ ១៩
១.៦.១ ព្រៃឈើជារនាំងការពារព្យុះ........ ១៩
១.៦.២ ព្រៃឈើជួយការពារទប់ទល់ការហូរច្រោះដី ........ ២០
១.៦.៣ ព្រៃឈើជួយកាត់បន្ថយពន្លឺថ្ងៃ និងសីតុណ្ហាភាពបរិយាកាស ........ ២០
១.៦.៤ ព្រៃឈើផ្តល់ផល និងអនុផល ........ ២០
១.៦.៥ ព្រៃឈើជួយការពារទប់ទល់ទឹកជំនន់ ........ ២១
១.៦.៦ ព្រៃឈើមានតួនាទីកាត់បន្ថយជាតិពុលទៅក្នុងបរិយាកាស........ ២១
១.៦.៧ ព្រៃឈើផ្តល់ផលប្រយោជន៍ចំពោះសេដ្ឋកិច្ចសង្គម ........ ២២
១.៦.៨ ព្រៃឈើមានសារៈប្រយោជន៍ចំពោះវប្បធម៌ ........ ២២
១.៧ ការចាត់គម្របព្រៃឈើ........ ២៣
១.៧.១ ព្រៃស្រោង(ព្រៃបៃតងជានិច្ច)........ ២៣
១.៧.២ ព្រៃពាក់កណ្តាលស្រោង ........ ២៣
១.៧.៣ ព្រៃល្បោះ........ ២៣
១.៧.៤ ព្រៃឈើប្រភេទផ្សេងៗ ........ ២៣
១.៧.៥ ដីមិនមែនគម្របព្រៃឈើ........ ២៤

សន្និដ្ឋានជំពូក ..... ២៥

# ជំពូកទី២

# ស្ថានភាពទូទៅនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅស្ថិតក្នុងឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប

២.១ លក្ខណៈទូរទៅនៃស្ថានភាពភូមិសាស្ត្រ ..... ២៦
២.១.១ ទីតាំងភូមិសាស្ត្រ និងប្រវត្តិចម្ការពូជឈើគ្រញូង ..... ២៦
២.១.២ របាយ និងដង់ស៊ីតេប្រជាជន ..... ២៧
២.១.៣ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន ..... ២៨
២.១.៤ ប្រភេទដី ..... ២៨
២.១.៥ លក្ខណៈអាកាសធាតុ ..... ២៩
២.១.៦ ធនធានព្រៃឈើនៅក្នុងស្រុកបន្ទាយស្រី ..... ២៩
២.១.៧ ធនធានសត្វព្រៃ ..... ៣០
២.១.៨ សក្តានុពលនៅតំបន់នោះ ..... ៣០
២.២ ចក្ខុវិស័យ គោលបំណង និងបេសកម្ម ..... ៣១
២.២.១ ចក្ខុវិស័យ ..... ៣១
២.២.២ គោលបំណង ..... ៣១
២.២.៣ បេសកកម្ម ..... ៣២
២.៣ រចនាសម្ព័ន្ធនៃការគ្រប់គ្រង តួនាទី និងភារកិច្ចរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ..... ៣២
២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រង ..... ៣២
២.៣.២ តួនាទី និងភារកិច្ច ..... ៣៣
២.៤ ទិដ្ឋភាពទូទៅនៅតំបន់ចម្ការពូជគ្រញូង ..... ៣៣
២.៤.១ ធនធនព្រៃឈើក្នុងតំបន់ចម្ការគ្រញូង ..... ៣៣
២.៤.២ បទបញ្ជារផ្ទៃក្នុងនៃការចេញ និងចូលតំបន់ចម្ការពូជគ្រញូង ..... ៣៤
២.៥ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានព្រៃឈើ ..... ៣៥
២.៥.១ គោលនយោបាយគ្រប់គ្រងធនធានព្រៃឈើ ..... ៣៥
២.៥.២ គោលនយោបាយគ្រប់គ្រងធនធានព្រៃឈើរបស់សង្កាត់រដ្ឋបាលកន្ទួតខ្នារក្រៅ..... ៣៧
២.៥.៣ ផែនការយុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានព្រៃឈើ ..... ៣៨

២.៦ ដំណើការនៃការគ្រប់គ្រងធនធានព្រៃឈើតំបន់ចម្ការពូជឈើគ្រញូង ............................ ៤០
២.៦.១ សកម្មភាពនៃការគ្រប់គ្រងព្រៃឈើរបស់សង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្នារក្រៅ............. ៤០
២.៦.២ ការអនុវត្តន៍ការងារផ្សេងៗក្រៅពីកម្មវិធីព្រៃឈើជាតិ ........................................... ៤៤
២.៦.៣ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើ.................................................. ៤៥
២.៦.៤ ប្រយោជន៍ដែលអាច និងរំពឹងទទួលបានពីការគ្រប់គ្រងព្រៃឈើ ............................ ៤៨
២.៦.៥ វិធានការ និងទិសដៅអនុវត្តន៍បន្តរបស់តំបន់ចម្ការពូជគ្រញូង................................ ៤៨
២.៧ ស្ថាប័ន និងប្រជាពលរដ្ឋដែលចូលរួមក្នុងគ្រប់គ្រងចម្ការពូជឈើគ្រញូង........................ ៤៩
២.៧.១ ការចូលរួមពីអង្គការ និងស្ថាប័នពាក់ព័ន្ធ.......................................................... ៤៩
២.៧.១ ការចូលរួមពីប្រជាជនមូលដ្ឋាន ...................................................................... ៤៩
២.៨ ភាពជោគជ័យ ........................................................................................... ៤៩
២.៩ បញ្ហាដែលជួបប្រទះក្នុងតំបន់ចម្ការគ្រាប់ពូជគ្រញូង .......................................... ៥០
សន្និដ្ឋានជំពូក ............................................................................................ ៥២

## ជំពូកទី៣

## ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

៣.១ ភាពជោគជ័យលើការគ្រប់គ្រងចម្ការពូជឈើគ្រញូងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ.៥៣
៣.១.១ការដាំស្តារឡើងវិញក្នុងចម្ការពូជឈើគ្រញូង.........................................................៥៣
៣.១.២ ការបង្ក្រាបបទល្មើស....................................................................................... ៥៦
៣.១.៣ ហេដ្ឋារចនាសម្ព័ន្ធ ........................................................................................ ៥៦
៣.១.៤ ការការពារភ្លើងព្រៃ.......................................................................................៥៧
៣.១.៥ ការអប់រំផ្សព្វផ្សាយ.......................................................................................៥៧
៣.២ បញ្ហាប្រឈម និងដំណោះស្រាយ ......................................................................... ៥៨
៣.២.១ បញ្ហាប្រឈម................................................................................................ ៥៨
៣.២.១.១ កម្រិតវប្បធម៌និងជំនាញបច្ចេកទេសរបស់មន្ត្រីសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ..៥៨
៣.២.១.២ បញ្ហាផ្សេងៗ ............................................................................................ ៦០
៣.២.២ ដំណោះស្រាយ ............................................................................................ ៦២
សន្និដ្ឋានជំពូក ............................................................................................ ៦៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................ ៦៦
២. ការផ្តល់អនុសាសន៍........................................ ៦៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ស.រ.ព ៖ សង្កាត់រដ្ឋបាលព្រៃឈើ
- ម ៖ ម៉ែត្រ
- FAO (Food and Agricultural Organization of the United Nation): អង្គការស្បៀងអាហា និងកសិកម្មសហប្រជាជាតិ
- DANIDA: ទីភ្នាក់ងារអភិវឌ្ឍដាណឺម៉ាក(ដានីដា)
- UTM (Universal Transvers Mercator) ការព្យាករផែនទីដែលមានលក្ខណៈជាមូលដ្ឋាន
- REDD+ (Reducing Emission form Deforestation and Forest Degradation) គម្រោងកាត់បន្ថយការបភាយពីការបាត់បង់ព្រៃ និងការបំផ្លាញព្រៃឈើ
- ACCB (Angkor Centre for Conservation of Biodiversity) មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ
- BCCP (Biodiversity Conservation Corridors Project) គម្រោងអភិរក្សជីវៈចម្រុះ
- IUCN (International Union for the Conservation of Nature) សហជីអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ
- Kg (Kilogram): គីឡូក្រាម

# បញ្ជីតារាង

**ទំព័រ**

តារាង ២.១៖ ស្ថិតិប្រជាពលរដ្ឋតាមបណ្តាលភូមិក្នុងឃុំឃុនរាម ខែមេសា ឆ្នាំ២០១៩ ............. ២៧
តារាង ២.២៖ ប្រភេទព្រៃ និងទំហំផ្ទៃដីព្រៃឈើទូទាំងស្រុកបន្ទាយស្រី.................................. ២៩
តារាង ២.៣៖ វត្ថុតាងបទល្មើសគ្រប់ប្រភេទដែលបានចាប់ឃាត់របស់សង្កាត់រដ្ឋបាលព្រៃឈើ ....... ៤៧
តារាង ៣.១៖ ការដាំស្តារឡើងវិញនូវកូនឈើក្នុងចម្ការពូជឈើគ្រញូង .................................. ៥៤
តារាង ៣.២៖ កម្រិតវប្បធម៌របស់មន្រ្តីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ....................... ៥៨
តារាង ៣.៣៖ ជំនាញបច្ចេកទេសរបស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ .............. ៥៩

# បញ្ជីរូបភាព

**ទំព័រ**

រូបភាព ២.១៖ ផែនទីខេត្តសៀមរាប ........................................................................................ ២៦
រូបភាព ២.២៖ សកម្មភាពបង្ក្រាបបទល្មើស ........................................................................... ៤៧

# បញ្ជីក្រាហ្វិក

**ទំព័រ**

ក្រាហ្វិក ៣.១៖ ការដាំស្តារឡើងវិញនូវកូនឈើក្នុងចម្ការពូជឈើគ្រញូង ................................ ៥៤
ក្រាហ្វិក ៣.២៖ កម្រិតវប្បធម៌របស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ .................... ៥៩
ក្រាហ្វិក ៣.៣៖ ជំនាញបច្ចេកទេសរបស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ........... ៦០

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១ ៖ ផែនទីចម្ការពូជឈើគ្រញូងទំហំ ១៨៨៨ ហិកតា
ឧបសម្ព័ន្ធ ២ ៖ ការចូលរួមសហការលើការគ្រប់គ្រងព្រៃឈើក៏ដូចជាក្នុងចម្ការពូជឈើគ្រញូង
ឧបសម្ព័ន្ធ ៣ ៖ សកម្មភាពចុះកម្មសិក្សាក្នុងតំបន់ចម្ការពូជឈើគ្រញូង

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជាគឺជា ប្រទេសមួយដែលស្ថិតនៅ ក្នុងតំបន់អាស៊ីអាគ្នេយ៍ មានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រការេ។ កម្ពុជាគឺស្ថិត នៅក្នុងតំបន់ត្រូពិចក្តៅហើយសើម អំណោយផលទៅដល់ប្រភេទឈើរាប់រយប្រភេទដែលមានការដុះលូតលាស់យ៉ាងច្រើន ពាសពេញផ្ទៃប្រទេសជាជំរកសត្វព្រៃយ៉ាងសម្បូរបែប។ នៅមុនទសវត្សរ៍ទី៧០ គម្របព្រៃឈើនៅប្រទេសកម្ពុជាមានប្រមាណជា ៧៣% នៃផ្ទៃប្រទេស។

ធនធានព្រៃឈើត្រូវបានគេទទួលស្គាល់ថា ជាសម្បត្តិធម្មជាតិ ដ៏មានតម្លៃបំផុត សម្រាប់មនុស្ស និងសត្វដែលរស់នៅលើផែនដី។ មនុស្ស សត្វ ត្រូវការព្រៃឈើជាចាំបាច់ សម្រាប់ការរស់រៀនមានជីវិត។ ព្រៃឈើ បានរងការធ្លាក់ចុះដោយកត្តាជាច្រើន ដែលកត្តាទាំងនោះរួមមានដូចជាកត្តាមនុស្ស និងកត្តាធម្មជាតិជាដើម។ មនុស្សបានលុកទន្រ្ទាន កាប់បំផ្លាញព្រៃឈើយ៉ាងអាណាធិបតេយ្យ យកដីធ្វើកសិកម្ម ដីលំនៅដ្ឋាន។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ការទន្រ្ទានដីព្រៃ ធ្វើដីកសិកម្ម និងដីលំនៅដ្ឋាន បានកើតមានជាហូរហែរបង្កភាពអាណាធិបតេយ្យ ដែលជាមូលហេតុធ្វើឲ្យមានការ វិនាសដល់សម្បត្តិធនធានធម្មជាតិយ៉ាងខ្លាំង ជាពិសេស ព្រៃឈើជាតិ សត្វព្រៃ និងជីវចម្រុះ។ ព្រៃឈើ មានការបាត់បង់ ជាហេតុធ្វើឲ្យ ប្រភេទឈើ ប្រភេទសត្វព្រៃ ជីវចម្រុះមួយចំនួនបានផុតពូជ និងមួយចំនួនទៀតបានកំពុងរងការគំរាមគំហែងឈានទៅរកការផុតពូជផងដែរ។ ការបាត់បង់ ព្រៃឈើ សត្វព្រៃ និងជីវចម្រុះ គឺជាបញ្ហាមួយដែលពិភពលោក ក៏ដូចជាប្រទេសកម្ពុជា កំពុងតែជួបប្រទះ ហើយមានការព្រួយបារម្ភនិងយកចិត្តទុកដាក់ក្នុងការការពារ ក្នុងការអភិរក្សប្រភេទឈើ សត្វព្រៃ និងជីវចម្រុះនៅក្នុងតំបន់ក្នុងគោលបំណង ឲ្យមាននិរន្តរភាព និងមានលំនឹងប្រព័ន្ធអេកូឡូស៊ី។ ដើម្បីចូលរួមចំណែក ក្នុងការដោះស្រាយបញ្ហាដែលកើតមាន ចំពោះធនធានធម្មជាតិ ព្រៃឈើ សត្វព្រៃ និងជីវចម្រុះ រាជរដ្ឋាភិបាលកម្ពុជាដែលមានរដ្ឋបាលព្រៃឈើជាស្ថាប័នជំនាញ បានដើរតួនាទីយ៉ាងសកម្ម ក្នុងការរៀបចំ និងអនុវត្តច្បាប់ព្រៃឈើក្នុងការអភិរក្សព្រៃឈើ និងជីវចម្រុះ។ តំបន់ព្រៃឈើសំខាន់ៗ ទូទាំងប្រទេស បានត្រូវដាក់ទៅជាព្រៃការពារ និងតំបន់ការពារដែលមុខងារយ៉ាងសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវ ផ្នែកវិទ្យាសាស្ត្រ ក្នុងការសិក្សាលើការអភិរក្សជីវចម្រុះ សត្វព្រៃ និងព្រៃឈើ។ ការអភិរក្សព្រៃឈើទុកជាតំបន់គ្រាប់ពូជពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអភិរក្សព្រៃឈើ ក្នុងសកលនាពេលបច្ចុប្បន្ន ស្របពេលដែលប្រភេទឈើមួយចំនួនធំបានកំពុង តែរងការគំរាមគំហែងជិតផុតពូជ

និងបានបាត់បង់ផុតពូជរួចរាល់ទៅហើយ។ ជាក់ស្តែងប្រភេទឈើប្រណិតមួយចំនួនរួមមានដូចជា ប្រភេទឈើ បេង គ្រញូង នាងនួន ធ្នង់ ធ្នឹក និងបណ្តាឈើប្រណិតផ្សេងៗទៀត។ ប្រភេទឈើទាំងនេះ ជាប្រភេទឈើដែលមានតម្លៃខ្ពស់ នៅក្នុងទីផ្សារក្នុង និងក្រៅប្រទេស ព្រោះតម្រូវការរបស់ប្រជាជន ទាំងក្នុងស្រុក និងក្រៅស្រុក ដូចនេះប្រភេទឈើទាំងនេះបានរងការកាប់បំផ្លាញស្ទើរតែជិតផុតពូជពីក្នុងតំបន់។ ជាក់ស្តែង ចម្ការពូជឈើគ្រញូងដែលគេចាត់ទុកថាជា តំបន់អភិរក្សប្រភពគ្រាប់ពូជ ដែលមានផ្ទៃដី ១៨៨៨ហិចតា គឺស្ថិតនៅក្នុងការគ្រប់គ្រងយ៉ាងតឹងរឹងបំផុតពីសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ។ ដូចនេះដើម្បីចូលរួមចំណែកក្នុងការស្វែងយល់ពី ការអភិរក្សព្រៃឈើទុកជា តំបន់អភិរក្ស ប្រភេទគ្រាប់ពូជ ហេតុនេះហើយទើបមាន ប្រធានបទសារណាបានត្រូវជ្រើសរើសយកមកសិក្សា ដើម្បីស្វែងយល់បន្ថែមក្នុងការអភិរក្សប្រភព និងកិច្ចការការពារតំបន់គ្រាប់ពូជជាពិសេសពូជឈើគ្រញូង ដែលប្រធានបទនោះគឺ "ការគ្រប់គ្រងធនធានព្រៃឈើតំបន់ចម្ការពូជឈើគ្រញូងរបស់សង្កាត់រដ្ឋព្រៃឈើ កន្ទួតខ្នារក្រៅ" ។

## ២. ចំណោទបញ្ហា

នាពេលបច្ចុប្បន្ន ផ្ទៃដីព្រៃឈើរងការទន្ទ្រាន និងកាប់បំផ្លាញពីសំណាក់ប្រជាជនដោយខុសច្បាប់ ជាហេតុធ្វើឲ្យមានការបាត់បង់គម្របព្រៃឈើ។ ការបាត់បង់គម្របព្រៃឈើធ្វើឲ្យមានការព្រួយបារម្ភពីការផុតពូជប្រភេទឈើប្រណិតមួយចំនួន ពោលធ្វើឲ្យបាត់បង់ប្រភពព្រៃឈើប្រណិត ជាហេតុទាមទារការយកចិត្តទុកដាក់ក្នុងការសិក្សា ការពារ និងអភិរក្សយ៉ាងតឹងរឹងបំផុតដោយរក្សាទុកតំបន់អភិរក្សប្រភេទឈើប្រណិតទាំងឡាយទូទាំងប្រទេស។ ដូចនេះ តំបន់អភិរក្សពូជឈើគ្រញូង ក្នុង ឃុំឃុនរាម ស្រុកបន្ទាយស្រី មានដំណើរការយ៉ាងណាខ្លះ? និងបញ្ហា នឹងដំណោះស្រាយបែបណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបឲ្យបានសមស្របទៅ និងប្រធានបទខាងលើដែលយកមកសិក្សាស្រាវជ្រាវមានគោលបំណងមួយចំនួនបានបង្កើតឡើង ដែលគោលបំណងទាំងនោះរួមមានដូចជា៖

- ស្វែងយល់អំពី ការការពារ ការជ្រើសរើស និងគ្រប់គ្រង តំបន់ប្រភពគ្រាប់ពូជនៅនឹងកន្លែងនៃប្រភេទគ្រញូងដើម្បីរក្សាទុកជាព្រៃពូជរបស់រដ្ឋាភិបាលព្រៃឈើក្នុងទីតាំងសិក្សា
- បង្ហាញពីវិធានការសំខាន់ៗនៃការអភិរក្សតំបន់ ប្រភពគ្រាប់ពូជ និងវិភាគលើបញ្ហាប្រឈមនៃការអភិរក្សព្រៃឈើក្នុងតំបន់សិក្សា
- សិក្សាអំពីបញ្ហានានា នៅលើការគ្រប់គ្រង

– រកដំណោះស្រាយលើអថេរបញ្ហា ដើម្បីធានាឲ្យបាននូវគ្រប់គ្រងប្រកបដោយនិរន្តភាព។

## ៤. ទំហំ និងដែនកំណត់ស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវមួយនេះ យើងបានធ្វើការជ្រើសរើសយកតំបន់ចម្ការពូជឈើគ្រញូង ដែលស្ថិតនៅ ឃុំយុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ស្ថិតក្រោមការគ្រប់គ្រងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ដើម្បីធ្វើកម្មសិក្សាចុះសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រធានបទ "**ការគ្រប់គ្រងធនធានព្រៃឈើតំបន់ចម្ការពូជឈើគ្រញូងរបស់សង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្នារក្រៅ**" ចាប់ពីឆ្នាំ ២០១៤ មកដល់បច្ចុប្បន្ន។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ការសម្រេចបាននូវការស្រាវជ្រាវមួយនេះ យើងបានធ្វើការបកស្រាយតាមរយៈព័ត៌មានដែលបានមកពីប្រភពទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ ដើម្បីឆ្លើយតបនឹងចំណោទបញ្ហា និងគោលបំណងនៃការសិក្សាស្រាវជ្រាវ។

– ទិន្នន័យចម្បង ៖ ប្រមូលព័ត៌មានតាមរយៈការចុះសម្ភាសន៍ ដែលធ្វើការនៅក្នុងតំបន់នោះផ្ទាល់ ដោយប្រើប្រាស់សំណួរបែបបរិមាណវិស័យ និងគុណវិស័យមួយផ្នែកតូច។
– ទិន្នន័យបន្ទាប់បន្សំ ៖ ប្រមូលបានតាមរយៈការអនុញ្ញាត និងអនុគ្រោះរបស់ នូវការផ្តល់ជាឯកសាររបាយការណ៍ សង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្នារក្រៅនឹងខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប និងមួយផ្នែកទៀតប្រមូលពីសៀវភៅ ឯកសារ របាយការណ៍ដែលពាក់ព័ន្ធ រួមមានឯកសារដែលបានចងក្រងកន្លងមករបស់សិស្សច្បង ឯកសារទាក់ទងនឹងជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឯកសារក្នុងបណ្ណាល័យសេដ្ឋកិច្ចនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងឯកសារក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម(ចំការដូង) ច្បាប់ស្តីពីព្រៃឈើ(២០០២) សេចក្តីណែនាំអំពីច្បាប់ព្រៃឈើ(២០០៥) កម្មវិធីព្រៃឈើជាតិ(២០១០-២០២៩) សេចក្តីណែនាំពីគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព និងឯកសារដែលដកស្រង់ចេញពីគេហទំព័រអ៊ីនធើណេតមួយចំនួន។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សាមួយនេះមានសារៈសំខាន់ដូចជា៖

– ជាបទពិសោធន៍មួយយ៉ាងសំខាន់សម្រាប់ខ្លួនឯងក្នុងការអនុវត្តន៍ជាក់ស្តែង និងជាសមិទ្ធិផលមួយក្រោយពីបញ្ចប់ការសិក្សា

- ជាឯកសារ ឬជាសៀវភៅជំនួយស្មារតីដល់អ្នកដែលមានភារកិច្ចក្នុងការការពារ និងអភិរក្សធនធានព្រៃឈើ
- ជាប្រយោជន៍ដល់ប្រជាជនដែលស្រលាញ់សម្បត្តិធម្មជាតិ
- ជាប្រយោជន៍ដល់សង្គម សេដ្ឋកិច្ច បរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌ តាមរយៈការជម្រុញឲ្យមានការចូលរួមការពារ និងអភិរក្សធនធានព្រៃឈើ
- ជាសៀវភៅ ឬឯកសារសម្រាប់បង្កើនចំនេះដឹងដល់សិក្សានុសិស្ស ឬនិស្សិតជំនាន់ក្រោយ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សានេះ ចែកចេញជា ៣ ជំពូក ដូចខាងក្រោមៈ

- ជំពូកទី១ រួមមាន និយមន័យនៃពាក្យគន្លឹះដែលទាក់ទងនឹងប្រធានបទ សញ្ញាណសំខាន់ៗពាក់ព័ន្ធនឹងប្រធានបទ វិធីសាស្ត្រគ្រប់គ្រងព្រៃឈើ ទ្រឹស្តីរបស់អ្នកប្រាជ្ញ ទ្រឹស្តីកិតិយុទ្ធអំពីច្បាប់ព្រៃឈើ គោលនយោបាយផែនការយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធ ចុងក្រោយការបង្ហាញពីបទពិសោធន៍បរទេស។
- ជំពូកទី២ រួមមាន ទីតាំងភូមិសាស្ត្រ និងប្រវត្តិចម្ការពូជឈើគ្រញូង នៃរួមជាមួយស្ថានភាពទូទៅក្នុងតំបន់ ចក្ខុវិស័យ បេសកកម្ម រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច សក្តានុពលនៅតំបន់នោះ ដំណើការគ្រប់គ្រងព្រៃឈើ បញ្ហាប្រឈម និងដំណោះស្រាយ។
- ជំពូកទី៣ រួមមាន ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ សមិទ្ធិផលសំខាន់ៗ បញ្ហាប្រឈម ដំណោះស្រាយ និងសន្និដ្ឋាន។

# ជំពូក ១ ៖
# រំលឹកទ្រឹស្តីការគ្រប់គ្រងធនធានព្រៃឈើ

# ជំពូកទី១
# រំលឹកទ្រឹស្តីការគ្រប់គ្រងធនធានព្រៃឈើ

## ១.១ និយមន័យ

### ១.១.១ ការគ្រប់គ្រងព្រៃឈើ

ការគ្រប់គ្រងព្រៃឈើ គឺជាវិធានការណ៍ចម្រុះអនុវត្តទៅលើសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងធនធានព្រៃឈើ ដែលរួមបញ្ចូលនូវកិច្ចការរដ្ឋបាល ច្បាប់ សេដ្ឋកិច្ច សង្គម បច្ចេកទេស វិទ្យាសាស្ត្រ ដែលពាក់ព័ន្ធនឹងការការពារ ការអភិរក្សប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ការអភិវឌ្ឍន៍ ការប្រើប្រាស់នឹងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។[1]

### ១.១.២ ព្រៃឈើដោយ FAO

ជាការពិតព្រៃឈើត្រូវបាន គេអោយនិយមន័យខុសៗគ្នាជាច្រើនដែលឆ្លុះបញ្ចាំងអំពី ជីវៈចម្រុះនៃព្រៃឈើនោះ និងប្រព័ន្ធអេកូឡូស៊ីព្រៃឈើ (Forest Ecosystem) នៅក្នុងពិភពលោក និងគឺជាជីវៈចម្រុះនៃមនុស្សលោកចំពោះព្រៃឈើនោះ។ នៅក្នុងឯកសារ FAO ព្រៃឈើមានន័យថាគឺជាតំបន់ដែលមានផ្ទៃដីចាប់ពី ០.៥ ហិកតា ហើយមានគម្របព្រៃច្រើនជាង១០ភាគរយ ហើយមិនមែនជាដីកសិកម្ម ឬក៏មិនមែនជាដីដែលបានប្រើប្រាស់ និងមិនមែនជាព្រៃមានលក្ខណៈផ្សេងៗទៀត។ ក្នុងករណីព្រៃក្មេង ( Young forest ) ឬតំបន់មានដុះដើមឈើតាមលក្ខណៈអាកាសធាតុនោះដើមឈើ ត្រូវមានលទ្ធភាពដុះរហូតដល់កម្ពស់ ៥ ម៉ែត្រ ក្នុងតំបន់កំណើតរបស់វា ហើយចាំបាច់ត្រូវមានកន្សោមស្លឹកត្រួតលើគ្នា។[2]

### ១.១.៣ ព្រៃឈើដោយ SOKASOV

អ្នកវិទ្យាសាស្ត្រខាងដាំព្រៃឈើរបស់សហភាពសូវៀត បានកំណត់ថាព្រៃឈើ គឺជាការប្រមូលផ្តុំនៃជីវិតទាំងអស់លើដីដែលកំណត់រួមជាមួយរបស់គ្មានជីវិតទាំងឡាយ។ ការប្រមូលផ្តុំនៃរបស់មានជីវិត និងរបស់គ្មានជីវិតគឺជាដំណុះព្រៃឈើមួយ នៅក្នុងប្រភេទដីមួយកំណត់ ដែលមានចំណងពាក់ព័ន្ធរវាងគ្នាទៅវិញទៅមក ពីស្រទាប់រុក្ខជាតិ ពពួកសត្វ អតិសុខុមសត្វ សត្វនៅក្នុងដី ពីមេសិលា ពីផ្ទៃទឹកក្នុងដី អាកាសធាតុនឹងប្រភេទដីបង្កឡើងនូវការប្រែប្រួលនៃអង្គធាតុសរីរៈថាមពល

[1] រដ្ឋបាលព្រៃឈើ, សេចក្តីណែនាំការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ២០០៥, ទំព័រ ២

[2] អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ(FAO)

ទៅតាមបាតុភូតធម្មជាតិផ្សេងៗ។[3]

### ១.១.៤ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

គឺជាដំណើរការគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដើម្បីឆ្លើយតបទៅនឹងគោលដៅជាក់លាក់មួយ ឬច្រើននៃការគ្រប់គ្រងព្រៃឈើដោយធានាអោយបានជាប្រចាំនូវផលិតកម្មផលអនុផលព្រៃឈើ និង សេវាកម្មព្រៃឈើ និងមិនធ្វើអោយបាត់បង់នូវតម្លៃផលិតផល ក៏ដូចជាទិន្នផលទៅអនាគតរបស់ព្រៃឈើ ព្រមទាំងមិនធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍សង្គម បរិស្ថាន និងវប្បធម៌។ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពក្នុងកម្រិតជាតិ តម្រូវឲ្យមានគោលនយោបាយវិស័យព្រៃឈើជាតិ និងផែនការគ្រប់គ្រងវិស័យព្រៃឈើរយៈពេលវែងជាមូលដ្ឋាន ដើម្បីធានានូវនិរន្តរភាពនៃមជ្ឈដ្ឋានព្រៃឈើ និងបណ្តាលមុខងារសំខាន់ៗរបស់ព្រៃឈើ។[4]

## ១.២ ក្របខ័ណ្ឌនយោបាយព្រៃឈើ[5]

ក្របខ័ណ្ឌនយោបាយព្រៃឈើមួយដែលសមស្រប គឺជាមូលដ្ឋានសម្រាប់អនុវត្តកម្មវិធីគ្រប់គ្រងព្រៃឈើ និងការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព។ នយោបាយព្រៃឈើជាតិគួរមានផ្នែកមួយចែកពីរនយោបាយប្រើប្រាស់ដីដែលនឹងនាំអោយមាននូវតុល្យភាពរវាងការប្រើប្រាស់ និងការអភិរក្សព្រៃឈើជាមួយកសិកម្ម និងការប្រើប្រាស់ដីផ្សេងទៀត។

ទិដ្ឋភាពសំខាន់នៃនយោបាយព្រៃឈើជាតិ យ៉ាងហោចណាស់ក៏ត្រូវរួមបញ្ចូលនូវៈ

- សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដែលអាស្រ័យលើការធានាសិទ្ធិកាន់កាប់ដីរយៈពេលវែង សម្រាប់គ្រប់គ្រងភាគីពាក់ព័ន្ធ
- វិធានការម៉ឹងម៉ាត់ និងមិនរុញរាដើម្បីបង្ក្រាបរាល់សកម្មភាពកាប់ឈើ ការបរបាញ់ ការចាប់សត្វ និងការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់
- ការវាយតម្លៃធនធានព្រៃឈើជាតិ ដើម្បីពង្រឹងមូលដ្ឋានការការពារព្រៃឈើការប្រើប្រាស់ និងទិដ្ឋភាពនៃការគ្រប់គ្រងព្រៃឈើផ្សេងទៀតសម្រាប់រយៈពេលវែង
- ការកំណត់និតិវិធី និងដំណើរការដែលនឹងអនុញ្ញាតឲ្យរាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការសម្រេចចិត្តស្តីពីការប្រើប្រាស់ដីបានសមហេតុផល និងមានតុល្យភាព

---

[3] SOKASOV, ១៩៦៤

[4] រដ្ឋបាលព្រៃឈើ, សេចក្តីណែនាំការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ២០០៥, ទំព័រ ៤

[5] នាយកដ្ឋានរុក្ខាប្រមាញ់, គោលការណ៍ណែនាំសម្រាប់គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព, ទំព័រ ១២, ១៣

- ការបញ្ជាក់ច្បាស់លាស់ពីនិតិវិធីស្របច្បាប់ ដើម្បីធានាប្រសិទ្ធិភាពនៃការតាមដានការគ្រប់គ្រងព្រៃឈើ និងការរៀបចំអោយមានការអនុវត្តន៍តាមកិច្ចព្រមព្រៀង និងកិច្ចសន្យានានា
- ការទាញយកផលចំណូលជាអតិបរមាសម្រាប់រាជរដ្ឋាភិបាលកម្ពុជាពីការលក់ឈើហ៊ុប និងផលិតផលព្រៃឈើផ្សេងទៀត
- ការអភិរក្សតំបន់តំណាងជីវៈចម្រុះក្នុងព្រៃឈើប្រទេសកម្ពុជា។

**១.២.១ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព**

ការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើប្រទេសកម្ពុជា និងផ្អែកលើគោលការណ៍សំខាន់ៗដូចតទៅៈ

- ការគ្រប់គ្រងព្រៃធម្មជាតិរបស់ប្រទេសប្រកបដោយនិរន្តរភាព គឺជាវិភាគទានមួយដ៏សំខាន់បំផុតរបស់វិស័យព្រៃឈើ ចំពោះកម្មវិធីអភិវឌ្ឍន៍ជាតិដោយសារតែសក្តានុពលនឹងលទ្ធភាពធនធានព្រៃឈើក្នុងការបង្កើតចំណូលហិរញ្ញវត្ថុប្រចាំ ការផ្តល់ការងារយូរអង្វែងដល់ប្រជាជន ការបំពេញសេចក្តីប្រាថ្នាដ៏ច្រើននៃសហគមន៍មូលដ្ឋាន និងការឆ្លើយតបនឹងតម្រូវការបរិស្ថាន វប្បធម៌ និងមនុស្សនាពេលអនាគត
- ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងក្រសោបនូវសកម្មភាពមានតុល្យភាព និងទូលំទូលាយទាំងឡាយដែលរួមបញ្ចូលនូវផែនការគ្រប់គ្រងរយៈពេលវែង និងរយៈពេលខ្លី ការធ្វើនិទស្សន៍ទិន្នផលការដាក់បញ្ញត្តិ និងត្រួតពិនិត្យរុក្ខវប្បកម្ម និងការការពារព្រៃឈើប្រកបដោយប្រសិទ្ធិភាព។ ការប្រមូលផលព្រៃឈើ គឺជាផ្នែកមួយនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដែលមិនមែនជាសកម្មភាពដាច់ដោយឡែក ឬពុំមានការទាក់ទងនិងការគ្រប់គ្រងឡើយ
- ក្នុងឋានៈជាទីភ្នាក់ងាររាជរដ្ឋាភិបាលដែលមានសមត្ថកិច្ចក្នុងវិស័យព្រៃឈើ នាយកដ្ឋានរុក្ខា-ប្រមាញ់មានតួនាទីចម្បង ក្នុងការដាក់បទបញ្ជា និងត្រួតពិនិត្យការការពារ និងគ្រប់គ្រងព្រៃឈើដែលជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍។

**១.២.២ ការការពារព្រៃឈើ**

ការការពារព្រៃឈើមានសារៈសំខាន់ជាមូលដ្ឋាន ជាពិសេសលើការទប់ស្កាត់ការចេញលិខិតអនុញ្ញាតអោយធ្វើអាជីវកម្មព្រៃឈើច្រើនហួសហេតុ និងការធ្វើអាជីវកម្មល្មើសច្បាប់។ សារៈសំខាន់ជាមូលដ្ឋាននៃការពារព្រៃឈើមានដូចតទៅៈ

- ដើម្បីរក្សាបូរណភាពនៃប្រព័ន្ធអេកូឡូស៊ី (ecological integrity) ព្រៃឈើ និងដើម្បីរក្សាលទ្ធភាពផ្តល់ផលនៃធនធានព្រៃឈើ
- ដើម្បីរក្សានៃសមត្ថភាពនៃប្រព័ន្ធអេកូឡូស៊ីព្រៃឈើក្នុងការបន្តពូជដោយធម្មជាតិ និងធានាថាប្រភពគ្រាប់ពូជនៃរាល់ដើមឈើនៅក្នុងប្រព័ន្ធអេកូឡូស៊ីនេះត្រូវបានរក្សាទុកព្រមទាំងធានាថាដី និងការបំផ្លាញរុក្ខជាតិស្ថិតក្នុងកម្រិតទាបបំផុត។

ដើម្បីការពារសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ពីការរំលោភបំពាន ការប្រើប្រាស់មិនសមរម្យ ការបំផ្លាញឬការលួចផលិតផលឈើមានតម្លៃ។

### ១.២.៣ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

សមាសភាគជាមូលដ្ឋាននៃគោលនយោបាយព្រៃឈើជាតិ គឺជាការកំណត់អត្តសញ្ញាណសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ដែលរួមមានព្រៃឈើស្ថិតនៅក្រោមកម្មសិទ្ធិគ្រប់ប្រភេទ ដែលផ្អែកលើការធានាសិទ្ធិកាន់កាប់ព្រៃឈើរយៈពេលវែងសំរាប់ព្រៃសម្បទានសហគមន៍មូលដ្ឋាន និងអ្នកប្រើប្រាស់ព្រៃឈើដ៏ទៃទៀត។ បើសិនជាគ្មានការកំណត់នូវសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ទេនោះគេមិនអាចធ្វើផែនការគ្រប់គ្រងព្រៃឈើអោយមាននិរន្តរភាព ឬធ្វើអោយកម្មវិធីគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពបានឡើយជាពិសេសការការពារព្រៃឈើ និងការត្រួតពិនិត្យការប្រមូលផលព្រៃឈើ។ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមានៈ

១. ព្រៃបម្រុងទុកអចិន្ត្រៃយ៍

២. ព្រៃឯកជន

ព្រៃបម្រុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទៈ

១. ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្មផលអនុផលព្រៃឈើនិរន្តរភាព ដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់។

២. ព្រៃឈើការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ។

៣.ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់អោយស្ថិតនៅក្នុងចំណោមថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍រហូតដល់មានការសម្រេចអោយប្រើប្រាស់ និងអភិវឌ្ឍន៍សម្រាប់គោលបំណងផ្សេងទៀតដោយរាជរដ្ឋាភិបាល។

### ១.២.៤ ការគ្រប់គ្រងព្រៃសម្បទាន

ការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើធម្មជាតិមានលក្ខណៈពាណិជ្ជកម្មអាស្រ័យលើការចាត់តាំង និងការគ្រប់គ្រងតាមបែបសម្បទាន។ នេះគឺជាប្រព័ន្ធផ្តល់សិទ្ធិកាន់កាប់ដែលរាជរដ្ឋាភិបាលបានធ្វើការជ្រើសរើសដើម្បីប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើរបស់ជាតិ។ ក្រោមប្រព័ន្ធព្រៃសម្បទានក្រុមហ៊ុនឯកជនអាចត្រូវបានផ្តល់នូវផ្ទៃដីព្រៃឈើជាកំណត់ណាមួយ និងសិទ្ធិប្រមូលផល ព្រមទាំងគ្រប់គ្រងព្រៃឈើសម្រាប់រយៈពេលជាក់លាក់មួយស្របទៅតាមតម្រូវការច្បាប់ និង កិច្ចសន្យា។ ព្រៃសម្បទានិក និងទទួលខុសត្រូវលើការងារគ្រប់គ្រងជាក់លាក់នានាដែលរួមបញ្ចូលទាំងការធ្វើផែនការការការពារព្រៃឈើ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការបង់ថ្លៃកាតព្វកិច្ចនានា។ ផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងត្រូវបានការពារតាមរយៈការធ្វើផែនការសមស្រប និងការរៀបចំចេញលិខិតអនុញ្ញាតទាំងឡាយ។

### ១.២.៥ ការធ្វើផែនការគ្រប់គ្រង

ការទទួលខុសត្រូវលើការធ្វើផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង មធ្យម ប្រចាំឆ្នាំ និងអាស្រ័យលើព្រៃសម្បទាន។ ផែនការគ្រប់គ្រងប្រចាំឆ្នាំ រយៈពេលមធ្យម និងរយៈពេលវែង និងបកស្រាយបញ្ចូលនយោបាយព្រៃឈើជាតិទៅក្នុងកម្មវិធីដែលមានការរៀបចំយ៉ាងម៉ត់ចត់ និងមានការសម្របសម្រួលយ៉ាងល្អ។ ផែនការនឹងដាក់ចុះនូវបទបញ្ញាត្តិការពារការធ្វើសារពើភ័ណ្ឌ ការកំណត់ទិន្នផល ការប្រមូលផលព្រៃឈើ រុក្ខវប្បកម្ម ការអភិរក្សជីវៈ និងទីជំរាល ការការពារ ផលប្រយោជន៍សហាកម្មមូលដ្ឋាន ការតាមដានត្រួតពិនិត្យ និង ការប្រតិបត្តិការងារព្រៃផ្សេងទៀត ដែលបញ្ជាក់ច្បាស់ពីគោលដៅ សកម្មភាព និង ការរៀបចំការត្រួតពិនិត្យ។

ការធ្វើផែនការ និងការរៀបចំប្រតិបត្តិការងារអាជីវកម្មព្រៃឈើរួមមានបីដំណាក់កាលដូចខាងក្រោម៖

ក. ការធ្វើផែនការរយៈពេលវែង សម្រាប់គ្រប់គ្រងព្រៃសម្បទានទាំងមូល។ ផែនការនេះរៀបចំឡើងសម្រាប់ខួបអាជីវកម្មរយៈពេលពី២០-៣០ឆ្នាំ។

ខ. ការធ្វើផែនការរយៈពេលមធ្យម សម្រាប់អនុតំបន់ផែនការនេះរៀបចំឡើងសម្រាប់ប្រតិបត្តិរយៈពេល៣-៦ឆ្នាំ។

គ. ការធ្វើផែនការប្រចាំឆ្នាំសម្រាប់គ្រប់គ្រងកម្រិតគុប និងប្លុកគឺផ្តោតទៅលើធ្វើផែនការផ្អែកលើលិទ្ធភាពផ្តល់ផលសម្រាប់រយៈពេល ១ឆ្នាំ ហើយព្រៃដី ព្រៃគុប ត្រូវបានបែងចែកជាប្លុកអាជីវកម្ម ដើម្បីប្រើប្រាស់សម្រាប់ត្រួតពិនិត្យ និងតាមដានឃ្លាំមើលប្រតិបត្តិការប្រមូលផលព្រៃ

ឈើលើទីតាំងព្រៃគុបផ្ទាល់ ហើយផែនការទាំងនេះ និងផ្អែកលើយុទ្ធសាស្ត្រនៃការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង និងមធ្យម។

### ១.២.៦ ផែនការគ្រប់គ្រងព្រៃឈើកម្រិតអនុតំបន់

ផែនការគ្រប់គ្រងព្រៃឈើកម្រិតអនុតំបន់រយៈពេលមធ្យមនឹងត្រូវបានឯកភាពពី នាយករុក្ខា-ប្រមាញ់។ តម្រូវការជាមូលដ្ឋានដើម្បីទទួលបាននូវការឯកភាពលើផែនការគ្រប់គ្រងកម្រិតអនុតំបន់មាន៖

- សេចក្តីសង្ខេប និង កំណត់លក្ខណៈពិសេសៗ ដែលមានរៀបរាប់ពីតំបន់ព្រំប្រទល់ ការធ្វើសារពើភ័ណ្ឌ ការបែងចែកគុប ការកំណត់បរិមាណឈើដែលអនុញ្ញាតអោយធ្វើអាជីវកម្មប្រចាំឆ្នាំ ការរៀបចំកិច្ចការពារព្រៃឈើ ការធ្វើផែនការវិស្វកម្មព្រៃឈើ ការកំណត់ព្រំប្រទល់ និងការគ្រប់គ្រងតំបន់គ្រប់គ្រងពិសេសការប្រតិបត្តិការងារគ្រប់គ្រងព្រៃឈើ ការត្រួតពិនិត្យតាមដានឡើងវិញការចូលរួមពីសហគមន៍ និងតម្រូវការកិច្ចអភិរក្សបរិស្ថាន។
- លក្ខណៈពិសេសចម្បងនៃផែនការត្រូវបានពន្យល់ និងពិភាក្សាដោយផ្ទាល់ជាមួយមន្ត្រីជំនាញ នាយកដ្ឋានរុក្ខា-ប្រមាញ់។[6]

## ១.៣ គោលការណ៍នៃការគ្រប់គ្រងព្រៃឈើ

### ១.៣.១ គោលនយោបាយវិស័យព្រៃឈើជាតិ

ក្នុងឆ្នាំ២០០២ កន្លងទៅនេះរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍មួយស្តីពី គោលនយោបាយវិស័យព្រៃឈើជាតិដែលមានគោលបំណងសំខាន់៥ចំនុចដូចខាងក្រោម៖

- ការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើជាតិប្រកបដោយនិរន្តរភាព ត្រូវផ្តល់នូវវិភាគទានអតិបរមាចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាព ក្នុងព្រះរាជាណាចក្រកម្ពុជា។
- ធនធានព្រៃឈើជាតិដែលសល់ត្រូវរក្សាទុកជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយរៀបចំផែនការអភិរក្ស និងគ្រប់គ្រងប្រកបដោយនិរន្តរភាពសំដៅស្តារឡើងវិញអោយបាននូវផលជាអតិបរមានៃព្រៃឈើ និងធនធានព្រៃឈើ។
- ត្រូវធានាការចូលរួមជាអតិបរមាពីសំណាក់ផ្នែកឯកជន និងសហគមន៍មូលដ្ឋានក្នុងបែបផែននៃការអភិរក្ស និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពសំដៅធានាសន្តិសុខស្បៀងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

[6] រដ្ឋបាលព្រៃឈើ, សេចក្តីណែនាំការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ២០០៥

- ត្រូវធានាការសម្របសម្រួលគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់អោយបានទូលំទូលាយក្នុងដំណើរការរៀបចំ និងគ្រប់គ្រងព្រៃឈើជាតិដើម្បីធានានូវការឆ្លើយតបទៅនឹងទស្សនៈផលប្រយោជន៍ និងគោលបំណងរបស់គ្រប់មជ្ឈដ្ឋានដែលមានផលប្រយោជន៍ពាក់ព័ន្ធទៅនឹងព្រៃឈើក្រោមគោលការណ៍និរន្តរភាព។
- ត្រូវបន្តជំរុញដំណើរការដាំដើមឈើឡើងវិញនៅតាមទីកន្លែងដែលអាចដាំបាន និងការពារកូនឈើដែលបានដាំរួចកន្លងមកដើម្បីបង្កើនធនធានព្រៃឈើ។

ជារួមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងកាគ្រប់គ្រងធនធានព្រៃឈើជាតិគឺគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិអោយបានត្រឹមត្រូវដោយធានាអោយបាននូវនិរន្តរភាពនៃការប្រើប្រាស់ជាពិសេសគឺធនធានព្រៃឈើ។[7]

### ១.៣.២ ច្បាប់ ក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានក្រោមច្បាប់ដែលពាក់ព័ន្ធនឹងវិស័យដើមឈើ[8]

ការគ្រប់គ្រងព្រៃឈើជាការងារមួយរបស់រាជរដ្ឋាភិបាលដែលត្រូវយកចិត្តទុកដាក់ និងចាត់វិធានការជាបន្តបន្ទាប់ ដើម្បីគ្រប់គ្រងធនធានព្រៃឈើអោយទទួលបានលិទ្ធផលល្អ ទាំងនោះគឺត្រូវពឹងផ្អែកលើ ច្បាប់ ក្រឹត អនុក្រឹត និង លិខិតបទដ្ឋានក្រោមច្បាបើជាច្រើនដែលបានអនុម័តក្នុងឆ្នាំ ២០០៣-២០០៦ កន្លងមកនេះរួមមានៈ

**ក. ព្រះរាជក្រឹត្យ (Royal-Decree)**

- ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦/០២/២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី របស់ព្រះរាជវាំង។

**ខ. អនុក្រឹត្យ (Sub-decree)**

- អនុក្រឹត្យលេខ៦៤ អនក្រ.បកចុះថ្ងៃទី ១១/០៩/២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ទៅជារដ្ឋាបានព្រៃឈើ របស់រាជរដ្ឋាភិបាលកម្ពុជា។
- អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០២/១២/២០០៣ ស្តីពីការគ្រប់គ្រងសហាគមន៍ព្រៃឈើរបស់រដ្ឋាភិបាលកម្ពុជា។
- អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី០៦/១០/២០០៤ ស្តីពីតំបន់ព្រៃការពារសម្រាប់
- អភិរក្សជីវៈចម្រុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្តារលទ្ធភាពដែលទ្រទ្រង់

---

[7] រដ្ឋបាលព្រៃឈើ, សេចក្តីណែនាំការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ២០០៥, ទំព័រ ៤៦

[8] ឯម សុខុម ២០០៦

លក្ខណៈជីវសាស្ត្រសត្វព្រៃខេត្តកោះកុង របស់រាជរដ្ឋាភិបាលកម្ពុជា។

- អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១/១៤/២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃអចិន្ត្រៃយ៍ របស់រាជរដ្ឋាភិបាលកម្ពុជា។
- អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧/១០/២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋរបស់រាជរដ្ឋាភិបាលកម្ពុជា។
- អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី ០៧/០៣/២០០៦ ស្តីពីការតែងតាំងសមាសភាពរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី របស់រាជរដ្ឋាភិបាលកម្ពុជា។
- អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩/០៥/២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខាជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ របស់រាជរដ្ឋាភិបាលកម្ពុជា។
- អនុក្រឹត្យលេខ៦៥អនក្រ.បកចុះថ្ងៃទី ១៥/០៧/២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី របស់រាជរដ្ឋាភិបាលកម្ពុជា។

គ. ប្រកាស (Declaration)

- ការប្រកាសលេខ ៦០៩ សហវ.ប្រក/៤៧២ ប្រក.កសក ចុះថ្ងៃទី ២៨/០៨/២០០៣ ស្តីពីការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើ របស់ក្រសួងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ៥០៩ ប្រក.កសក ចុះថ្ងៃទី ១៧/០៩/២០០៣ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់រដ្ឋបាល ព្រៃឈើ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ០៨៩ ប្រក.កសក.ប ចុះថ្ងៃទី ០២/០៣/២០០៤ ស្តីពីការតែងតាំងមន្ត្រីរាជការរបស់ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ២៧ ប្រក.បកយ ចុះថ្ងៃទី១១/០៦/២០០៤ ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌។
- ប្រកាសលេខ ៣៣៣ ប្រក.បកយ ចុះថ្ងៃទី ១៨/១០/២០០៤ ស្តីពីការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើ គ្រញូង និង ធ្នង់នៅខេត្តសៀមរាប របស់ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ៣៦៧ ប្រក.កសក ចុះថ្ងៃទី០៣/១២/២០០៤ ស្តីពីការដាក់អោយប្រើប្រាស់គំរូលិខិតអនុញ្ញាត ក្នុងសកម្មភាពព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

- ប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី១៤/០២/២០០៥ ស្តីពីផល-អនុផលព្រៃឈើ ដែលត្រូវហាមឃាត់ការប្រមូលផល របស់ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ០៩០ ប្រក.កសក ចុះថ្ងៃទី ១៤/០២/២០០៥ ស្តីពីគំរូសំណាបិទភ្ជិតលើខុន ថែនណីផ្ទុកផល និងអនុផលព្រៃនាំចេញ របស់ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ០៩១ ប្រក.កសក ចុះថ្ងៃទី ១៤/០២/២០០៥ ស្តីពីបែបបទ និងសិទ្ធិ សម្រេចពិន័យអន្តរការណ៍ របស់ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ០៩២ ប្រក.កសក ចុះថ្ងៃទី ១៤/០២/២០០៥ ស្តីពីអនុផលព្រៃឈើ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ១៣២ ប្រក.កសក ចុះថ្ងៃទី ១៤/០៣/២០០៥ ស្តីពីអនុផលព្រៃឈើ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៨/០៧/២០០៧ ស្តីពីនីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផលអនុផលព្រៃឈើប្រចាំឆ្នាំនៅក្នុងដែនព្រៃផ្តល់ផលក្រៅព្រៃសម្បទាន របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ៤១២ ប្រក.កសក ចុះថ្ងៃទី ២២/០៨/២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងមន្ទីពិសោធន៍ចម្រុះវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើ និងសត្វព្រៃ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ០៩៧ ប្រក.កសក.កយ/០៦/០៣/២០០៦ ស្តីពីទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ របស់ក្រសួងយុត្តិធម៌ និង ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១/០៧/២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។
- ប្រកាសលេខ ១៣៧ ប្រក.កសក ចុះថ្ងៃទី ១៣/០៤/២០០៦ ស្តីពីការលុបចោលរោងចក្រអារកែច្នៃឈើជាសាខារបស់ក្រុមហ៊ុនព្រៃសម្បទានក្នុងទូទាំងប្រទេស របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

**ឃ. សេចក្តីសម្រេច (Decision)**

- សេចក្តីសម្រេចលេខ ៣៦៥ រព.ករសចុះថ្ងៃទី ០៤/០២/២០០៤ ស្តីពីការកំណត់ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ របស់រដ្ឋបាលព្រៃឈើ។

- សេចក្តីសម្រេចលេខ ៣២ សសរ ចុះថ្ងៃទី ០២/០៦/២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់ លុបបំបាត់ និង បង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធព្រៃឈើដើម្បីរានទយកដីធ្វើជាកម្មសិទ្ធិនៅតាមបណ្តាខេត្ត-ក្រុងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជារបស់រាជរដ្ឋាភិបាលកម្ពុជា។

**ង. បទបញ្ជា** (Reulation)

- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ០៦/០៦/២០០៤ ស្តីពីការទប់ស្កាត់លុបបំបាត់ និង បង្ក្រាបការកាប់រាន ការដុត ការឈូសឆាយ និងហ៊ុមព័ទ្ធកាន់កាប់យកដីព្រៃឈើរបស់រដ្ឋាភិបាលកម្ពុជា។
- បទបញ្ជាលេខ ០៥ បប ចុះថ្ងៃទី ១៥/១១/២០០៦ ស្តីពីវិធានការការពារ និងអភិរក្សដើមត្នោត របស់រាជរដ្ឋាភិបាលកម្ពុជា។
- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ១០/០៥/២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃគ្រប់ប្រភេទ របស់រដ្ឋយកធ្វើជាកម្មសិទ្ធិ របស់រាជរដ្ឋាភិបាលកម្ពុជា។
- បទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ២០/០៩/២០០៦ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យលើការប្រើប្រាស់រណារយន្តកាត់-អារឈើ របស់រដ្ឋាភិបាលកម្ពុជា។

**ច. សារាចរណែនាំ** (Circular)

- សារាចរណែនាំលេខ ៤៨១ សរណន.កសក ចុះថ្ងៃទី ០៥/០៩/២០០៣ ស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និង ធ្វើអាជីវកម្មដើមត្នោត របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

**ឆ. សេចក្តីជូនដំណឹង** (Announcement)

- សេចក្តីជូនដំណឹងលេខ១៤៥០ រព.ករស ចុះថ្ងៃទី ១៤/០៦/២០០៤ ស្តីពីលទ្ធផលនៃកិច្ចប្រជុំការងារអនុវត្តភារកិច្ចរបស់អង្គភាពរដ្ឋាភិបាលព្រៃឈើមូលដ្ឋាន ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤ របស់រដ្ឋបាលព្រៃឈើ។
- សេចក្តីជូនដំណឹងលេខ០០៦៦ សជណ.កសក ចុះថ្ងៃទី០៥/០១/២០០៥ ស្តីពីការការពារ និងការទប់ស្កាត់ភ្លើងឆេះព្រៃ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

ក្រៅពីបណ្តាច្បាប់ ក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានក្រោមច្បាប់ទាំងអស់ខាងលើនៅមានច្បាប់ ក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានក្រោមច្បាប់ជាច្រើនទៀតដែលបានអនុម័តមុនឆ្នាំ ២០០២ប៉ុន្តែនៅមានសុពលភាពមួយចំនួនដូចជាខាងក្រោម៖

- ច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី ៣១/០៨/២០០២
- អនុក្រឹត្យលេខ ០៥ អនុក្រ.បក ចុះថ្ងៃទី ០៧/០៩/២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជរដ្ឋាភិបាល។
- អនុក្រឹត្យលេខ ១៧ អនុក្រ.បក ចុះថ្ងៃទី ១០/០៩/២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ របស់រាជរដ្ឋាភិបាល។
- ប្រកាសលេខ ៣៥៧ ប្រក.កសក ចុះថ្ងៃទី ១០/១១/១៩៩៩ ស្តីពីការបង្កើតឯកសណ្ឋាន និងសញ្ញាសំគាល់របស់អង្គការរុក្ខា-ប្រមាញ់ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ។

### ១.៣.៣ ក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា

គឺជាសំណុំនៃឯកសារដែលចងក្រងនូវបណ្តាគោលការណ៍ណែនាំសម្រាប់ធានាការគ្រប់គ្រងព្រៃឈើក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយនិរន្តរភាព ដែលរួមមានគោលការណ៍ណែនាំសម្រាប់ប្រព័ន្ធនៃផែនការគ្រប់គ្រងព្រៃឈើ ការងារវិស្វកម្មព្រៃឈើ ការគ្រប់គ្រងតំបន់គ្រប់គ្រងពិសេស ការអភិរក្សជីវចំរុះ ការប៉ាន់ស្មានផល ប៉ះពាល់សង្គម និង បរិស្ថាន និងការសិក្សាអង្កេតសេដ្ឋកិច្ច សង្គមជុំវិញតំបន់ព្រៃឈើ។ល។

### ១.៣.៤ ការគាំទ្រតាមប្រព័ន្ធច្បាប់

ការដាក់អោយដំណើរការរចនាសម្ព័ន្ធខ្សែរយៈបណ្តោយរបស់រដ្ឋបាលព្រៃឈើ គឺជាការចាំបាច់សំរាប់ធានាដល់ការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដែលបានប្រកាសអោយប្រើប្រាស់ជាប្រញ្ញាប់តាមព្រះរាជក្រឹត្យលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣០ សីហា ឆ្នាំ២០០២ ហើយក៏ជាកូនសោ និងត្រីវិស័យសំរាប់បើកទ្វារ និងចង្អុលបង្ហាញទិសឈានទៅរកការគ្រប់គ្រងធនធានព្រៃឈើមួយប្រកបដោយនិរន្តរភាព។

អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល បានសម្រេចប្តូរឈ្មោះនាយកដ្ឋាន-រុក្ខាប្រមាញ់ទៅជារដ្ឋបាលព្រៃឈើ ដែលបានបញ្ជាក់ថា រដ្ឋបាលព្រៃឈើគឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និង នេសាទ ក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានព្រៃឈើស្របតាមគោលនយោបាយវិស័យព្រៃឈើជាតិ និងច្បាប់ស្តីពីព្រៃឈើ។

ក្រសួងកសិកម្មរុក្ខា-ប្រមាញ់ និង នេសាទបានចេញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើដែលបានកំណត់

អោយរដ្ឋបាលព្រៃឈើ មានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទៅប្រទេសជាខ្សែរយៈ បណ្តោយដែលបានបែងចែកជា ថ្នាក់កណ្តាល ០១កន្លែង អធិការដ្ឋាន ០៤កន្លែង ខណ្ឌរដ្ឋបាលព្រៃឈើ ១៥កន្លែង ផ្នែករដ្ឋបាលព្រៃឈើ ៥៥កន្លែង និង សង្កាត់រដ្ឋបាលព្រៃឈើ ១៧០កន្លែង នៅទូទាំងប្រទេស។

## ១.៤ គោលដៅ និង គោលបំណងនៃការគ្រប់គ្រងព្រៃឈើ

អត្តសញ្ញាណកម្មនៃគោលដៅគ្រប់គ្រង និងគោលបំណងគ្រប់គ្រងដ៏ជាក់លាក់ស្របទៅនឹងអាទិភាពនៃនយោបាយសក្តានុពលនៃធនធាន និងឧបសគ្គ គឺមូលដ្ឋាននៃគោលការណ៍គ្រប់គ្រងព្រៃឈើ ហើយសម្រេចបានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ គួរមាននៃការធ្វើផែនការព្រៃសម្បទានទាំងអស់។

+ គោលដៅគឺជាគោលបំណងរយៈពេលវែង និងអាចត្រូវបានកំណត់ចេញពីនយោបាយព្រៃ ឬត្រូវបានកំណត់ថាជាលទ្ធផលចុងក្រោយនៃយុទ្ធសាស្ត្រ ដើម្បីសម្រេចបានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ គួរមានគោលដៅតែមួយប៉ុណ្ណោះ សម្រាប់ព្រៃសម្បទានណាមួយ។
+ គោលបំណងគឺជាសកម្មភាពទាំងឡាយដែលអាចវាស់បាន ដែលបានបង្ហាញនូវលទ្ធផលជាក់លាក់ ដើម្បីឲ្យបានសម្រេចក្នុងអំឡុងពេលមួយកំណត់។គោលបំណងមួយចំនួនអាចត្រូវកំណត់ និងបញ្ជាក់ន័យច្បាស់ក្នុងផែនការមួយ។

គោលបំណងនីមួយៗគួរបញ្ជាក់ឲ្យបានច្បាស់លាស់ពីៈ

- សកម្មភាពអ្វីដែលនឹងត្រូវអនុវត្ត
- សកម្មភាពនេះ នឹងកើតឡើងនៅកន្លែងណា
- នរណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍
- នៅពេលណាដែលសកម្មភាពត្រូវបានអនុវត្ត និង ត្រូវបានបញ្ចប់
- តើទិន្នន័យលទ្ធផលដែលពាក់ព័ន្ធមានប៉ុន្មាន ឬចំនួនសេចក្តីរាយការណ៍ដែលជាក់លាក់មានប៉ុន្មាន។

+ គោលបំណងជាក់លាក់នៃផលិតកម្មឈើជាទូទៅត្រូវៈ

– ផ្តល់នូវគោលការណ៍ដ៏តឹងរឹងលើបរិមាណមាឌឈើហ៊ុបដែលអាចដកហូតបានបញ្ជាក់ពីលក្ខខណ្ឌ និងផលវិបាកក្នុងការប្រមូលផលព្រៃឈើ។[9]

[9] រដ្ឋបាលព្រៃឈើ, សេចក្តីណែនាំការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ ២០០៥

## ១.៥ រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ[10]

ការរៀបចំរចនាសម្ព័ន្ធខ្សែបណ្ដោយរបស់រដ្ឋបាលព្រៃឈើ គឺដើម្បីជំរុញល្បឿន និងលើកកំពស់ការអនុវត្តន៍ច្បាប់ស្ដីពីព្រៃឈើទូទាំងព្រះរាជាណាចក្រកម្ពុជា ឲ្យកាន់តែមានប្រសិទ្ធិភាព។ ខ្សែរយៈបណ្ដោយនេះគឺជាខ្សែរយៈចាត់តាំង និង គ្រប់គ្រងដោយផ្ទាល់ពីរដ្ឋបាលព្រៃថ្នាក់កណ្ដាល។ រាល់ផែនការដែលរដ្ឋបាលព្រៃឈើថ្នាក់មូលដ្ឋានបានរៀបចំត្រូវផ្ញើរមករដ្ឋបាលព្រៃឈើថ្នាក់កណ្ដាលតាមឋានានុក្រមនៃរដ្ឋបាលព្រៃឈើ។

### ១.៥.១ ខ័ណ្ឌរដ្ឋបាលព្រៃឈើមានតួនាទី និងភារកិច្ច

- ត្រួតពិនិត្យ និងដឹកនាំសម្របសម្រួលផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- អនុវត្តតាមគោលនយោបាយ និងផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ
- ដឹកនាំការសិក្សារៀបចំផែនការគ្រប់គ្រងវិស័យព្រៃឈើក្នុងដែនសមត្ថកិច្ចនិងរៀបចំផែនការ
- សកម្មភាពការងារសម្រាប់ដាក់ឲ្យបណ្ដាផ្នែកក្រោមឱវាទអនុវត្តន៍ ហើយផែនការនេះត្រូវសុំសេចក្ដីសម្រេចប្រធានរដ្ឋបាលព្រៃឈើ
- សិក្សារៀបចំព្រៃបម្រុងទុកអចិន្ត្រៃយ៍ដើម្បីបង្កើតជាព្រៃសហគមន៍ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និង ទំហំសមស្របផ្អែកតាមលទ្ធភាពធនធានព្រៃឈើ និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍
- ផ្ដល់លិខិតកំណត់តួតាអនុញ្ញាតឲ្យប្រមូលផល អនុផលសម្រាប់សហគមន៍មូលដ្ឋាន
- ផ្ដល់លិខិតអនុញ្ញាតឲ្យបង្កើតរោងសន្និធិលក់ ចែកចាយ អនុផលព្រៃឈើ និងសិប្បកម្មកែច្នៃផល អនុផល អនុផលព្រៃឈើប្រភេទតូច
- ផ្ដល់លិខិតអនុញ្ញាតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីសហគមន៍
- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ ជាមួយសហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍
- ធ្វើរបាយការណ៍ជាប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែដើមឆ្នាំ និង ប្រចាំឆ្នាំ អំពីសកម្មភាពការងារវិស័យព្រៃឈើក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនរដ្ឋបាលព្រៃឈើ
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើប្រគល់ឲ្យ។

[10] រដ្ឋបាលព្រៃឈើ, សេចក្ដីណែនាំការអនុវត្តន៍ច្បាប់ស្ដីពីព្រៃឈើ ២០០៥, ទំព័រ២០, ២១

**១.៥.២ ផ្នែករដ្ឋបាលព្រៃឈើមានតួនាទី និង ភារកិច្ច**

- អនុវត្តវាយតម្លៃសារពើភ័ណ្ឌធនធានព្រៃឈើ សត្វព្រៃ និង ធ្វើការកំណត់ព្រំប្រទល់ដែនព្រៃ
- សិក្សាស្រាវជ្រាវ អនុវត្តការគ្រប់គ្រង ការពារ អភិរក្ស សត្វព្រៃ និង ដែនជម្រក
- សិក្សារៀបចំ និង អនុវត្តផែនការគ្រប់គ្រងវិស័យព្រៃឈើ ក្នុងដែនសមត្ថកិច្ច
- រៀបចំ និង ដាក់ស្នើផែនការគ្រប់គ្រងផ្តល់ផលក្រៅពីព្រៃសម្បទាន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនប្រធានរដ្ឋបាលព្រៃឈើដើម្បីពិនិត្យ និង សម្រេច
- អនុវត្តការងារដាំឈើ និងស្តារព្រៃឈើឡើងវិញ
- ផ្សព្វផ្សាយ ការពារ និង ប្រឆាំងភ្លើងឆេះព្រៃ
- សម្របសម្រួល ពិនិត្យ និង ផ្តល់ជំនួយបច្ចេកទេសព្រៃឈើដល់សហគមន៍ព្រៃឈើ
- ត្រួតពិនិត្យការប្រមូលផល អនុផលព្រៃឈើ និង វាស់វែង វាយតម្លៃគុណភាព និង បរិមាណផល អនុផលព្រៃឈើ ដើម្បីចុះកំណត់ហេតុបញ្ជីសៀវភៅ
- ធ្វើការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ
- រៀបចំចងក្រង និង បញ្ជូលសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃទៅតុលាការ
- ចេញលិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើលើសពីសិទ្ធិប្រើប្រាស់ជាប្រពៃណីសម្រាប់សហគមន៍មូលដ្ឋានក្នុងព្រៃសហគមន៍
- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើចេញពីតំបន់ដែនសមត្ថកិច្ចសាមី
- ធ្វើរបាយការណ៍ជាប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែដើមឆ្នាំ និង ប្រចាំឆ្នាំអំពីសកម្មភាពការងារ វិស័យព្រៃឈើក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូននាយខ័ណ្ឌរដ្ឋបាលព្រៃឈើ
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើប្រគល់ឲ្យ។

**១.៥.៣ សង្កាត់រដ្ឋបាលព្រៃឈើមានតួនាទី និង ភារកិច្ច**

- ល្បាតជាអចិន្ត្រៃយ៍ដើម្បីត្រួតពិនិត្យ ការពារធនធានព្រៃឈើ និង សត្វព្រៃព្រមទាំងប្រយុទ្ធប្រឆាំងនឹងភ្លើងឆេះព្រៃ
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងគោលបំណងថែរក្សា ការពារធនធានព្រៃឈើ និង សត្វព្រៃ
- រៀបចំថ្នាលបណ្តុះកូនឈើ រួមទាំងអនុវត្តការងារដាំដើមឈើ និងស្តារព្រៃឈើឡើងវិញ
- សម្របសម្រួល និង ផ្តល់ជំនួយបច្ចេកទេសផ្ទាល់ដល់សហគមន៍ព្រៃឈើ
- អនុវត្តន៍ផ្ទាល់លើការងារធ្វើសារពើភ័ណ្ឌ និង រៀបចំព្រៃឈើ និង សត្វព្រៃ

- អនុវត្តផ្ទាល់លើការងារវាស់វែង វាយតម្លៃ និង កំណត់បរិមាណផល អនុផលព្រៃឈើ
- តាមដាន រាយការណ៍ ចងក្រងសំណុំរឿង ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ និង សត្វព្រៃ
- ទទួលភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើប្រគល់ជូន។

## ១.៦ សារៈប្រយោជន៍របស់ព្រៃឈើ

ជាការចាំបាច់បំផុតសម្រាប់អ្នកដែលសិក្សា ពីការដាំដើមឈើឡើងវិញត្រូវតែយល់ពីសារៈប្រយោជន៍របស់ព្រៃឈើវាមានសារៈសំខាន់ណាស់សម្រាប់មនុស្សជាតិដូចជាការទប់ទល់ នឹងខ្យល់ព្យុះ កាត់បន្ថយការហូរច្រោះដី ការពារទប់ទល់នឹងគ្រោះទឹកជំនន់ ជួយបន្ថយនូវកំដៅថ្ងៃ និងសីតុ-ណ្ហាភាពបរិយាកាស មានតួនាទីកាត់បន្ថយជាតិពុលក្នុងបរិយាកាស និងទប់ទល់គ្រោះរាំងស្ងួត ផ្តល់ជាអនុផលព្រៃឈើ។

### ១.៦.១ ព្រៃឈើជារនាំងការពារព្យុះ

នៅពេលជ្រើសរើសប្រភេទឈើត្រូវយកចិត្តទុកដាក់ផងដែរលើទម្រង់លូតលាស់តម្រូវការទំហំនិងអត្រាលូតលាស់ដើម្បីបង្កើតប្រសិទ្ធិភាពនៃរបាំងការពារខ្យល់។ ចម្ងាយរវាងរបាំងខ្យល់ត្រូវបានកំណត់យ៉ាងច្បាស់លាស់ដោយយកកម្ពស់នៃដើមឈើដែលខ្ពស់ជាងគេបង្អស់នៃជួរធ្វើជាគោល។ ទម្រង់ដែលសមស្របរបស់វាមានរាងដូចម្រាមដៃហើយអាចការពារទីវាលយ៉ាងហោចណាស់ប្រវែង ១០ដង ស្មើនឹងកម្ពស់ដើមឈើដែលខ្ពស់ជាងគេ។ ឥទ្ធិពលនៃការការពារ និងថយចុះអាស្រ័យលើចំងាយពីរបាំង។ របាំងខ្យល់ដែលរីកចម្រើនគ្រប់គ្រាន់អាចឲ្យផលជា ឈើ ផ្លែចំណីសត្វ សរសៃ និងឃ្មុំសម្រាប់លក់ដូរនិងប្រើប្រាស់ក្នុងផ្ទះ។

ការសាកល្បងពិសោធន៍របាំងការពារខ្យល់ក្នុងលក្ខខណ្ឌនៅ Sahelianនៃ Majjla Velley, Niger ទិន្នផលមធ្យមនៃអុសដែលអាចយកមកប្រើបានពីដើមស្តៅមានចំនួន ៥គីឡូក្រាមក្នុងមួយឆ្នាំ។ ផ្អែកលើការគិតគូរនេះ ដើមឈើពីជួរមួយកន្លែងប្រវែងបណ្តោយ១០០ម៉ែត្រ ហើយដើមនីមួយៗ ចម្ងាយឃ្លាត ពីគ្នា៤ម៉ែត្រអាចផ្តល់អុសទម្ងន់២៥០គីឡូក្រាម(៥គីឡូក្រាម×២ដើម×២ជួរ) ឬផ្គត់ផ្គង់គ្រប់គ្រាន់សម្រាប់តម្រូវការនៃគ្រួសារមួយដែលមានសមាជិក៥នាក់ក្នុងរយៈពេល២ខែ។[11]

[11] លោក ឡាំ រ៉ែ, ១៩៩៨

### ១.៦.២ ព្រៃឈើជួយការពារទប់ទល់ការហូរច្រោះដី

ព្រៃឈើនៅតំបន់ដីគោកទោះជាវាមិនបានរួមបញ្ចូលក្នុងព្រៃលិចទឹកក្តីក៏ព្រៃឈើដីគោកបានចូលរួមចំណែកយ៉ាងសំខាន់ជួយដល់គុណភាពដី។ ព្រៃឈើដីគោកបានរក្សាលំនឹងដល់ការហួតហែងនៃទន្លេបឹង ស្ទឹង អូរ និងជួយដល់ការស្រោចស្រពហើយរួមទាំងរក្សាដង្ហើមទឹកក្នុងដីដោយសារមានស្រទាប់ព្រៃកម្រាលពុកផុយមីក្រូសារពាង្គកាយសត្វក្នុងដីវាធ្វើឲ្យមានចរន្តទឹកហូរទៅលើដីពេលមានភ្លៀងធ្លាក់ត្រូវចុះខ្សោយយ៉ាងខ្លាំង។ គម្របព្រៃឈើបានជួយស្ទាក់ស្កាត់ទឹកភ្លៀងមួយចំនួនសម្រាប់ការភាយហួតក៏វាជួយកុំឲ្យមានការហួតខ្លាំងលើផ្ទៃដីលើសពីនេះទៅទៀតព្រៃឈើវាជួយកាត់បន្ថយល្បឿនដំណក់ទឹកដែលស្រក់លើដីកុំឲ្យខូចដី និងការហូរច្រោះខ្លាំងលើផ្ទៃដី។ ដោយដីព្រៃមានមមោកច្រើន និងកម្រាលងាប់ពុកផុយដោយសារសកម្មភាពអតិសុខុមសត្វធ្វើឲ្យទឹកជ្រៀតចូលទៅក្នុងដីជាច្រើន។[12]

### ១.៦.៣ ព្រៃឈើជួយបន្ថយពន្លឺថ្ងៃនិងសីតុណ្ហភាពបរិយាកាស

នៅពេលពន្លឺថ្ងៃជះទៅលើព្រៃឈើ ១០០ភាគរយនោះ២៥ភាគរយ នៃពន្លឺថ្ងៃត្រូវចំណាំងផ្លាតទៅវិញតាមរយៈស្លឹក ៣៥ភាគរយ ដល់៧០ភាគរយ នៃពន្លឺថ្ងៃត្រូវគម្របព្រៃឈើទទួលយកហើយ៥ភាគរយ ដល់ ៤០ភាគរយនៃពន្លឺថ្ងៃបានជះដល់ព្រៃឈើ។ ពន្លឺថ្ងៃដែលគម្របព្រៃទទួលបាននេះគឺសម្រាប់ការលូតលាស់ ព្រោះថានៅក្នុងពន្លឺថ្ងៃមានរស្មីពណ៌ក្រហមអ៊ុលត្រាក្រហមលឿងទុំខៀវខ្ចីស្វាយហើយរុក្ខជាតិស្រូបយករស្មីពណ៌ស្វាយ និងអ៊ុលត្រាស្វាយមានឥទ្ធិពលគីមីជីវសាស្ត្រលើដើមឈើ។ នៅក្នុងព្រៃដោយសារមានគម្របព្រៃលឿងខ្សោយនិងមានសំណើមជាហេតុធ្វើឲ្យសីតុណ្ហភាពក្នុងព្រៃខុសប្លែកសីតុណ្ហភាពពីខាងក្រៅ ជាពិសេសជាងនេះទៅទៀត ព្រៃឈើជួយឲ្យមានខ្យល់អាកាសបរិសុទ្ធ។[13]

### ១.៦.៤ ព្រៃឈើបានផ្តល់ផល និងអនុផល

បន្ទាប់ពីការធ្វើអាជីវកម្មទៅលើព្រៃឈើយើង និងទទួលបានមកវិញនូវផលជាច្រើនប្រភេទដូចជា ឈើសម្រាប់ធ្វើជាឧស្សាហកម្មដែលរួមមាន ឈើហ៊ុប ឈើអារ ឈើក្តារបន្ទះ ឈើសំណង់គ្រឿងសង្ហារឹមជាដើម។ សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារវិញគឺ ឈើធ្វើអុស ធ្យូង បង្គោលរបងក្រៅពីផលព្រៃឈើនៅមានអនុផលព្រៃឈើជាច្រើនប្រភេទ និងច្រើនមុខដែលមានដូចជា សត្វព្រៃ

[12] លោក វន មុនិន្ទ, ១៩៩៨

[13] សៀវភៅ តួនាទីព្រៃឈើ, ២០០១

ផ្តៅ ឬស្សី រំពាក់ ផ្សិត វល្លិ៍ ផ្លែឈើ ជ័រទឹក ជ័រចុងស្បូវព្រិច ឬសឈើ សំបកឈើស្លឹកឈើនិងមានប្រភេទផ្សេងៗទៀតជាច្រើន។[14]

### ១.៦.៥ ព្រៃឈើជួយការពារទប់ទល់ទឹកជំនន់

ព្រៃឈើមានលក្ខណៈធម្មជាតិអនុគ្រោះដល់ការរស់នៅរបស់មនុស្ស សត្វទាំងពួង។ មានព្រៃឈើជាច្រើនវាអាចជួយទប់ដំណក់ទឹកភ្លៀងកុំឲ្យធ្លាក់ពេញទំហឹងទៅលើដី ដោយសារមានកន្សោមស្លឹកជួយការពារដល់រុក្ខជាតិស្រទាប់ក្រោមនិងកម្រាស់ស្លឹកឈើកំទេចកំទីដែលគ្របដណ្តប់ដីហាក់ដូចជាក្រដាសផ្ចិតជាប់ទឹក។ ព្រៃឈើបានបង្កលក្ខណៈងាយស្រួលឲ្យទឹកជ្រាបចូលទៅក្នុងដីសន្សើមៗ ដោយសារប្រព័ន្ធឫស ឬស្លឹកឈើសម្រាប់ការស្រូបយកទឹកយ៉ាងសំខាន់។ ព្រៃឈើវាអាចជួយបន្ថយល្បឿនចរន្តទឹកហូរលើផ្ទៃដីកុំឲ្យ ទឹកជំនន់មានភាពខ្លាំងក្លាហួសហេតុពេលដែលវាអាចធ្វើឲ្យមានគ្រោះថ្នាក់ជាច្រើនដល់របរកសិកម្មដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិជាដើម។

### ១.៦.៦ ព្រៃឈើមានតួនាទីកាត់បន្ថយជាតិពុលនៅក្នុងបរិយាកាស

នៅក្នុងបរិយាកាសយើងនេះមានបរិមាណឧស្ម័នកាបូនិច ០.០៣ភាគរយ តែបើនៅក្នុងទីក្រុងឧស្សាហកម្មកម្រិតឧស្ម័នកាបូនិចមានពី ០.០៥ភាគរយទៅ០.០៧ភាគរយ វាជាមូលហេតុបណ្តាលឲ្យមានផលប៉ះពាល់ដល់មនុស្សនិងសត្វ។ ព្រៃឈើនឹងមនុស្សវាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធិព្រោះមនុស្សត្រូវការឧស្ម័នអុកស៊ីសែនដើម្បីដកដង្ហើមហើយបញ្ចេញមកវិញនូវឧស្ម័នកាបូនិចចំណែកឯព្រៃឈើវិញវាបានស្រូបយកឧស្ម័នកាបូនិច និងបញ្ចេញឧស្ម័នអុកស៊ីសែនតាមរយៈការធ្វើរស្មីសំយោគរុក្ខជាតិបៃតង។

តាមរយៈការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថាមនុស្សត្រូវការអុកស៊ីសែន ហើយព្រៃឈើត្រូវបានគេកាប់បំផ្លាញអស់នោះគ្មានអ្វីបញ្ចេញអុកស៊ីសែនទៀតពេលនេះហើយផែនដីក្នុងរយៈពេលណាមួយនោះនឹងត្រូវអស់អុកស៊ីសែន។ លើសពីនេះទៅទៀត ព្រៃឈើជារបាំងធម្មជាតិការពារមិនឲ្យខ្យល់បក់បោកខ្លាំងគួចយកធូលីទៅបង្ហើរពេញទាំងផ្ទៃអាកាស ហើយព្រៃឈើវាក៏ជាវត្ថុមួយសម្រាប់ត្រង់ធូលីទៅបង្ហើរពេញទាំងផ្ទៃអាកាស ហើយព្រៃឈើវាក៏ជាវត្ថុមួយសម្រាប់ត្រង់ធូលីទៅលើបង្ហើរពេញទាំងផ្ទៃអាកាស ហើយព្រៃឈើវាក៏ជាវត្ថុធាតុមួយសម្រាប់ត្រង់ធូលីធ្វើឲ្យខ្យល់មានភាពបរិសុទ្ធ ដូច្នេះមនុស្សយើងពុំអាចខ្វះអុកស៊ីសែនបានឡើយក៏ដូចជាការមិនអាចព្រៃឈើអញ្ចឹងដែរ។[15]

[14] កម្មវិធីព្រៃឈើជាតិ, ២០១០ដល់២០២៩

[15] ការអប់រំបំណិនជីវិតស្តីពីបរិស្ថាន, ២០១៣

### ១.៦.៧ ព្រៃឈើផ្តល់ផលប្រយោជន៍ចំពោះសេដ្ឋកិច្ចសង្គម

មនុស្សយើងអាចរស់នៅបានក៏ដោយសារមានការទាក់ទងនិងព្រៃឈើប៉ុន្តែមនុស្សភាគច្រើននៅឆ្ងាយពីព្រៃមិនបានយល់ថាជីវភាពរបស់គាត់មានការទាក់ទងនឹងព្រៃឈើនោះជានិច្ចសោះ។ ហេតុដូចនេះហើយយើងគប្បីយល់ថាៈ

- ព្រៃឈើអាចនឹងកែលំអគុណភាពដីឲ្យបានល្អ
- ឈើអាចនឹងកែសម្រួលប្រភពទឹក
- ព្រៃឈើធ្វើឲ្យអាកាសធាតុល្អបរិសុទ្ធ

ព្រៃឈើជាសម្បត្តិមួយចាំបាច់សម្រាប់ទ្រទ្រង់ជីវភាពទូទៅ ហើយអំណោយផលដ៏ថ្លៃថ្លាដល់បរិយាកាស បើយើងចេះថែរក្សាទាំងព្រៃឈើនោះឲ្យបានល្អយើងនឹងអាចដកហូតបានលើសចំនួន ដែលយើងត្រូវការប្រើប្រាស់ក្នុងប្រទេស ហើយអាចនាំចេញទៅក្រៅប្រទេសទទួលបានចំណូលរូបិយប័ណ្ណមកប្រទេសយើងវិញទៀតផង។ ព្រៃឈើ ជាទីមនោរម្យនិងជាប្រភពនៃសេចក្តីសប្បាយមិនចេះរីងស្ងួត ហើយព្រៃឈើបានផ្តល់នូវសារៈប្រយោជន៍ច្រើនយ៉ាងចំពោះសង្គម និង សេដ្ឋកិច្ច។[16]

### ១.៦.៨ ព្រៃឈើមានសារៈប្រយោជន៍ចំពោះវប្បធម៌

វប្បធម៌និយាយរួមគឺជាបែបបទនៃជីវិតរស់នៅរបស់ក្រុមមនុស្សណាមួយខុសគ្នាពីតំបន់មួយទៅតំបន់មួយទៀត ពីប្រទេសមួយទៅប្រទេសមួយទៀត។ ហើយបែបបទនៃជីវិតបានផ្សារភ្ជាប់មិនអាចកាត់ផ្តាច់ពីគ្នាបានទៅនឹងធម្មជាតិជាពិសេសព្រៃឈើ។ សកម្មភាពការងារមួយចំនួនជាការបំផ្លិចបំផ្លាញ ដូចជាការកាប់ឆ្ការព្រៃឈើខ្ពស់ៗដែលធ្វើឲ្យបាត់បង់ពូជឈើនិងសត្វព្រៃមួយចំនួន។ តែទោះជាយ៉ាងណាអ្នកឯកទេសនៅមានជំនឿថារហូតមកដល់ពេលនេះប្រជាជនរស់នៅក្បែរៗព្រៃមានតុល្យភាពទៅនឹងព្រៃឈើរវាងគ្នាទៅវិញទៅមក អស់ជាច្រើនទសវត្សរ៍មកហើយ។ ជនជាតិនៅឥសានមានការស្តាយកាផាហើយតែងតែដាក់ជាប់ជានិច្ចនៅឃ្លោកទឹក។ ឃ្លោកទឹកជានិមិត្តរូបសម្រាប់ព្រះព្រហ្មដង្ហើមជីវិត។ ចំណែកឯកាផាវិញជា និមិត្តរូបតំណាងប្រភពថាមពលមិនចេះរីងស្ងួត។ ឧទាហរណ៍ទាំងពីរនេះមិនអាចកាច់ផ្តាច់ចែកបានឡើយ។ នៅក្នុងប្រពៃណីបែបព្រហ្មសាសនានៅក្នុងតំបន់ខ្លះគេមានជំនឿដោយថែរក្សាព្រៃឈើ ពីព្រោះគេយល់ថាព្រៃឈើមានរុក្ខទេវតាអារក្សព្រៃឈើជាអ្នកថែរក្សាការពារ។ ជំនឿទាំងអស់នេះមានអត្ថប្រយោជន៍ធំធេង

[16] យើងត្រូវដាំដើមឈើ, ទស្សនាវដ្តី ១៩៩៩

សម្រាប់ជួយដល់ការថែរក្សាព្រៃឈើឲ្យបានគង់វង្សដើម្បីគោរពបូជា។[17]

## ១.៧ ការចាត់ថ្នាក់គម្របព្រៃឈើ[18]

### ១.៧.១ ព្រៃស្រោង(ព្រៃបៃតងជានិច្ច)

ព្រៃបៃតងជានិច្ចជាព្រៃមានស្រទាប់ដែលមានស្លឹករបស់វាពោពេញមួយឆ្នាំ។ ព្រៃប្រភេទនេះរួមបញ្ចូលទាំងព្រៃតំបន់ទំនាបត្រូពិច ព្រៃបៃតងតំបន់ភ្នំ ព្រៃបៃតងស្ងួត និងព្រៃនៅតាមមាត់ស្ទឹង ទន្លេ ។

### ១.៧.២ ព្រៃពាក់កណ្ដាលស្រោង

ព្រៃពាក់កណ្ដាលស្រោងជាការបញ្ចូលគ្នានៃប្រភេទព្រៃស្រោង និងប្រភេទព្រៃល្បោះ ហើយភាគរយ នៃព្រៃស្រោងប្រែប្រួលពី ៣០ភាគរយ ទៅ៧០ភាគរយ។ព្រៃពាក់កណ្ដាលស្រោងបន្ត មានពណ៌បៃតងពេញមួយឆ្នាំទោះបីជាអត្រាភាគនៃព្រៃល្បោះខ្ពស់ក៏ដោយ។

### ១.៧.៣ ព្រៃល្បោះ

ព្រៃល្បោះជាការរួមបញ្ចូលចម្រុះស្ងួត (Dry mixed deciduous forest) និងប្រភេទព្រៃ Dipterocarp ស្ងួត។ ព្រៃល្បោះជ្រុះស្លឹកស្ទើរតែទាំងស្រុងនៅរដូវប្រាំង។ ឥទ្ធិពលរបស់មនុស្សដូចជាភ្លើងឆេះព្រៃមានកំរិតខ្ពស់ជាងបើប្រៀបធៀបនឹងប្រភេទព្រៃផ្សេងទៀត។ លក្ខណៈធម្មជាតិព្រៃ Dipterocarp ស្ងួតមានភាពហាល ឬចំហរ។ ប្រសិនពុំមានការរំខានទេ ព្រៃល្បោះអាចមានគម្របកន្ទ្រាមស្លឹកត្រឹមត្រូវតែ ៥០ភាគរយ។ ដី និងវាលស្មៅអាចមានឥទ្ធិពលសំខាន់លើការសម្គាល់ព្រៃប្រភេទនេះហើយមានការលំបាកក្នុងការញែកប្រភេទព្រៃល្បោះចេញពីព្រៃគុម្ពោតក្នុងកំឡុងរដូវប្រាំង។

### ១.៧.៤ ព្រៃប្រភេទផ្សេងៗ

គម្របដីប្រភេទនេះរួមបញ្ចូលទាំងដំណុះព្រៃឡើងវិញ ព្រៃគៀ ព្រៃកោងកាង ព្រៃលិចទឹក ព្រៃដាំ ព្រៃឬស្សី កៅស៊ូ និងដូងប្រេង។ ដំណុះព្រៃឡើងវិញនៃព្រៃបន្ទាប គឺជាតំណាងនៃស្រទាប់កូនឈើតូចៗដែលជាទូទៅក្រាស់ៗ។ ព្រៃគៀដុះយឺតណាស់ ដោយសារតែលក្ខខណ្ឌទឹកន្លែងអន់ដីគ្មានជីវជាតិ និងមានថ្មផុសពីដី។ ព្រៃមានការរំខានខ្លាំងដូចជា ព្រៃដុះដោយដុំៗដំណុះព្រៃឡើងវិញតំបន់នៃដំណុះព្រៃឡើងវិញចាស់ៗដំណុះកូនឈើឡើងវិញនៃព្រៃបន្ទាបក្រោយពីការកាប់រាន និងដំណាំនៃកសិកម្មពនេចរដែលក្នុងនោះភាគរយនៃដីព្រៃឈើនៅសល់ច្រើនជាង ៥០ភាគរយ ក៏ស្ថិតនៅក្នុងចំណាត់ថ្នាក់នេះដែរ។ ព្រៃឬស្សី តំបន់ធំៗសម្បូរដោយដើមឬស្សីក្រាស់ៗជាទូទៅងាយមើល

[17] កម្មវិធីព្រៃឈើជាតិ ២០១០ដល់២០២៩

[18] ធនធានគម្របព្រៃឈើកម្ពុជា, ២០១០, ទំព័រ ៥៨

ឃើញដោយសារតែមានពណ៌ផ្កាឈូកនិងពណ៌ទឹកក្រូច និងវាយនភាពទូទៅនៅលើរូបភាពផ្កាយរណប។ ព្រៃឬស្សីស្តើងៗឬដើមឬស្សីតូចពិបាកនឹងញែកចេញពីចំណាត់ថ្នាក់ប្រភេទព្រៃផ្សេងទៀត។

**១.៧.៥ ដីមិនមានគម្របព្រៃឈើ**

ចំណាត់ថ្នាក់ប្រភេទនេះបញ្ចូលគ្នារវាងដីកសិកម្ម តំបន់ប្រជុំជន ផ្ទៃទឹក វាលស្មៅ ថ្ម ព្រៃគុម្ពោតបៃតងជានិច្ច និងព្រៃគុម្ពោតស្ងួត។ ព្រៃគុម្ពោតបៃតងជានិច្ចជាការដុះលាយនៃពពួកចុល្ល-ព្រឹកក្រាស់ វាលស្មៅនឹងដើមឈើដែលកម្របនៀវាមស្លឹកក្រោម ២០ភាគរយ។ ព្រៃប្រភេទនេះឃើញមានភាគច្រើននៅតំបន់ដីរាក់ៗស្ថិតនៅលើកំពូលភ្នំក្រោមលក្ខខណ្ឌអាកាសធាតុ ឬជាលទ្ធផលនៃកាប្រើប្រាស់ដីមិនមាននិរន្តរភាព។ ជាទ្រឹស្តីព្រៃប្រភេទនេះអាចក្លាយទៅជាព្រៃធំៗឡើងវិញបាន។

## សន្និដ្ឋានជំពូក

យោងតាមការលើកឡើងនូវទ្រឹស្តីដែលមាន និយមន័យ ទស្សនទាន និងទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួនដែលទាក់ទងទៅនឹងព្រៃឈើ និងការគ្រប់គ្រងព្រៃឈើ ដែលជាកត្តាដល់សំខាន់ក្នុងការរីកចម្រើនលើការអភិរក្ស និងធ្វើការគ្រប់គ្រងធនធានព្រៃឈើ។ លើសពីនេះទៅទៀតនោះក្នុងជំពូកទី១នេះផងដែរ យើងបានបង្ហាញអំពី ក្របខណ្ឌព្រៃឈើ ការធ្វើផែនការគ្រប់គ្រង អំពីគោលដៅ និងគោលបំណងនៃការការពារព្រៃឈើ បូករួមជាមួយរចនាសម្ព័ន្ធរបស់រដ្ឋបាលព្រៃឈើដែលមានដូចជា ខណ្ឌរដ្ឋបាលព្រៃឈើ ផ្នែករដ្ឋបាលព្រៃឈើ និងសង្កាត់រដ្ឋបាលព្រៃឈើផងដែរ។ ក្រៅពីនេះយើងបានភ្ជាប់នូវចំណុចទាក់ទងជាមួយនឹង ផលប្រយោជន៍របស់ព្រៃឈើ និងការចាត់គម្របព្រៃឈើបន្ថែមទៀត។

# ជំពូកទី២ ៖

# ស្ថានភាពទូទៅនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្លាត្រៅ

# ជំពូកទី២

# ស្ថានភាពទូទៅនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្លារក្រៅស្ថិតក្នុងឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប

## ២.១ លក្ខណៈទូទៅនៃស្ថានភាពភូមិសាស្ត្រ

### ២.១.១ ទីតាំងភូមិសាស្ត្រ និងប្រវត្តិចម្ការពូជឈើគ្រញូង

ស្រុកបន្ទាយស្រីជា ស្រុកមួយក្នុងចំណោមស្រុកទាំង១១ របស់ខេត្តសៀមរាប ដែលចំងាយប្រហែលជា៣២គីឡូម៉ែត្រពីទីរួមខេត្ត។ ស្រុកបន្ទាយស្រីមានផ្ទៃដីចំនួន ៦០.០៧២ ហិកតា ក្នុងនោះមានដីព្រៃចំនួន ២.២៦៩ ហិកតា និងមានឃុំចំនួន ៦ ដែលក្នុងនោះរួមមានដូចជា៖ ឃុំឃុនរាម ឃុំរុនតាឯក ឃុំខ្នាសណ្តាយ ឃុំព្រះដាក់ ឃុំត្បែង និងឃុំចេក។ ស្រុកបន្ទាយស្រីមានព្រំប្រទល់៖

- ខាងកើតជាប់និង ស្រុកស្វាយលើ
- ខាងលិចជាប់និង ស្រុកអង្គរធំ
- ខាងត្បូងជាប់និង ស្រុកបាគង
- ខាងជើងជាប់និង ស្រុកវ៉ារិន។

រូបភាព ២.១ ៖ ផែនទីខេត្តសៀមរាប




ប្រភព៖ https://www.google.com.kh/search?q=Siem+Reap+Province

ចំពោះប្រវត្តិរបស់ចម្ការពូជឈើគ្រញូង នៅដើមឆ្នាំ ២០០១ ក្រុមការងារអង្គការ DANIDA និងការិយាល័យរុក្ខាប្រមាញ់ នៃនាយកដ្ឋានរុក្ខាប្រមាញ់ខេត្តសៀមរាបបាន ចុះស្រាវជ្រាវរកកន្លែងដែល មានដំណុះឈើគ្រញូងដុះដោយធម្មជាតិ។ ពេលនោះការិយាល័យរុក្ខាប្រមាញ់ខេត្តសៀមរាប បានចុះធ្វើការលាបថ្នាំ ធ្វើផែនទីវាយស្លាក ដែលធ្វើអំពីស័ង្កសី ប្រាប់ថាជាតំបន់ព្រៃពូជឈើគ្រញូង។ ក្នុងអំឡុងពេលនោះ ក្រុមការងារការិយាល័យខេត្ត ដែលបានសហការជាមួយ អង្គការ DANIDA បានបង្កើតបានផែនទី ដែលមានផ្ទៃដីចំនួន ២៥ហិចតា ក្រោយមកទៀត ក្រុមការងារបានពង្រីកផ្ទៃដីបន្ថែមចំនួន ២៥ហិចតា ពីលើបន្ថែមលើផ្ទៃដីដែលមានស្រាប់។ បង្កើតចម្ការគ្រាប់ពូជរួចមក នាយផ្នែកបន្ទាយស្រី ដែលមានលោក **ឃឹម ប៉ាន់** ជានាយផ្នែក បានសរសេរលាយល័ក្ខណ៍អក្សរដោយដៃផ្ទាល់ ផ្ទេរសិទ្ធិទៅឲ្យសង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្នារក្រៅ ជាអ្នកមើលការខុសត្រូវដែលមានលោក **ប៊ូ វណ្ណៈ** ជានាយសង្កាត់ និងលោក **ម៉ុង ប៊ុនលីម** ជានាយរងសង្កាត់។

ក្នុងឆ្នាំ២០០៤ ចម្ការពូជគ្រញូងត្រូវបានបង្កើតជាលើកដំបូង ដែលបានរៀបចំឡើងដោយខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តសៀមរាបដែលបាន ប្រគល់ឲ្យសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅជាអ្នកមើលការខុសត្រូវ និងការពារតំបន់ដែលមានផ្ទៃដីទំហំ ៥០ហិចតា តាមប្រកាសលេខ ៣៣៤ ប្រក.ស.ក.ស ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការបង្កើតតំបន់ប្រភពគ្រាប់ពូជគ្រញូង និងធ្នង់ក្នុងខេត្តសៀមរាប ដើម្បីធ្វើការរៀបចំ និងគ្រប់គ្រង និងអភិវឌ្ឍន៍។ ពេលនោះមានកងកម្លាំងយាមការចំនួន ០២នាក់។ នៅឆ្នាំ២០០៦ ផ្ទៃដីចម្ការពូជគ្រញូងមានទំហំ ២៥០ហិចតា ដែលពេលនោះបានដាក់កងកម្លាំងយាមល្បាតចំនួន ០៤នាក់។ នៅឆ្នាំ២០១០ ចម្ការពូជគ្រញូង បានពង្រីកបន្ថែមទំហំ ១.៨៨៨ ហិចតា តាមប្រកាសលេខ ៦៨៥ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

## ២.១.២ រចាយ និខដខ់ស៊ីតេប្រជាជន

ស្ថិតិប្រជាជន ជាកត្តាមួយយ៉ាងសំខាន់ផងដែរសំរាប់កំនត់នូវភាពរីកចម្រើនរបស់ស្រុកភូមិ។ ឃុំយុនរាម មានប្រជាជនសរុប ១៧៣២ គ្រួសារ មានមនុស្សសរុប ៧៨៦០នាក់ ស្រី ៣៩៤២នាក់។ មានអាយុ១៨ឆ្នាំឡើងមាន ៥៦៥៣នាក់ ស្រី ២៣៤០នាក់ (សាលាឃុំ យុនរាម, ស្ថិតិក្នុងខែមេសា ឆ្នាំ២០១៩)។

តារាង ២.១៖ ស្ថិតិប្រជាពលរដ្ឋតាមបណ្តាលភូមិក្នុងឃុំយុនរាម ខែមេសា ឆ្នាំ២០១៩

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារសរុប | ចំនួនប្រជាពលរដ្ឋសរុប | អាយុ១៨ឆ្នាំឡើងទៅ |
|---|---|---|---|---|

| | | | សរុប | ស្រី | សរុប | ស្រី |
|---|---|---|---|---|---|---|
| ១ | ឈូកស | ២៣០ | ១០០៧ | ៥១៤ | ៦២៤ | ៣២៣ |
| ២ | កំព្រហ្ម | ៥៧៥ | ២៦៣៥ | ១៣៣១ | ១៥៧៩ | ៧៧៦ |
| ៣ | ឃុនរាម | ១៩៤ | ៩៩០ | ៤៨២ | ៥៨៧ | ២៩៥ |
| ៤ | ខ្នាររង្វាស | ១៤៧ | ៦៨៦ | ៣៧៤ | ៣៦៥ | ១៩៧ |
| ៥ | ទួលគ្រួស | ១៨៤ | ៨៧២ | ៤២៥ | ៥១៩ | ២៥៧ |
| ៦ | ត្រពាំងថ្ម | ២៤៦ | ១១០០ | ៥១៤ | ៥៩៥ | ២៨៨ |
| ៧ | ពើងឆ័ត្រ | ១៥៦ | ៥៧០ | ៣០២ | ៣៨៤ | ២០៤ |
| សរុបរួម | | ១៧៣២ | ៧៨៦០ | ៣៩៤២ | ៤៦៥៣ | ២៣៤០ |

ប្រភពទិន្នន័យ: សាលាឃុំឃុនរាម ស្ថិតិក្នុងខែមេសា ឆ្នាំ២០១៩

### ២.១.៣ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន

ប្រជាជនដែលរស់នៅក្នុងឃុំឃុនរាមស្រុកបន្ទាយស្រីខេត្តសៀមរាបពួកគាត់ភាគច្រើនជាកសិករ ដោយប្រកបរបរធ្វើស្រែ និងចម្ការដូចជាការដាំដំណាំស្រូវ ដាំដំឡូង ស្វាយចន្ទីជាដើម និងមុខរបរបន្ទាប់បន្សំមានដាំបន្លែ ការចិញ្ចឹមសត្វ ទទួលអនុផលព្រៃឈើ និងលក់ដូរ។ ប្រជាជននៅទីនោះមិនប្រកបរបរបបាញ់ទេ តែពួកគាត់ស្វែងរកកាប់ឈើដើម្បីធ្វើអុសសម្រាប់ប្រើប្រាស់ និងយកលក់នៅលើទីផ្សារ។ ប៉ុន្តែការកាប់ឈើប្រណិតផ្សេងៗមិនមានសកម្មភាពទៀតនោះទេនាពេលបច្ចុប្បន្ន បន្ទាប់ពីមានការអប់រំផ្សព្វផ្សាយ និងចាត់វិធានការយ៉ាងតឹងរឹងដល់ប្រជាជនដោយអាជ្ញាធរមូលដ្ឋាន និងសង្កាត់រដ្ឋបាលផងដែរ។

### ២.១.៤ ប្រភេទដី

នេះជាលក្ខណៈសម្បត្តិមួយសំខាន់ ដីមមោក និងដីល្បាប់ជ្រៅជាប្រភេទដីល្អបំផុតសម្រាប់ដាំឈើ។ ដីមមោកជារឿយៗច្រើនជួបប្រទះនៅផ្នែកខាងក្រោមនៃជំរាលដែលកើតឡើងពីការប្រមូលផ្តុំនៃដី និងកំទេចកំទីរុក្ខជាតិ។ ដីល្បប់កើតឡើងពីកំទេចកំណាដែលរងធ្លាក់នៅស្រទាប់ក្រោមនៃផ្ទៃទឹក ដែលជាទូទៅរួមផ្សំដោយភក់និងដីឥដ្ឋ។ ដីដែលនៅពាក់កណ្តាលជំរាលក៏សមស្របសម្រាប់ដាំឈើផងដែរ។ នៅក្នុងតំបន់ដែលមាន ស្រទាប់ថ្មបាយក្រៀមនៅក្បែរផ្ទៃដីបង្ករការលំបាកដល់ការចាក់ឬសចុះក្រោម ហើយដីប្រភេទនេះមិនសមស្របចំពោះការដាំឈើជាលក្ខណៈពាណិជ្ជកម្មទេ។ ក៏ប៉ុន្តែ សម្រាប់គោលបំណងការពារហូរច្រោះដី គេគួរជ្រើសរើសប្រភេទស្មៅនិងគុម្ពព្រឹក្សមកដាំនៅតំបន់នោះ។

### ២.១.៥ លក្ខណៈអាកាសធាតុ

ប្រទេសកម្ពុជា ជាប្រទេសនៅ អាស៊ីមូសុង ស្ថិតនៅក្នុងតំបន់ត្រូពិច ដូចនេះអាកាសធាតុខេត្តសៀមរាប លក្ខណៈដូចគ្នាទៅនឹងតំបន់ផ្សេងៗទៀតដែលនៅក្នុងប្រទេសកម្ពុជា។

- រដូវប្រាំង៖ មានរយៈពេល ០៦ខែ គឺចាប់ផ្តើមពីខែវិច្ឆិកា រហូតដល់ ខែមេសា។ រដូវប្រាំងនេះបែងចែកជាពីរគឺ រដូវរំហើយ និងរដូវក្តៅ។ រដូវរំហើយមានរយៈពេល ០៣ខែ គឺចាប់ពីខែវិច្ឆិការ ហើយបញ្ចប់ទៅវិញក្នុងខែមករា។ ពេលនេះខ្យល់មូសុងប្រាំងបក់មកពី ទិសខាងជើងឈៀងខាងកើតដោយនាំ ចំហាយត្រជាក់ពីស៊ីបេរីមកជាមួយផង។ អាកាសធាតុនេះ ត្រជាក់ហើយស្ងួត ពីខែកុម្ភៈ រហូតដល់ខែមេសា គឺជារដូវក្តៅ។ អាកាសធាតុនេះ មានរយៈពេល ០៣ខែ មានលក្ខណៈពិបាកទ្រាំនៅពេលថ្ងៃ រុក្ខជាតិមានស្លឹកស្វិតស្រពោនរញោម ប្រភេទឈើមួយចំនួន បានជ្រុះស្លឹកអស់ គឺជាអាកាសធាតុក្តៅហើយសើម (យ៉ង់ ភិរម្យ, ១៩៩៨)។
- រដូវវស្សា៖ មានរយៈពេល ០៦ខែ គឺចាប់ពីខែឧសភា ដល់ខែតុលា។ រយៈពេលនេះ ខ្យល់មូសុងបានបក់មកពីទិសនារតី នៃប្រទេស ពោលគឺបកមកពីមហាសមុទ្រឥណ្ឌា ដោយនាំយកបរិមាណទឹកភ្លៀងច្រើនសន្ធឹកសន្ធាប់ ភ្លៀងចាប់ផ្តើមនៅពេលនេះ។ ប៉ុន្តែជារៀងរាល់ឆ្នាំគេសង្កេតឃើញ មានកូនរដូវប្រាំងមួយនៅចន្លោះរដូវវស្សា ដែលមានរយៈពេលពី ១០-១៥ថ្ងៃ គឺនៅចុងខែកក្កដា និងដើមខែសីហា (យ៉ង់ ភិរម្យ, ១៩៩៨)។

### ២.១.៦ ធនធានព្រៃឈើនៅក្នុងស្រុកបន្ទាយស្រី

ធនធានព្រៃឈើក្នុងស្រុកបន្ទាយស្រី មានលក្ខណៈអំណោយផលដល់ធម្មជាតិយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ច ដែលសំបូរទៅដោយព្រៃឈើធម្មជាតិចម្រុះ ក្នុងនោះមានព្រៃស្រោង ព្រៃល្បោះ។ ព្រៃទាំងនោះគឺជាប្រភពផ្គត់ផ្គង់ ផល-អនុផល ព្រៃឈើយ៉ាងសំបូរបែបផ្សេងៗ ដល់សង្គមជាតិ។ ផល-អនុផលព្រៃឈើទាំងនោះមានតម្លៃ ក្នុងពាណិជ្ជកម្ម អាចយកមកប្រើប្រាស់សម្រាប់គ្រឿងសង្ហារឹម គ្រឿងសំណង់ អុស ធ្យូង។

តារាង ២.២៖ ប្រភេទព្រៃ និងទំហំផ្ទៃដីព្រៃឈើទូទាំងស្រុកបន្ទាយស្រី

| ល.រ | ប្រភេទព្រៃ | ទំហំគិតជាហិចតា | ភាគរយ% |
|---|---|---|---|
| ១ | ព្រៃស្រោង | ១២១៤៩ | ២០.២២ |
| ២ | ព្រៃពាក់កណ្តាលស្រោង | ២១២៦ | ៣.៥៣ |
| ៣ | ព្រៃល្បោះ | ៤៧៦២ | ៧.៩២ |
| ៤ | ព្រៃផ្សេងៗ | ១២៨៧៥ | ២១.៤៣ |

| | | | |
|---|---|---|---|
| ៥ | ព្រៃគុម្ពោតបៃតង | ៧៨៧១ | ១៣.១០ |
| ៦ | ព្រៃគុម្ពោតស្ងួត | ១២២ | ០.២០ |
| ៧ | ដីមិនមែនព្រៃ ដីលំនៅដ្ឋាន និងដីផ្សេងៗ | ២០១៧០ | ៣៣.៥៧ |
| | សរុប | ៦០០៧៥ | ១០០% |

ប្រភព៖ ផ្នែករដ្ឋបាលបន្ទាយស្រី

ផ្អែកតាមតួលេខខាងលើឃើញថា ទំហំផ្ទៃដីព្រៃឈើ (ព្រៃស្រោងមានទំហំ ២០.២២% ព្រៃពាក់កណ្ដាលស្រោង ៣.៥៣% ព្រៃល្បោះមានចំនួន ៧.៩២% ព្រៃគុម្ពោតបៃតងមានចំនួន ១៣.១០% ព្រៃគុម្ពោតស្ងួត ០.២០% និងព្រៃផ្សេងៗមានចំនួន ២១.៤៣% បើធៀបនឹងផ្ទៃដីស្រុកទាំងមូល)។ ដោយសង្កេតឃើញដូចនេះវាស្ទើរតែគ្របលើ ផ្ទៃទាំងមូលជាង ៥០% នេះបញ្ជាក់ឲ្យឃើញថា ស្រុកបន្ទាយស្រីជាស្រុកមួយក្នុងចំណោមស្រុកទាំងអស់នៃខេត្តសៀមរាបមានព្រៃឈើក្រាស់ក្រៃលគ្រាន់បើ។

### ២.១.៧ ធនធានសត្វព្រៃ

ចំពោះធនធានសត្វព្រៃនៅក្នុងតំបន់ភូមិសាស្ត្រស្រុកបន្ទាយស្រី បានឲ្យដឹងថានៅក្នុងស្រុកនេះ សំបូរដោយពពួកសត្វព្រៃជាច្រើនប្រភេទមានដូចជា ពពួកថនិកសត្វ រួមមាន ដំរី ទន្សោងឈ្លូស ខ្ទីង ប្រើស សត្វស្វា ឆ្កែចចក ខ្លាត្រី កាំប្រម៉ា។ ពពួកល្មូនជាច្រើនប្រភេទដូចជា ត្រកួត អន្សង ពង្រូល ពស់ថ្លាន់ ពស់វែក ជាដើម និងប្រភេទសត្វបក្សីមានចំនួនផងដែរ រួមមាន កេងកង អង្កត់ខ្មៅល្វាចេក ត្រដក់ ជាដើម ដែលពពួកសត្វទាំងនេះបានជ្រកកោនក្នុងព្រៃនៃ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

### ២.១.៨ សក្ដានុពលនៅតំបន់នោះ

ទាក់ទិននឹងសក្ដានុពលនៅក្នុងតំបន់ចម្ការពូជឈើគ្រញូងរួមមាន៖

- ចម្ការគ្រាប់ពូជ ជាតំបន់ដែលសម្បូរទៅដោយប្រភេទឈើប្រណិត ប្រភេទឈើលេខ១ ប្រភេទឈើលេខ២ ប្រភេទឈើលេខ៣ និងប្រភេទឈើក្រៅលំដាប់ថ្នាក់។
- ជាកន្លែងដែលអាចផ្គត់ផ្គង់ នូវប្រភពគ្រាប់ពូជទៅកាន់តំបន់ផ្សេងៗ នៅក្នុងទូទាំងប្រទេសកម្ពុជា
- អាចទាក់ទាញនូវប្រភេទសត្វព្រៃដូចជា ជ្រូកព្រៃ ប្រើស ក្ដាន់ ស្វា ក្ងោក ជាពិសេសប្រភេទសត្វកម្រដូចជា ទន្សោង និងប្រភេទសត្វតាដក ដែលកំពុងតែមកតាំងសំបុកក្នុងតំបន់ចម្ការពូជ

- ចម្ការពូជក្រញូងជាគោលដៅទេសចរណ៍ក្នុងការទាក់ទាញភ្ញៀវអោយមកចូលទស្សនាប្រភេទឈើ ក៏ដូចជាប្រភេទសត្វព្រៃផងដែរ។

## ២.២ ចក្ខុវិស័យ គោលបំណង គោលដៅ និងបេសកម្ម

### ២.២.១ ចក្ខុវិស័យ

គឺការគ្រប់គ្រងធនធានព្រៃឈើដែលធានានិរន្តរភាព អេកូឡូស៊ី សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន គឺជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពសាធារណៈ។

- ការរៀបចំអោយក្លាយជាតំបន់ទេសចរណ៍សម្រាប់ភ្ញៀវ ជាតិ និង អន្តរជាតិអាចចូលទស្សនា
- ការប្រមូលបាននូវគ្រាប់ពូជប្រភេទឈើប្រណិតកាន់តែមានបានឡើង
- ការដាំស្តារឡើងវិញនូវរុក្ខជាតិចម្រុះ។

### ២.២.២ គោលបំណង

ដោយយោងតាមព្រះរាជក្រមលេខ ន/ស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ និងតួនាទីដ៏សំខាន់របស់ព្រៃឈើដល់ សង្គម មនុស្ស សត្វ និងទំនាក់ទំនងនៃព្រៃឈើនៅលើកត្តាមានជីវិត និងគ្មានជីវិតទាំងឡាយដែលស្ថិតនៅក្នុងបរិស្ថាន។ ការគ្រប់គ្រងធនធានព្រៃឈើគឺដើម្បី ការបញ្ចៀសកុំអោយមានការរេចរាលដាល ការរេចរឹលព្រៃតទៅទៀត ក្នុងការថែរក្សាស្ថេរភាព បរិស្ថាន និងស្ថានភាពសេដ្ឋកិច្ចសង្គម។

មានគោលបំណងមួយចំនួនដែលបណ្តាលអោយមាន ការខិតខំការពារ និងអភិរក្សធនធានព្រៃឈើក្នុងតំបន់គ្រប់គ្រងនៃសង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្វារក្រៅ នោះគឺៈ

- ស្តារព្រៃឈើឡើងវិញតាមរយៈការដាំឈើសម្រាប់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវសេដ្ឋកិច្ចសង្គម និងបរិស្ថាន។
- អភិវឌ្ឍន៍ចំណេះដឹងបច្ចេកទេស ដាំឈើ និងបំផុសការចូលរួមដាំឈើ
- បង្ការទប់ស្កាត់ ការហ៊ុមព័ន្ធកាន់កាប់ដីព្រៃឈើដើម្បីធ្វើជាកសិកម្ម
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និងកែលម្អដីតាមរយៈដំណុះព្រៃដាំ និងជីវចម្រុះ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិដោយបង្កើនផលិតផលឈើពីព្រៃដាំ
- ចូលរួមចំណែកក្នុងយន្តការអភិវឌ្ឍស្អាត ឬយន្តការផ្សេងៗដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើផែនដី និងចូលរួមទប់ស្កាត់ការប្រែប្រួលអាកាសធាតុ
- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំផ្សព្វផ្សាយបណ្តាល និងអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន

- សិក្សាស្រាវជ្រាវបច្ចេកទេសបណ្ដុះកូនឈើ ដាំឈើ ថែរក្សាការពារ និងប្រមូលផលអនុផល
- បណ្ដុះបណ្ដាលនិងផ្សព្វផ្សាយបច្ចេកទេសដាំដុះ ផលិត កែច្នៃ និងផ្ដល់មុខរបរដល់សហគមន៍មូលដ្ឋាន
- សហការជាមួយដៃគូអភិវឌ្ឍន៍ ដៃគូវិនិយោគក្នុងប្រទេស ឬក្រៅប្រទេសក្នុងការដាំដុះផលិតកែច្នៃនិងប្រមូលផលអនុផលចម្ការព្រៃដាំ
- កៀរគរទាក់ទាញការចូលរួមគាំទ្រ និងទទួលជំនួយឧបត្ថម្ភពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

**២.២.៣ បេសកកម្ម**

បេសកកម្មរបស់យើង គឺជម្រុញឲ្យមានការគ្រប់គ្រងនិងការអភិវឌ្ឍព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកដល់ការកាត់បន្ថយ ភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅ ការអភិវឌ្ឍសេដ្ឋកិច្ច ការការពារបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះ និងមរតវប្បធម៌របស់យើង។

## ២.៣ រចនាសម្ព័ន្ធនៃការគ្រប់គ្រងតួនាទី និងភារកិច្ចសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ

### ២.៣.១ រចនាសម្ព័ន្ធគ្រប់គ្រង

ដ្យាក្រាមរចនាសម្ព័ន្ធរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ



### ២.៣.២ តួនាទី និងភារកិច្ច

សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ មានតួនាទី និងភារកិច្ចមួយចំនួនដែលគាត់ត្រូវបំពេញមានដូចខាងក្រោម៖

- ល្បាតជាអចិន្ត្រៃយ៍ ដើម្បីត្រួតពិនិត្យការពារធនធានព្រៃឈើ និងសត្វព្រៃព្រមទាំងប្រយុទ្ធប្រឆាំងនឹងភ្លើងឆេះព្រៃ
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងគោលបំណងថែរក្សាការពារធនធានព្រៃឈើ និងសត្វព្រៃ
- រៀបចំថ្នាលបណ្តុះកូនឈើកូនឈើរួមទាំងអនុវត្តន៍ការងារដាំដើមឈើ និងស្តារព្រៃឈើឡើងវិញ
- សម្របសម្រួល និងផ្តល់ជំនួយបច្ចេកទេសផ្ទាល់ដល់សហាគមន៍ព្រៃឈើ
- អនុវត្តន៍ផ្ទាល់លើការងារធ្វើសារពើភ័ណ្ឌ និងរៀបចំព្រៃឈើ និងសត្វព្រៃ
- អនុវត្តន៍ផ្ទាល់លើការងារវាស់វែង វាយតម្លៃ និងកំណត់បរិមាណផល អនុផលព្រៃឈើ
- តាមដានរាយការណ៍ ចងក្រងសំណុំរឿងទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើប្រគល់ជូន។

## ២.៤ ទិដ្ឋភាពទូទៅតំបន់ចម្ការពូជឈើគ្រញូង

### ២.៤.១ ធនធានព្រៃឈើ និងសត្វព្រៃក្នុងចម្ការពូជឈើគ្រញូង

ផ្ទៃដីចម្ការពូជឈើគ្រញូងមានផ្ទៃដីសរុបទំហំ ១៨៨៨ ហិកតា ដែលបែងចែកជាគំរបព្រៃឈើដូចខាងក្រោម៖

| | |
|---|---|
| – ព្រៃស្រោង | ៧៨៤ ហិកតា |
| – ព្រៃពាក់កណ្តាលស្រោង | ១ ហិកតា |
| – ព្រៃល្បោះ | ៩១៣ ហិកតា |
| – ព្រៃគម្ពោធស្ងួត | ៧៣ ហិកតា |
| – ព្រៃគម្ពោធបៃតង | ៩២ ហិកតា |
| – ដីមិនមានគំរបព្រៃ | ២៥ ហិកតា |

នៅក្នុងចម្ការពូជឈើគ្រញូង មានប្រភេទឈើសំខាន់ៗ ដែលយើងរាប់តាមលំដាប់ថ្នាក់មានដូចខាងក្រោម៖

១/.ឈើប្រភេទប្រណិត

-គ្រញូង បេង នាងនួន ធ្នង់ ហៃសាន ត្រយឹង តាត្រាវ ច្រេស គ្រើល អង្កត់ខ្មៅ ។

២/.ឈើប្រភេទលេខ១ សុក្រម កកោះ ពពេល ស្រឡៅ គគីរ ត្រសេក ក្រឡាញ់ ធ្នឹក រាំងភ្នំ ទ្រាស អង្គួតខ្មោត ពពូលសំព័រ ស្តី ។

៣/.ឈើប្រភេទលេខ២

ឈើទាល ត្រាចខ្លុង ត្បែង ផ្ចៀក ខ្ទារ ត្រឡាត ស្រគុំ ស្រងាំ ច្រម៉ាស់ ផ្អុង ។

៤/.ឈើប្រភេទលេខ៣

ល្បៀង ធ្លក កណ្តោល ក្តុល ប្រាំដំឡឹង ព្រីង ព្រូស ក្របៅ ត្រមេង ត្រមូង ស្មាច់ ស្មាក្របី ស្វាយព្រៃ ខ្នុរព្រៃ ពពាលខែ ។

៥/.ឈើក្រៅលំដាប់ថ្នាក់

ពភ្លាប្រើស ពពូលថ្ម រំដួល ពន់តាឡី ពង្រ ក្រាយ រកា ចំបក់ ចំរៀក ដង្កៀបក្តាម ដកពោធិ ពេនស្វា ជើងគោ ដៃខ្លា ធ្មេញត្រី មៀនព្រៃ ភ្លៅមាន់ ឈើភ្លើង ជ្រៃ សេមាន់ ស្តៅ ត្បៀរ អង្គារសីល អង្គារបុស្ស កញ្ចើបាយដាច ភ្ញាស ភ្លូង រាំងទឹក ព្រះភ្នៅ រមាំង ត្រមូងសេក សង្កែ សំរោង ស្នួល តាឡាក់ ទំពូង បាក់ដង លឿងរាជ ក្រូង ល្វា ល្វៃ ពួច ស្តុកស្តុល ស្រម៉ រំពុក(ស) រំពុក(ក្រហម) រវៀង ពោល្វែក លាំងជ័យ ភ្នំភ្នេង ក្រាង ត្រប៉ែកឬខ្វិត ត្របែកព្រៃ។

នៅក្នុងចម្ការពូជឈើគ្រញូងមានប្រភេទសត្វព្រៃសំខាន់ៗ ដូចខាងក្រោមៈ

- o ជ្រូកព្រៃ ឈ្លូស ប្រើស រមាំង ស្វាក្រេស ស្វាអង្កត់ ស្វាខ្មៅ
- o សំពោច ខ្លត្រី ស្ការ អណ្តើក ត្រកួត ទន្សាយ
- o ក្ងោក ព្រាប មាន់ព្រៃ មាន់ទោ កេងកង ឥទ្រីពស់ លលក ពពូល ស្ទាំង សារិកា សេក ទីទុយ កុក មៀម។

### ២.៤.២ បទបញ្ជាផ្ទៃក្នុងនៃការចេញ និងចូលតំបន់ចម្ការពូជឈើគ្រញូង

ដោយយោងតាមប្រសាសន៍របស់នាយសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ បានឲ្យដឹងថា កន្លងមកតំបន់ព្រៃការពារតែងតែជួបប្រទះនូវសកម្មភាពបទល្មើសជាច្រើនបង្កឡើងដោយជនខិលខូចដែលតែងតែយកតំបន់ព្រៃការពារធ្វើជាកន្លែងអាជីវកម្មរបស់ខ្លួន និងប្រជាពលរដ្ឋតែងតែចេញចូលតំបន់ការពារពុំមានការទទួលខុសត្រូវនិងបង្កការស្មុគស្មាញដល់មន្ត្រីអនុវត្តច្បាប់។ ការធ្វើនូវបទបញ្ជានេះឡើងក្នុងគោលបំណង ការពារអភិរក្សធនធានធម្មជាតិ និងលើកកម្ពស់ជីវភាពប្រជា-ពលរដ្ឋក្នុងតំបន់នោះ។ តំបន់ព្រៃការពារសៀមរាបដែលមានបទបញ្ជាមួយចំនួនដូចខាងៈ

- ក្នុងការចេញចូលត្រូវមានលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំ និងត្រូវមានមន្ត្រីល្បាតថាអ្នកនាំផ្លូវជានិច្ច។

- ហាមទៅលើបទល្មើសការបរបាញ់គ្រប់ប្រភេទ
- មិនអនុញ្ញាតឲ្យមានការកាប់ព្រៃឈើក្នុងចម្ការ
- ការដុតព្រៃដើម្បីបំណងណាមួយគឺមិនត្រូវបានអនុញ្ញាតនោះទេ
- អាវុធជាតិផ្ទុះមិនត្រូវអនុញ្ញាតឲ្យយកចេញ-ចូលតំបន់ព្រៃការពារបានឡើយ លើកលែងតែ៖
    - o មន្ត្រីរាជការដែលមានលិខិតបញ្ជាបេសកម្មច្បាស់លាស់
    - o មន្ត្រីរាជការជាថ្នាក់ដឹកនាំដែលគ្រាន់តែឆ្លងកាត់
    - o កម្លាំងសមត្ថកិច្ចប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋាន ( ភូមិ ឃុំ ស្រុក)។

## ២.៥ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានព្រៃឈើ

### ២.៥.១ គោលនយោបាយគ្រប់គ្រងធនធានព្រៃឈើ

ព្រះរាជក្រឹត្យដែលបានឡាយព្រះហត្ថលេខាដោយព្រះបាទសម្តេចព្រះនរោត្តមសីហនុ នៅថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ វាគឺជារឿងដែលប្រសើរថ្លៃថ្លាបំផុត ដើម្បីធ្វើការអភិរក្សនូវធនធានធម្មជាតិដែលកំពុងទទួលរងនូវការបាត់បង់ដ៏ធ្ងន់ធ្ងរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់ចំណុច មាត្រា៥៩ បានចែងថា ″ រដ្ឋ ត្រូវការពារបរិស្ថាន និង តុល្យភាពភោគទ្រព្យធម្មជាតិ ហើយត្រូវបែងចែកអោយមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ខ្យល់អាកាស ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត ឧស្ម័ន ថ្ម ខ្សាច់ ត្បូងថ្ម ព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ និងធនធានជលផល។

គោលនយោបាយសំខាន់ៗក្នុងវិស័យព្រៃឈើ ដើម្បីចូលរួមចំណែកកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដោយបន្តអនុវត្តន៍កម្មវិធីព្រៃឈើជាតិ រួមមាន៖ ការកែលម្អ និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើ ការដាំដុះស្តារព្រៃឈើឡើងវិញ ការបង្កើនសមត្ថភាព និងការស្រាវជ្រាវដើម្បីផ្តល់ព័ត៌មានវិទ្យាសាស្ត្រ ក្នុងការធ្វើសេចក្តីសម្រេចគោលនយោបាយក្នុងការអភិវឌ្ឍវិស័យព្រៃឈើអោយមាននិរន្តរភាព និងប្រសិទ្ធភាពខ្ពស់។

ទី១. **ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងព្រៃឈើ៖** មានកិច្ចការសំខាន់ៗមួយចំនួនដែលនឹងជួយរួមចំណែកបង្កើនប្រសិទ្ធភាព ក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពរួមមានជាអាទិ៍ ការពិនិត្យនិងកំណត់ឡើងវិញនូវព្រំប្រទល់ដែនព្រៃឈើ ការចុះបញ្ជី និងការរៀបចំផែនការគ្រប់គ្រងអភិវឌ្ឍន៍ និងអភិរក្សអោយស្របតាមមុខងារ និងស្ថានភាពព្រៃតាមតំបន់នីមួយៗ។ ក្នុងន័យនេះ តំបន់មានសក្តានុពលមួយចំនួន រួមទាំងតំបន់សហគមន៍ព្រៃឈើនឹងត្រូវមានរៀបចំអនុវត្តន៍គម្រោង REDD+ ដែលជាកិច្ចការបន្ថែមទៅលើតំបន់

មួយចំនួនដែលរដ្ឋាភិបាលព្រៃឈើបាន និងកំពុងអភិវឌ្ឍន៍គម្រោង REDD+(Reducing Emission from Deforestation and Forest Degradation) ។ ចំណូលពីការលក់កាបូន គឺជាកម្លាំងចលករដ៏សំខាន់មួយ ក្នុងការជំរុញអោយភាគីពាក់ព័ន្ធនានាក្នុងវិស័យព្រៃឈើ ពិសេសប្រជាសហគមន៍ និងអាជ្ញាធរមូលដ្ឋានចូលរួមកាន់តែខ្លាំងក្លាថែមទៀត ក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។

**ទី២. ការអភិរក្ស និងស្តារព្រៃឈើ៖** ការងារអាទិភាពមួយចំនួនទៀតក្នុងការអភិរក្ស និងគ្រប់គ្រងព្រៃឈើ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុនេះ រួមមាន៖ ការជំរុញអោយមានផែនការប្រើប្រាស់ដីក្នុងតំបន់សម្បទានសេដ្ឋកិច្ច អោយបានសមស្របតាមលក្ខណៈបច្ចេកទេស ការបង្កើនការយល់ដឹងអំពីភ្លើងឆេះព្រៃ និងការការពារ ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ព្រមទាំងការពារ និងអភិរក្សជីវៈចម្រុះ។ ការស្តារ ការដាំដុះដើមឈើ និងព្រៃឈើឡើងវិញ ជាពិសេសផ្តោតទៅលើការស្តារគម្របព្រៃឈើតំបន់វេចរិល ក៏ជាការងារចាំបាច់ផងដែរក្នុងការឆ្លើយតបនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុតាមរយៈការលើកទឹកចិត្តដល់ការដាំចម្ការឈើឯកជន សហគមន៍ និងជាលក្ខណៈចម្ការព្រៃឈើដៃគូ ដោយដាំប្រភេទឈើចម្រុះឬឈើឧស្សាហកម្ម ក្នុងគោលបំណងសម្រាប់បង្កើនជីវភាព និងបង្កើនសេវាកម្មបរិស្ថាន។ ទន្ទឹមគ្នានោះដែរ ត្រូវយកចិត្តទុកដាក់ផ្តោតលើការរៀបចំគោលនយោបាយ បទបញ្ញត្តិ ច្បាប់ និងឯកសារបច្ចេកទេសផ្សេងៗ សម្រាប់គាំទ្រការងារដាំឈើ និងស្តារព្រៃឈើប្រកបដោយប្រសិទ្ធភាពជាចាំបាច់។

**ទី៣. ការស្រាវជ្រាវ និងការផ្សព្វផ្សាយ៖** ការសិក្សាស្រាវអំពីការបន្សុំ និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងសកម្មភាព ក្នុងការគ្រប់គ្រងព្រៃឈើជាកត្តាចាំបាច់ណាស់ក្នុងការរួមចំណែកក្នុងការបន្សុំ និងជម្នះក្នុងការដោះស្រាយបញ្ហា ដែលកើតឡើងពីការប្រែប្រួលអាកាសធាតុដើម្បីធានាដល់សន្តិសុខស្បៀង ការបង្កើនជីវភាពរស់ និងការកែលម្អផ្នែកបរិស្ថាន ដែលការងារនេះអាចជួយបង្កើតប្រព័ន្ធនៃការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិផងដែរ។ បង្កើនសមត្ថភាពស្ថាប័ន និងជំនាញបច្ចេកទេសក្នុងការគ្រប់គ្រងព្រៃឈើ ជាកត្តាសំខាន់ណាស់ក្នុងការចូលរួមចំណែកការគ្រប់គ្រងព្រៃឈើសំដៅកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ការងារនេះអាចធ្វើឡើងតាមរយៈ ការផ្តល់វគ្គបណ្តុះបណ្តាល ការធ្វើទស្សនកិច្ចសិក្សា ការចូលរួមប្រជុំ សិក្ខាសាលាក្នុង និងក្រៅប្រទេស និងបន្ទប់ពិសោធន៍សម្រាប់បម្រើអោយការអនុវត្ត។ ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីការប្រែ

ប្រែប្រួលអាកាសធាតុអោយដល់គ្រប់មជ្ឈដ្ឋាន ជាពិសេសអាជ្ញាធរដែនដី និងសហាគមន៍មូលដ្ឋានជាកត្តាគន្លឹះផងដែរ។

**ទី៤. ការពង្រឹងការអនុវត្តច្បាប់៖** សមត្ថភាពក្នុងការគ្រប់គ្រង និងការពារព្រៃឈើរបស់ស្ថាប័នជំនាញនៅមានកម្រិត ដោយសារមិនមានមន្ត្រីគ្រប់គ្រាន់ដើម្បីបំពេញការងារ និងកង្វះខាតមធ្យោបាយសម្ភារៈ និងបរិក្ខារក្នុងការគ្រប់គ្រង និងការពារព្រៃឈើ។ ដើម្បីចូលរួមកាត់បន្ថយការបាត់បង់ព្រៃឈើ ដែលបង្កអោយមានការប្រែប្រួលអាកាសធាតុនេះ ចាំបាច់ពង្រឹងសមត្ថភាពក្នុងការអនុវត្តច្បាប់ តាមរយៈការពង្រឹងសមត្ថភាពជំនាញ និងបំពាក់មធ្យោបាយគ្រប់គ្រាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ។

**ទី៥. ការបន្សុាំទៅនឹងការប្រែប្រួលអាសធាតុ៖** ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ការងារ បន្សុាំក៏មានសារសំខាន់ ដូចការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែរ។ យុទ្ធសាស្ត្រ សំខាន់ៗដើម្បីបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុរួមមាន៖ ការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុដល់សហាគមន៍ ដែលរស់នៅក្បែរ និងក្នុងតំបន់ព្រៃឈើ ការកំណត់នៅតំបន់ព្រៃ និងសហាគមន៍ព្រៃឈើណាដែលងាយរងគ្រោះ ដោយការប្រែប្រួលអាកាសធាតុ ការរៀបចំការកាត់បន្ថយភាពងាយរងគ្រោះ និងការស្រាវជ្រាវរក និងដាំដុះនូវប្រភេទឈើដែលស៊ូទ្រាំបានល្អ ជាមួយការប្រែប្រួលអាកាសធាតុ។

### ២.៥.២ គោលនយោបាយគ្រប់គ្រងធនធានព្រៃឈើរបស់សង្កាត់រដ្ឋបាលកន្ទួតខ្វាវក្រៅ

គោលនយោបាយ នៃការគ្រប់គ្រងព្រៃឈើរបស់ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្វារក្រៅគឺ អនុលោមទៅតាម គោលនយោបាយព្រៃឈើ ជាតិនិងច្បាប់ស្តីពីព្រៃឈើ ជាពិសេសការកសាងផែនការត្រូវផ្អែក និងឆ្លុះបញ្ចាំងខ្លឹមសារប្រាំចំណុចដូចតទៅ៖

១. ការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីឈានទៅរកការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព។

២. ធនធានព្រៃឈើដែលនៅសល់ត្រូវរក្សាទុកជាព្រៃផ្តល់ផលដោយរៀបចំតាមបែបផែននៃការអភិរក្ស នឹង ការគ្រប់គ្រងប្រកបដោយនិរន្តរភាពសម្តៅស្តារឡើងវិញអោយបាននូវផលជាអតិបរមានៃដីព្រៃឈើ និងធនធានព្រៃឈើ។

៣. បំផុសអោយមានការចូលរួមពីសំណាក់ផ្នែកឯកជន និង សហាគមន៍មូលដ្ឋានក្នុងការអភិរក្ស នឹងដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន។

៤. សម្របសម្រួល ជាមួយស្ថាប័នដែលពាក់ព័ន្ធទាំងអស់ នៅក្នុងមូលដ្ឋានក្នុងការរៀបចំ និង ការគ្រប់គ្រងព្រៃឈើដើម្បីឆ្លើយតបទៅ និង ផលប្រយោជន៍ដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ។

៥. បន្តជម្រុញដំណើរការដាំដើមឈើឡើងវិញ នៅតាមទីកន្លែងដែលអាចដាំបាន និង ការពារកូនឈើដែលបានដាំកន្លងមក ដើម្បីបង្កើនធនធានព្រៃឈើ។

### ២.៥.៣ ផែនការយុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានព្រៃឈើ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ របស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ បានកំណត់នៅក្នុងកម្មវិធីទី៤៖ ការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ ប្រកបដោយនិរន្តរភាព៖

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល បានផ្តោតលើការគ្រប់គ្រង និងអភិរក្ស ធនធានធម្មជាតិ ដើម្បីធានាកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅ តំបន់ជនបទ តាមរយៈការជំរុញអនុវត្ត "**កម្មវិធីព្រៃឈើជាតិ**" ការត្រួតពិនិត្យតាមដានការធ្វើអាជីវកម្ម ព្រៃឈើ ការពង្រឹងការអនុវត្ត "**ច្បាប់ស្តីពីព្រៃឈើ**" និងការអនុវត្តវិធានការម៉ឺងម៉ាត់ចំពោះបទល្មើស ព្រៃឈើ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃការពារ ការអនុវត្តស៊ីជម្រៅនូវកំណែទម្រង់ក្នុងវិស័យព្រៃ ឈើ។

ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង និងពង្រីកថែមទៀតនូវការគ្រប់គ្រង ធនធានធម្មជាតិសំដៅរក្សា "**តុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្ស**" ពិសេសលើកកម្ពស់ វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ(១)ការធានាតម្របបៃតង ការអភិរក្សព្រៃឈើ និងសត្វព្រៃ (២)ការធានាចីរភាពប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាគុណភាពដី និងចីរ ភាពនៃប្រភពទឹក ដោយផ្តោតទៅលើការការពារជីវចម្រុះ តំបន់ដីសើម និងតំបន់ឆ្នេរ។

**គោលបំណងកម្មវិធីទី៤៖** "បង្កើនការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំអោយបានយ៉ាងតិច២៥.០០០.ហិកតា ក្នុង១ឆ្នាំ បង្កើតព្រៃការពារ និងតំបន់អភិរក្សសត្វព្រៃអោយបាន៥០.០០០.ហិកតាក្នុង១ឆ្នាំ និងបង្កើន សហគមន៍ព្រៃអោយបាន៣២សហគមន៍ក្នុង១ឆ្នាំ"។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងផ្តោត សកម្មភាពជាអាទិភាពលើ៖

- ការបន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ ប្រកបដោយចីរភាព និងសមធម៌ស្រប តាម "**កម្មវិធីព្រៃឈើជាតិ**" ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់នឹងអភិបាលកិច្ច

ការកំណត់ព្រំប្រទល់ចំណាត់ថ្នាក់ និងការចុះបញ្ជីដែនព្រៃឈើ ការគ្រប់គ្រងនិងប្រើប្រាស់អោយមានប្រសិទ្ធភាពនូវព្រៃឈើរដ្ឋ និងឯកជន។

- ការអនុវត្តវិធានការលើកកម្ពស់ជីវភាព និងការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យព្រៃឈើ ការលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងនឹងអភិរក្ស ការកាត់បន្ថយនូវការបាត់បង់ និងរេចរិលព្រៃឈើ។
- ការបង្កើនការដាំ និងស្តារព្រៃឈើឡើងវិញ ការពង្រឹងកិច្ចអភិរក្សសត្វព្រៃ និងជម្រកសត្វព្រៃ ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការជំរុញការងារស្រាវជ្រាវ និងផ្សព្វផ្សាយក្នុងវិស័យព្រៃឈើ។
- ការបន្តជម្រុញអនុវត្តវិធានការនានា ដើម្បីថែរក្សាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី សំដៅធានាគុណភាពដីនឹងទឹក រួមទាំងទឹកក្រោមដីផង សម្រាប់បម្រើអោយវិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការជម្រុញការរៀបចំ និងអនុវត្តគោលនយោបាយ និងបទដ្ឋានគតិយុត្ត ព្រមទាំងផែនការសកម្មភាព និងកម្មវិធីនានា អោយមានប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចជាជម្រកសត្វព្រៃ តំបន់ព្រៃការពារ តំបន់អភិរក្សធម្មជាតិ។
- ការបន្តជម្រុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ តាមរយៈការអនុវត្តក្របខណ្ឌគតិយុទ្ធ និងយន្តការសម្រាប់ការធ្វើពាណិជ្ជកម្មកាបូន ការពង្រឹងសមត្ថភាព ការរៀបចំនិងអនុវត្តវិធានការសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីឲ្យ ដំណើរការគ្រប់គ្រងព្រៃឈើ ប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធិភាព និង និរន្តរភាព ការបង្កើតអោយមានយុទ្ធសាស្ត្រគ្រប់គ្រង គឺជាការចាំបាច់ខ្លាំងណាស់។ ដូចនេះ ដើម្បីគ្រប់គ្រងធនធានព្រៃឈើឲ្យមាននិរន្តរភាពនោះគឺ ទាមទារអោយមានការសិក្សានិងវិភាគអោយបានច្បាស់លាស់នូវ ទីតាំងភូមិសាស្ត្រសក្តានុពលតំបន់ ជាពិសេសនោះការចូលរួមពីប្រជាជនមូលដ្ឋានដើម្បីរួមគ្នាពិភាក្សា ស្វែងរកតម្រូវការជាអាទិភាព រួចរៀបជាយុទ្ធសាស្ត្រគ្រប់គ្រងមួយ ដែលមានការទទួលស្គាល់ធានានិរន្តរភាពព្រៃឈើ។ បច្ចុប្បន្ននេះសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្ទារក្រៅបានដាក់ចេញសកម្មភាពធំៗចំនួនប្រាំដូចជា៖

- ការអភិរក្សនិងគ្រប់គ្រងធនធានធម្មជាតិ គឺជាការកំណត់ព្រំប្រទល់និងគ្រប់គ្រងសម្បត្តិព្រៃឈើអចិន្ត្រៃយ៍និងការពារទីជម្រកសំខាន់ៗការការពារសត្វព្រៃ ការត្រួតពិនិត្យការរុករានដីនឹងការហ៊ុមព័ទ្ធយកដីព្រៃឈើរបស់រដ្ឋដោយខុសច្បាប់ហើយនឹងការត្រួតពិនិត្យប្រភេទត្បាត និង ជម្ងឺសត្វព្រៃសម្រាប់ធានាដល់ការគ្រប់គ្រង និង ប្រើប្រាស់ធនធានព្រៃឈើដោយនិរន្តរភាព។
- ការរៀបចំ នឹង គ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និង ទេសចរណ៍ធម្មជាតិគឺ ជាការគ្រប់គ្រងធនធាន និង សកម្មភាពទេសចរណ៍ធម្មជាតិទីផ្សារទេសចរណ៍ធម្មជាតិ នឹង សេវាកម្មនាំភ្ញៀវទេសចរណ៍នៅក្នុងតំបន់។
- សមាហរណកម្មការអភិវឌ្ឍសហគមន៍ និង ការចូលរួមគឺ ជាការពង្រឹងដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើ ធនធានធម្មជាតិ នឹង ដោះស្រាយជម្លោះហើយ នឹង លើកកម្ពស់កិច្ចសហប្រតិបត្តិការថ្នាក់មូលដ្ឋាន នៅក្នុងការគ្រប់គ្រងតំបន់និងការអប់រំផ្សព្វផ្សាយ។
- ការអភិវឌ្ឍធនធានមនុស្ស និង ពង្រឹងសមត្ថភាព នឹង ធ្វើអោយប្រសើរឡើងដល់ការគ្រប់គ្រងរបស់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន នឹងបណ្តុះបណ្តាល បំពាក់បំប៉ន ការយល់ដឹងជាសាធារណៈ ដល់សហគមន៍មូលដ្ឋានដើម្បីអោយចូលរួមក្នុងការអភិវឌ្ឍ និង អភិវឌ្ឍធនធានព្រៃឈើ។
- ការស្រាវជ្រាវ នឹង អភិវឌ្ឍគឺ សម្រាប់រៀបចំប្រព័ន្ធទិន្នន័យពត៌មានភូមិសាស្ត្រ រៀបចំការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវចំរុះ ការគ្រប់គ្រងតំបន់លំហែកំសាន្ត និង ទេសចរណ៍ធម្មជាតិព្រមទាំងសហគមន៍មូលដ្ឋាននៅក្នុងតំបន់ឲ្យមានប្រសិទ្ធិភាព។

## ២.៦ ដំណើការនៃការគ្រប់គ្រងធនធានព្រៃឈើតំបន់ចម្ការពូជឈើគ្រញូង

### ២.៦.១ សកម្មភាពនៃការគ្រប់គ្រងព្រៃឈើរបស់សង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្លារគ្រាំ

### ក. ការងារក្នុងឆ្នាំ២០១៤

នៅក្នុងឆ្នាំ២០១៤ នេះដែរ សង្កាត់រដ្ឋបាលព្រៃឈើបានធ្វើផ្លូវចូលទៅក្នុងចម្ការពូជឈើគ្រញូងដែលមានខ្នងលើ៤.៥ម៉ែត្រ បាត៥.៥ម៉ែត្រ ចំណែកកំពស់វិញ ០.៦០ម៉ែត្រ, ប្រវែងប្រមាណ ២៧០០ម៉ែត្រ និងដាក់លូចំនួន ០៥កន្លែង។ លើសពីនេះបានជីកស្រះទឹកទំហំ ២០ម x៥០មx៣.៥ម បានមួយកន្លែង។ ហើយក៏បានធ្វើការសាងសង់ស្ពានប៉េតុងនៅអូរចំបក់បណ្តោយ ៤ម ទទឹង៣.៥ម ០១កន្លែង និងធ្វើការដាំដើមឈើនៅតាមដងផ្លូវនូវប្រភេទ កូនឈើគ្រញូងចំនួន ៨១១៨ដើម កូនឈើបេងចំនួន ៣២៥២ដើម និងកូនឈើទាលចំនួន ៦៣០ដើម។

**ខ. ការងារក្នុងឆ្នាំ២០១៥**

នៅក្នុងឆ្នាំ២០១៥ នេះដែរ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្វាវក្រៅ បានដាំដើមឈើបន្ថែមទៀតនូវប្រភេទកូនឈើគ្រញូង និងកូនឈើនាងនួន នឹងបានទទួលមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ ភ្ញៀវជាតិនិងអន្តរជាតិចូលរួមដាំកូនឈើ ក្នុងសួនអនុស្សាវរីយ៍ផងដែរ។ ក្រៅពីនេះ ក៏បានធ្វើការសាងសង់ផ្ទះបាយ ៩មx៤ម ចំនួន០១ខ្នងប្រកស័ង្កសីបន្ថែមទៀតក្នុងចម្ការពូជឈើគ្រញូង។

**គ. ការងារក្នុងឆ្នាំ២០១៦**

ចំពោះសកម្មភាពអនុវត្តន៍ការងារ ក្នុងឆ្នាំ២០១៦ មានដូចជា ការទទួលស្វាគមន៍នូវការគណៈប្រតិភូរាជរដ្ឋាភិបាល មន្ត្រីនិស្សិត ភ្ញៀវជាតិ និងអន្តរជាតិបានចូលរួមដាំកូនឈើគ្រញូងក្នុងសួនអនុស្សាវរីយថៃចម្ការពូជឈើគ្រញូង។ លើសពីនេះទៅទៀតបានជីកស្រះទឹកសម្រាប់ទុកឲ្យសត្វព្រៃក្នុងចម្ការពូជឈើគ្រញូងដែលមានទំហំ ៣៥មx៥៥ម មានជម្រៅ០៤ម៉ែត្រ និងធ្វើការជីកទឹកស្រះទឹកមួយកន្លែងទៀតនៅត្រង់ចំណុចឆ្អើរមាស មានអង្កត់ផ្ចិត ២៧ម៉ែត្រ ជម្រៅ០៤ម៉ែត្រ មានការកោះចំកណ្តាល ១២០មX១២០ម។ ក្រៅពីនេះក៏មានការសាងសង់បន្ទប់ទឹកចំនួន០៣ស្មើ ៧បន្ទប់ធ្វើអំពីថ្ម ដំបូលប្រក់ស័ង្កសី និងសាងសង់រោងសម្រាប់ទទួលភ្ញៀវជាតិ និងអន្តរជាតិដោយក្រាលថ្មប៉េតុង ដំបូលប្រកកៅស៊ូមានទំហំ ៤មX១៦ម។ ហើយក្នុងឆ្នាំដដែលនេះដែរ គេបានធ្វើការដាក់ស៊ីទែនទឹក០១កន្លែង ទម្ងន់ផ្ទុក៥០០០លីត្រ គឺជាធុងជ័រផងដែរ។

**ឃ. ការងារក្នុងឆ្នាំ២០១៧**

ទាក់ទងនឹងសកម្មភាពដែល អនុវត្តន៍ក្នុងឆ្នាំ២០១៧ គឺមានដូចជា គណៈប្រតិភូជាតិ គណៈប្រតិភូអន្តរជាតិ មន្ត្រី សិស្សានុសិស្ស ភ្ញៀវជាតិនិងអន្តរជាតិ ដូចជាក្រុមការងារទូរទស្សន៍ ចូលរួមដាំកូនឈើ គ្រញូង និងកូនឈើប្រភេទដ៏ទៃទៀតក្នុងចម្ការ។ ក្រៅពីនេះទៀត មានសកម្មភាពសាងសង់នូវរោងជូនកម្មករស្នាក់នៅក្នុងចម្ការពូជចំនួន០២កន្លែងធ្វើអំពីឈើដំបូលប្រក់ស្បូវផងដែរ។

**ង. ការងារក្នុងឆ្នាំ២០១៨**

ខណ្ឌរដ្ឋបាលព្រៃឈើបានរៀបចំនិងថែទាំចម្ការពូជឈើគ្រញូង និងផ្ទង់ ចំនួន ០៣កន្លែង នៅឃុំ ឃុនរាម ស្រុកបន្ទាយស្រី ហើយការអនុវត្តសកម្មភាពការងារសំខាន់ៗរួមមាន៖

- បន្តចាត់វិធានការទប់ស្កាត់បទល្មើសព្រៃឈើក្នុងដែនចម្ការពូជ និងល្បាតជាប្រចាំ ។
- ថែទាំ និងកាត់ស្មៅកូនឈើនៅសួនអនុស្សាវរីយ និងតាមដងផ្លូវចូលចម្ការពូជ ។
- កាត់ត្រាយផ្លូវភ្លើងទទឹង ០៥ម៉ែត្របណ្តោយ ៦.០០០ម៉ែត្រជុំវិញចម្ការពូជឈើគ្រញូងទំហំ ១.៨៨៨ហិកតា។

- បេះប្រមូលគ្រាប់ពូជនាងនួន ៣៥គីឡូក្រាម(ទាំងសំបក)និងគ្រាប់គ្រញូងសំអាតរួច០៥គីឡូក្រាម។
- ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ បានទទួល និងដឹកនាំនិស្សិតសកលវិទ្យាល័យភូមិន្ទចំការដូង ចំនួន១៥ នាក់ ស្រី ០៥នាក់ ចុះធ្វើកម្មសិក្សាគម្រោងស្វែងយល់ពីប្រភពគ្រាប់ពូជនៅចម្ការពូជ ។
- ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ លោកនាយខណ្ឌ បាននាំភ្ញៀវជនជាតិជប៉ុនចូលទស្សនាចម្ការ ពូជឈើគ្រញូង និងថ្នាលបណ្តុះកូនឈើ ។
- ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ ទទួលប្រតិភូដឹកនាំដោយលោក ឈុន ឌីលុច អនុប្រធាននាយកដ្ឋាន អភិវឌ្ឍន៍ឧស្សាហាកម្ម និងពាណិជ្ជកម្មព្រៃឈើ មានសមាជិក ០៦នាក់ ទស្សនកិច្ចចម្ការពូជឈើ គ្រញូង។
- ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ ទទួលប្រតិភូជាតិ និងអន្តរជាតិ ដឹកនាំដោយលោក ខៀវ សំណាង តំណាងក្រុមការងាររបស់គម្រោង BCCP របស់រដ្ឋបាលព្រៃឈើខេត្តកោះកុង និងមណ្ឌលគីរី មានសមាជិក ៥៣នាក់ ស្រី១០នាក់ទស្សនកិច្ចដកបទពិសោធន៍ពីចម្ការពូជ គ្រញូងនិងសហគមន៍ព្រៃឈើក្បាលទឹក(ត្បែងលិច)។
- ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ទទួលប្រតិភូជាតិ និងអន្តរជាតិ អង្គការស្បៀង និងកសិកម្មនៃ សហប្រជាជាតិ(FAO) និងអង្គការ IUNCN មានសមាជិក ៥0នាក់ (ជនបរទេស ១០នាក់) ទស្សនកិច្ចដកបទពិសោធន៍ពីប្រវត្តិចម្ការឈើពូជគ្រញូង ។
- ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ ទទួលប្រតិភូជាតិ និងអន្តរជាតិ ដឹកនាំដោយលោកបណ្ឌិត សុខ ហេង ចុះទស្សនកិច្ចសិក្សាសក្តានុពលតំបន់ទេសចរណ៍ធម្មជាតិក្នុងចម្ការពូជ មាន សមាជិក ០៩នាក់ ជនបរទេស ០៤នាក់។
- ចុះពន្លត់ភ្លើងឆេះព្រៃក្បែរព្រំប្រទល់ចម្ការពូជចំនួន០៣លើក ដោយប្រើប្រាស់កំលាំងចំនួន ១០នាក់ និងម៉ូតូពន្លត់អគ្គីភ័យចំនួន ០១ គ្រឿង ។
- ថ្ងៃទី ០៨ ខែមីនា ឆ្នាំ២០១៨ ទទួលឯកឧត្តម ពិន ប្រាកដ អភិបាលរងខេត្តសៀមរាបចូលទស្សនា ចម្ការពូជគ្រញូង និងបានដាំកូនឈើចំនួន០៣ដើម ក្នុងសួនអនុស្សាវរីយ ។
- ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្វារក្រៅបានទទួលនិង ជូនភ្ញៀវជន ជាតិចិនចំនួន ០៦នាក់ ចុះសិក្សាពីសក្តានុពលតំបន់ទេសចរធម្មជាតិក្នុងចម្ការពូជឈើគ្រញូង។
- ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៨ ទទួលឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ចូលទស្សនាចម្ការពូជឈើគ្រញូង និងបានដាំកូនឈើចំនួន០៣ដើម ក្នុងសួន អនុស្សាវរីយ ។

- ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៨ សហការណ៍ជាមួយមន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និងជាមួយអង្គការសត្វព្រៃ ACCB ក្បាលស្ពាន និងឆ្មាំចម្ការពូជឈើបានដើរបំពាក់ CAMERA ថតសត្វព្រៃបានចំនួន ១១ CAMERAS ក្នុងចម្ការពូជឈើគ្រញូង។
- ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨ ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប និងផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រីជូនមន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និងមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះពិនិត្យប្រពន្ធ័ក្រវ៉ាត់ព្រំចម្ការពូជឈើគ្រញូង និងចម្ការឈើដាំឆ្នាំ២០១២ ២០១៣ និង ២០១៦។
- ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ទទួលប្រតិភូសវនកម្មក្រសួងកសិកម្មចូលទស្សនាចម្ការពូជ និងបានដាំកូនគ្រញូងចំនួន០៥ដើម ក្នុងសួនអនុស្សាវរីយ៍ ។
- ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ទទួលក្រុមនិសិត្យសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង ចំនួន២៨នាក់ ចុះទស្សនកិច្ច និងធ្វើកម្មសិក្សាក្នុងចម្ការពូជឈើគ្រញូង ។
- ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ទទួលសត្វពស់ថ្លាន់ចំនួន០១ក្បាល ទម្ងន់៥,៥គីឡូក្រាម ពីលោក ចាន់ ធឿន ជាប្រជាពលរដ្ឋនៅភូមិស្រែណូយ ដោះលែងក្នុងចម្ការពូជ ។
- ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅជូនភ្ញៀវមកពីប្រទេសកូរ៉េដើម្បី ចូលស្រាវជ្រាវសិក្សា និងប្រមូលសំណាកសត្វល្អិតក្នុងចម្ការពូជឈើគ្រញូង និងជូនអង្គការACCBចុះឆែក និងពិនិត្យ Camera តាមដានសត្វព្រៃ។
- ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៨ ផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រីចូលរួមជាមួយសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ចុះពិនិត្យទីតាំងដីដាំឈើ និងពិនិត្យទីតាំងទឹកលិចដែលបណ្តាលមកពីការកាយប្រពន្ធ័ព្រំបិតផ្លូវទឹកធ្វើឲ្យដើមឈើងាប់ក្នុងចម្ការពូជឈើគ្រញូង និងបានជីក និងចាក់ដីសំរាប់ធ្វើថ្នាលបណ្តុះកូនឈើនៅក្នុងចម្ការពូជគ្រញូងដែលមានទំហំទទឹង ១៨ម៉ែត្រ បណ្តោយ ៤០ម៉ែត្រ កំពស់០,៧ម៉ែត្របានសំរេចរួច។
- ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ និងនាយកដ្ឋានឧស្សាហកម្ម ព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ បានចុះត្រួតពិនិត្យការភ្ជួរដីដោយត្រាក់ទ័រសំរាប់ដាំកូនឈើ ៤,៨ហិកតា នៅក្នុងចម្ការពូជឈើគ្រញូងត្រង់ចំណុច UTM (400055-1521495)។
- បានទទួលប្រតិភូចំនួន០៧ នាក់ (បរទេស០១នាក់) ដើម្បីពិភាក្សាតំបន់លំហែកាយធម្មជាតិក្នុងចម្ការពូជគ្រញូង ។

- បានទទួលប្រតិភូអាស៊ានចំនួន១៧នាក់ (០៦ប្រទេស) ចូលទស្សនកិច្ចសិក្សាក្នុងចម្ការពូជឈើគ្រញូង ។
- សហការណ៍ជាមួយគម្រោងលំហែកាយធម្មជាតិដាំកូនឈើក្នុងចម្ការពូជចំនួន១៣.៦០០ដើម ។
- បេះប្រមូលគ្រាប់គ្រញូងបានចំនួន ២១១គីឡូក្រាម (ទាំងសំបក) ។
- ជូនក្រុមអង្គការ ACCB ចុះពិនិត្យ និងប្តូរទីតាំង Cameras សត្វព្រៃក្នុងចម្ការពូជ ។
- សហការណ៍ជាមួយគម្រោងលំហែកាយធម្មជាតិរៀបចំថ្នាលបណ្តុះកូនឈើក្នុងចម្ការពូជ ។
- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ទទួលសត្វពស់ថ្លាន់ ០១ក្បាល ទម្ងន់១០គីឡូក្រាម ពីប្រជាពលរដ្ឋឈ្មោះ ធរ សារឿន យកទៅប្រលែងនៅក្នុងព្រៃពូជ ។
- សហការណ៍ជាមួយគម្រោងធ្វើឡូត៍ពិសោធន៍ អនុវត្តបានចំនួន១០ឡូត៍ រួមមានៈ ព្រៃស្រោងចំនួន០៣ឡូត៍ស្មើនឹង ៧៣៨ដើម ព្រៃពាក់កណ្តាលស្រោងចំនួន០២ឡូត៍ស្មើនឹង ៤១០ដើម និងព្រៃល្បោះចំនួន ៥ឡូត៍ស្មើនឹង ៦៤៦ដើម ។

### ២.៦.២ ការអនុវត្តន៍ការងារផ្សេងៗក្រៅពីកម្មវិធីព្រៃឈើជាតិ

ក្រៅពីអនុវត្តន៍ការងាររបស់ខ្លួនអោយស្របតាមកម្មវិធីព្រៃឈើជាតិ នៅកំឡុងឆ្នាំ២០១៨ កន្លងទៅសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅក៏បានចុះអនុវត្តន៍សកម្មភាពការងារបន្ថែមទៀតនៅតាមតំបន់ផ្សេងៗ។

នៅក្នុងខែកមរា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានចូលរួមជាសកម្មភាពដូចជា សម្អាតដីលុបពូនគល់ឈើពីចំនុចភ្លើងស្តុបស្តាតចាស់ដល់មន្ទីរពេទ្យគន្ធបុប្ផាកុមារអង្គរ។ ចូលរួមមិទ្ទិញអបអរខួបអនុស្សាវរីយលើកទី៣៩ ទិវាជ័យជំនះ៧មករាឆ្នាំ១៩៧៩ នៅសាលាស្រុកស្វាយលើ។ ចំណែកឯនៅក្នុងខែកុម្ភៈឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានអនុវត្តសកម្មភាពដូចជា ចូលរួមប្រជុំគណៈបញ្ជាការឯកភាពស្រុកស្វាយលើ ស្តីពីការរៀបចំសន្តិសុខសណ្តាប់ធ្នាប់ ដើម្បីបោះឆ្នោតជ្រើសរើសសមាជិកសភា និងនៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ចូលរួមប្រជុំគណៈកម្មការបច្ចេកទេស ពិនិត្យ និងកែសម្រួលផែនការវិនិយោគបីឆ្នាំរំកិល២០១៨-២០២០ របស់ស្រុកស្វាយលើ និងប្រជុំគណៈបញ្ជាការឯកភាពស្រុកប្រចាំខែកុម្ភៈ ។ ចំពោះនៅក្នុង ខែមេសា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ បានចូលរួមប្រជុំសម្របសម្រួលបច្ចេកទេសផែនការបីឆ្នាំរំកិល ២០១៨ ២០២០ ស្រុកស្វាយលើ និងចូលរួមប្រជុំគណៈកម្មាការសម្របសម្រួលបច្ចេកទេសផែនការវិនិយោគបីឆ្នាំរំកិលរបស់ស្រុកស្វាយលើ។ រីឯនៅខែឧសភា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ បានជូនក្រុមការងារថ្នាក់ខេត្តចុះពិនិត្យដី អន្លង់ត្បាល់ភ្នំ១០០ និង

ជ្រោង ក្នុងភូមិកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ។ បានក្រីមែកឈើចំណុចព្រះអង្គ ចេកព្រះអង្គចម។ បានចុះពិនិត្យដីរបស់ប្រជាពលរដ្ឋសុំ កាយដំបូកដើម្បីដាំដំណាំជាមួយក្រុមការងារថ្នាក់ស្រុក នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកស្វាយលើ និងបានចូលរួមជាមួយក្រុមការងារថ្នាក់ ខេត្តចុះពិនិត្យដីដែលប្រជាពលរដ្ឋចំនួន៩៥គ្រួសារ តវ៉ា នៅចម្ការឈើដាំ២០១៤។ សកម្មភាពការងារនៅខែមិថុនា ឆ្នាំ ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានប្រគល់ និងចូលរួមដាំកូនឈើចំនួន ២១០ដើម (គ្រញូង២០០ដើម,ធ្នង់១០ដើម) ជាមួយក្រុមការងារចុះជួយពង្រឹងបក្សឃុំកន្ទួត លោកនាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស សាលាបឋមសិក្សាអូរតាកុក។ បានចូលរួមដាំកូនឈើនៅទីធ្លាវត្ត និងសាលាបឋមសិក្សាថ្មីកជ្រុំ(កូនក្រញូង=៤០០ ដើម)។ ម្យ៉ាងវិញទៀតនៅខែកក្កដា ឆ្នាំ២០១៨ មន្ត្រីសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ក៏បានចូលរួមសម្ពោធដាក់អោយប្រើប្រាស់អគារសន្តេវាសិ-ដ្ឋានអនុវិទ្យាល័យស្វាយលើ។ ចំពោះខែសីហា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ បានចូលរួមប្រជុំ និងធ្វើបទសម្ភាសវាយតម្លៃក្រោយបញ្ចប់គម្រោងស្តារព្រៃឈើ និងការបង្កើតបរិក្ខាស្រាវជ្រាវលើវិស័យព្រៃឈើក្នុងប្រទេសកម្ពុជា-កូរ៉េ នៅសាលប្រជុំខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប។ នៅខែកញ្ញា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានធ្វើសកម្មភាពចូលរួមជំនុំជម្រះដំណើរឿងដឹកជញ្ជូនផល អនុផលព្រៃឈើ នៅសាលាដំបូងខេត្តសៀមរាប។ នៅខែតុលា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ បានចូលរួមជំនុំជម្រះដំណើរឿងដឹកជញ្ជូនផល អនុផលព្រៃឈើ នៅសាលាដំបូងខេត្តសៀមរាប។ ចូលរួមប្រជុំចុះបញ្ជីដីធ្លូវ និងនីតិវិធីនៃការចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋស្រុកស្វាយលើ ។ ចុងក្រោយនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ បានចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងគ្រាប់ពូជ និងស្តារព្រៃឈើឡើងវិញ នៅសណ្ឋាគារអង្គរប៉ារ៉ាឌីសៀមរាប។ ចូលរួមសិក្ខាសាលាកម្មវិធីវិនិយោគ នៅស្រុកស្វាយលើ។ ចូលរួមគម្រោងជម្រុញការស្តារព្រៃឈើនៅកម្ពុជា និងវៀតណាម។ ចូលរួមសិក្ខាសាលាកម្មវិធីវិនិយោគ នៅស្រុកបន្ទាយស្រី និងបានចូលរួមគម្រោងធ្វើឡូត៍ពិសោធន៍នៅ ចម្ការពូជឈើគ្រញូង ។

### ២.៦.៣ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើ

#### ក. ការត្រួតពិនិត្យ

ចាប់តាំងពីឆ្នាំ ២០០២ តំបន់ចម្ការពូជឈើគ្រញូងបានដាក់កម្លាំងយាមល្បាត ចំនួន០២នាក់។ ចំនួន៤នាក់នៅឆ្នាំ ២០០៦ រហូតដល់បច្ចុប្បន្ននេះ ចម្ការពូជបានពង្រីកផ្ទៃដីរហូតដល់ផ្ទៃដីសរុប ១៨៨៨ហិចតា ពេលនោះកម្លាំងយោធាយាមល្បាតបានបន្ថែមរហូតដល់១៧នាក់ ដែលមានកម្មករបណ្តែតចំនួន ១០នាក់ ក្នុងចម្ការពូជឈើគ្រញូង ដើម្បីធ្វើការគ្រប់គ្រងនិងថែរក្សាសុវត្ថិភាពនិង

អភិវឌ្ឍន៍ចម្ការពូជឈើគ្រញូង។ ចំពោះការយាមល្បាតក្នុងចម្ការពូជឈើគ្រញូងក្រុមឆ្មាំការពារធ្វើការពារបានធ្វើការបែងចែកក្រុមតូចៗ ដែលមានចំនួន០៧ក្រុម ដែលមានទីស្នាក់ការធំនៅចំកណ្ដាលព្រៃចម្ការពូជ ដែលមានធ្វើការល្បាតទាំងយប់ ទាំងថ្ងៃ ទៅតាមទិសដៅនីមួយៗ។

ចំពោះវិធានការការពារភ្លើង ដែលកើតឡើង ដោយមានណែនាំពីថ្នាក់ដឹកនាំ ផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី សហការជាមួយ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានរៀបចំ ប្រឡាយមួយខ្សែសម្រាប់ជាប្រព័ន្ធការពារដែលមានរាងជាប៉ារ៉ាបូល ទទឹង១ម និងជំរៅ១ម ដែលមានប្រវែងសរុបរហូត ដល់១២.៧០០ម។ គោលចំណងនៃការបង្កើតប្រព័ន្ធនេះគឺ ការពារសម្រាប់ការទន្ទ្រានចូលយកដីព្រៃពីប្រជាជន និងផ្លូវសម្រាប់ការភ្លើងដែលឆ្លងចូលទៅក្នុងព្រៃចម្ការពូជ។ ចំពោះវិធានការផ្សេងៗទៀត មានដូចជា ធ្វើការសំអាតស្មៅ នៅក្នុងអំឡុងខែវិច្ឆិការ និងខែធ្នូ ដោយប្រើភ្លើងធ្វើការដុតសំអាតតាមប្រព័ន្ធ និងតាមព្រៃល្បោះ ព្រៃពាក់កណ្ដាលស្រោង គោលបំណងគឺទប់ស្កាត់កុំឲ្យមានបាតុភូត ភ្លើងព្រៃដែលកើតដោយចៃដន្យ។ ទោះជាយ៉ាងណាភ្លើងអាច ឲ្យយើងធ្វើការគ្រប់គ្រងបានដោយបង្ការដោយមិនបង្កឆេះទៅផ្នែកដ៏ទៃទៀតនៃព្រៃ ដោយប្រើប្រាស់ឧបករណ៍ផ្សេងៗ ជាពិសេស ម៉ូតូដែលបំពាក់ម៉ាស៊ីនបាញ់ទឹក និងអមដោយកម្លាំងមនុស្សផងដែរ សម្រាប់ជួយពន្លត់។

### ខ. ការបង្ក្រាបបទល្មើសក្នុងចម្ការគ្រាប់ពូជគ្រញូង

ជារឿយៗចម្ការគ្រាប់ពូជតែងតែមាន ការលួចកាប់ដើមពូជគ្រញូង ជាញឹកញយពីសំណាក់ជនល្មើសដែលមកពីខាងក្រៅ តំបន់ចម្ការគ្រាប់ពូជ ដោយដើមពូជគ្រញូងមានតម្លៃថ្លៃព្រោះនៅពេលនោះ កងកម្លាំងដែលធ្វើការយាមល្បាតនៅ មានកម្រិតនៅឡើយ។ ទោះជាយ៉ាងណា បទល្មើសតែងតែធ្វើ ការបង្ក្រាបយ៉ាងសកម្មផងដែរ ដែលរហូតមានឃាត់ខ្លួនជនល្មើស និងវត្ថុតាងដែលជនល្មើសបានធ្វើបានការកាប់បំផ្លាញ។ ដូចនេះរដ្ឋបាលបង្កើនឆ្មាំ ការពារបន្ថែមពីលើកម្លាំងចាស់ ដែលមានស្រាប់ ហើយធ្វើការល្បាត និងយាមកាមយ៉ាងតឹងរឹងបំផុតមិនឲ្យជនណាម្នាក់ចូលទៅក្នុងចម្ការពូជដោយគ្មានការអនុញ្ញាតឡើយ ពីថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ។

ទាក់ទិននឹងការបង្ក្រាបបទល្មើសនៅឆ្នាំ២០១៨ របស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានបង្ក្រាបបានបទល្មើសព្រៃឈើ ដីព្រៃឈើ និងសត្វព្រៃនៅក្នុងចម្ការ និងសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ។ ក្នុងនោះផងដែរបានវត្ថុតាងល្មើសមានដូចជា ដីព្រៃ ឈើអារលេខ២ ក្ដាន់ញែង អេស្កាវ៉ាទ័រ រថយន្ត ម៉ូតូ រណាយន្ត និងជនល្មើសផងដែរ។

រូបភាព២.២ ៖ សកម្មភាពបង្ក្រាបបទល្មើស



តារាង ២.៣៖ វត្ថុតាងបទល្មើសគ្រប់ប្រភេទដែលបានចាប់ឃាត់របស់សង្កាត់រដ្ឋបាលព្រៃឈើ

| ឈ្មោះជនល្មើស | វត្ថុតាងល្មើស | | ថ្ងៃខែឆ្នាំចាប់ឃាត់ | អ្នកថែរក្សា | កន្លែងថែរក្សា |
|---|---|---|---|---|---|
| សុខ ណាង | ប្រភេទឈើលេខ២ | រថយន្ត ០១ | ២០.០១.១០២៨ | សេង លន | សរព.កន្ទួតខ្នារក្រៅ |
| ឈុំ នឿន | ប្រភេទឈើលេខ២ | រថយន្ត ០១ | ២០.០១.២០១៨ | សេង លន | សរព.កន្ទួតខ្នារក្រៅ |
| សឿន អូន | ប្រភេទឈើលេខ២ | រថយន្ត ០១ | ០៧.០៨.២០១៨ | សេង លន | សរព.កន្ទួតខ្នារក្រៅ |
| អញ្ញាតជន | ដីព្រៃ | | ២៦.០៣.២០១៨ | សេង លន | សរព.កន្ទួតខ្នារក្រៅ |
| ស៊ឹងវត្ថា,នាងសុភាព,ព្រែកភក្តី | ដីព្រៃ | | ១៣.០៧.២០១៨ | ហាង្ស ជំនិតរិទ្ធិ | សរព.កន្ទួតខ្នារក្រៅ |

| | | | | | |
|---|---|---|---|---|---|
| អញ្ញាតជន | ដីព្រៃ | | ១៩.០៩.២០១៨ | សេង លន | សរព.កន្ទួតខ្នារក្រៅ |
| ដែន ឌឿន,សាម៉ុន ខាន់ | ក្តាន់ញ៉ែង ០៥ក្បាល | ម៉ូតូ | ០៦.១០.២០១៨ | សេង លន | សរព.កន្ទួតខ្នារក្រៅ |

ប្រភព៖ របាយការណ៍បូកសរុបការងារវិស័យព្រៃឈើ ឆ្នាំ២០១៨

### ២.៦.៤ ផលប្រយោជន៍ដែលអាចរំពឹងទទួលបានពីការគ្រប់គ្រងព្រៃឈើ

ការគ្រប់គ្រងអភិរក្សតែងតែផ្សារភ្ជាប់មកជាមួយសេចក្តី សង្ឃឹមថានឹងទទួលបានប្រយោជន៍ពីការគ្រប់គ្រងនោះក៏មិនខុសគ្នាដែរ ការគ្រប់គ្រងព្រៃឈើរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ស្រុកបន្ទាយស្រី ខេត្តសៀមរាប អាចនឹងទទួលបានផលប្រយោជន៍មួយចំនួនដូចខាងក្រោមនេះ៖

- មានធនធានព្រៃឈើនិងសត្វព្រៃក្នុងការផ្គត់ផ្គង់តម្រូវការប្រើប្រាស់បានយូរអង្វែងរហូតដល់កូនចៅជំនាន់ក្រោយ
- មានការកើនឡើងនូវធនធានព្រៃឈើ សត្វព្រៃ និងធនធានជីវៈចម្រុះនៅក្នុងតំបន់
- រក្សាបានលំនឹងធម្មជាតិ
- ការប្រមូលផលគ្រាប់ពូជ កាន់តែមានការកើតឡើង
- ទទួលបានលំនឹងធម្មជាតិ
- ការប្រមូលផលគ្រាប់ពូជកាន់តែមានការកើនឡើង
- ទទួលបានចំណូលដល់រដ្ឋតាមរយៈការបង្កើតតំបន់ទេសចរណ៍
- ជាប្រយោជន៍ដល់ការសិក្សាអប់រំ និងការស្រាវជ្រាវវិទ្យាសាស្ត្រ
- ទាក់ទាញចំណាប់អារម្មណ៍ម្ចាស់ជំនួយក្នុងស្រុក និងក្រៅស្រុកនៅលើដំណើរការគ្រប់គ្រងចម្ការពូជឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ទៀត។

### ២.៦.៥ វិធានការ និងទិសដៅអនុវត្តន៍របស់តំបន់ចម្ការពូជក្រញូង

- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋាន
- បន្តអនុវត្តបទបញ្ជាលេខ០១បប ,០២បប និងសារាចរលេខ០២របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ដីព្រៃឈើ
- បន្តអនុវត្តតាមសេចក្តីជូនដំណឹងលទ្ធផលការប្រជុំបូកសរុបការងារវិស័យព្រៃឈើឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តរបស់រដ្ឋបាលព្រៃឈើ

- ជំរុញការងារបណ្តុះកូនឈើ ដាំឈើជាចម្ការ ការដាំឈើជាដៃគូជាមួយរដ្ឋបាលព្រៃឈើជាពិសេសការបោះបង្គោលព្រំប្រទល់ដែនព្រៃឈើ
- ចុះកិច្ចព្រមព្រៀង និងរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍
- រៀបចំសូនអនុស្សាវរីយ៍ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធចម្ការពូជឈើគ្រញូង។

## ២.៧ ស្ថាប័ន និងប្រជាពលរដ្ឋដែលចូលរួមក្នុងគ្រប់គ្រងចម្ការពូជឈើគ្រញូង

### ២.៧.១ ការចូលរួមពីអង្គការ និងស្ថាប័នពាក់ព័ន្ធ

ការគ្រប់គ្រងធនធានព្រៃឈើ នៅក្នុងចម្ការគ្រាប់ពូជគ្រញូង ដោយមានការចូលរួមពីអង្គការ និងស្ថាប័នពាក់ព័ន្ធមួយចំនួនដែលធ្វើការសហការណ៍ជាមួយសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅដោយផ្ទាល់។ ស្ថាប័នទាំងនោះរួមមានដូចជា អាជ្ញាធរខេត្ត ឃុំ ភូមិ អាជ្ញាធរដែនដី និងអង្គការក្រៅរដ្ឋបាលមួយចំនួនទៀតផងដែរ។ រាល់បទល្មើសព្រៃឈើដែលកើតមានឡើងនៅក្នុងចម្ការពូជឈើគ្រញូង គឺត្រូវបានសហការណ៍គ្នាដើម្បីចុះបង្ក្រាបបទល្មើសទាំងនេះ។

### ២.៧.២ ការចូលរួមពីប្រជាជនមូលដ្ឋាន

ប្រជាជន គឺជាកត្តាសំខាន់បំផុតក្នុងការគ្រប់គ្រង និងអភិរក្សព្រៃឈើ និងដាំដុះព្រៃឈើឡើងវិញនៅក្នុងតំបន់ជួយទប់ស្កាត់បទល្មើសព្រៃឈើដែលកើតមានឡើងក្នុងតំបន់។ ប្រជាជនមូលដ្ឋាន បានចូលរួមចំណែកក្នុងការពារធនធានជីវៈចម្រុះយ៉ាងសកម្ម ហើយរាល់បទល្មើសព្រៃឈើដែលបានកើតឡើង និងបានជួបប្រទះ ពួកគាត់តែងតែរាយការណ៍ និងជូនដំណឹងដល់អាជ្ញាធរដែនដី និងមន្ត្រីរដ្ឋបាលព្រៃឈើដើម្បីអនុវត្តទៅតាមនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីព្រៃឈើ។ ប្រជាជនភាគច្រើនយល់ឃើញថាការការពារអភិរក្សធនធានព្រៃឈើ គឺមានសារៈសំខាន់ ហើយនៅពេលដែលពួកគាត់ទៅស្វែងរកធនធាន ក្នុងតំបន់ម្តងៗ ពួកគាត់តែងតែគិតគូរពីបញ្ហាថែរក្សាទុកសម្រាប់ជំនាន់ក្រោយ។

## ២.៨ ភាពជោគជ័យ

ក្រោយពីធ្វើការគ្រប់គ្រងក្នុងចម្ការគ្រញូងជាច្រើនឆ្នាំកន្លងមក របស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានធ្វើឲ្យចម្ការពូជមានការរីកចម្រើនទៅមុខ ដោយមានការលូតលាស់នូវប្រភេទឈើគ្រប់ប្រភេទក្នុងចម្ការពូជឈើគ្រញូង ជាពិសេសនោះគឺប្រភេទឈើប្រណិត ដូចជា គ្រញូង បេង នាងនួនជាដើម។ លើសពីនេះទៅទៀតនោះ ចម្ការពូជគ្រញូងអាចទាក់ទាញនូវសត្វព្រៃគ្រប់ប្រភេទចូលមកតាំងទីជម្រកក្នុងបរិវេណតំបន់នេះផងដែរ។

លើសពីនេះទៅទៀតនោះក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ដែលមានសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅផងដែរ បានធ្វើការប្រមូលគ្រាប់ពូជគ្រប់ប្រភេទនៅក្នុងចម្ការដើម្បីធ្វើចែកចាយបន្តដល់តំបន់ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាសម្រាប់ធ្វើការបណ្តុះ និងដាំផងដែរ។ ជារៀងរាល់ឆ្នាំសង្កាត់រដ្ឋបាលកន្ទួតខ្នារក្រៅតែងតែធ្វើការអនុវត្តន៍ផែនការយុទ្ធសាស្ត្ររបស់ថ្នាក់លើបានចងក្រងនៅក្នុងចម្ការ លើសពីនេះទៅទៀតសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានធ្វើផែនការយុទ្ធសាស្ត្រ និងទិសដៅអនុវត្តន៍បន្តរបស់ខ្លួន ដើម្បីធ្វើការអនុវត្តន៍បន្ថែមពីលើនេះផងដែរ។ ភាពជោគជ័យ ដែលបានធ្វើឲ្យចម្ការគ្រាប់គ្រញូងមានដំណើរទៅមុខយ៉ាងលូនក៏ដោយសារតែសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានធ្វើការគោរពគោលការណ៍របស់ក្រសួង និងអនុវត្តបញ្ជារបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនបានយ៉ាងល្អ។ ការអនុវត្តន៍បានយ៉ាងល្អនៃបញ្ជាទាំងអស់នេះបានធ្វើឲ្យមន្ត្រី និងឆ្មាំដើរល្បាតគោរពនូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដោយគ្មានការកិបកេងនូវផលប្រយោជន៍ផ្ទាល់ខ្លួន។ ជារួម មន្ត្រី និងឆ្មាំដើរល្បាតមានភាពស្មោះត្រង់ និងខិតខំព្យាមយាមក្នុងការគ្រប់គ្រងចម្ការពូជឈើគ្រញូងនេះ។

ក្រៅពីនេះទៅទៀត សង្កាត់រដ្ឋបាលព្រៃឈើបានចូលរួមសហការណ៍ជាមួយអង្គការមួយចំនួនក្នុងការរៀបចំគម្រោងអភិរក្ស និងអភិវឌ្ឍន៍ចម្ការពូជឈើគ្រញូងតាមរយៈការផ្តល់ជំនួយថវិការ សម្ភារៈ អ្នកជំនាញ និងការបណ្តុះបណ្តាលបន្ថែមដល់មន្ត្រី ក្នុងការគ្រប់គ្រងឲ្យបានកាន់តែប្រសើរ និងទទួលបានជោគជ័យ។

## ២.៩ បញ្ហាដែលជួបប្រទះក្នុងតំបន់ចម្ការពូជឈើគ្រញូង

ទន្ទឹមនឹងភាពជោគជ័យការគ្រប់គ្រងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ក៏បានជួបបញ្ហាប្រឈមសំខាន់ៗដែលមានការព្រួយបារម្ភជាខ្លាំងចំពោះតំបន់ចម្ការគ្រាប់ពូជដែលទាមទារឲ្យមានការយកចិត្តទុកដាក់ជាខ្លាំងពីថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើថ្នាក់ជាតិ។

បញ្ហាទាក់ទងនឹងការលបលួចអន្ទាក់សត្វរបស់ជនខិលខូច នៅក្បែរតំបន់ប្រភពគ្រាប់ពូជដែលធ្វើមានការប៉ះពាល់ដល់ធនធានសត្វព្រៃដែលរស់នៅក្នុងតំបន់ប្រភពគ្រាប់ពូជដែលជាប្រភេទសត្វកម្រជាដើម ដែលឈានដល់ការបាត់បង់នូវសត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទសត្វព្រៃកម្រ។ ក្រៅពីនេះ មានកើតឡើងនូវភាពអសកម្មមួយចំនួន តែងតែផ្ទុះឡើងម្តងម្កាលដូចជា ការលួចកាប់ព្រៃឈើ ទោះបីជាមានការហាមប្រាមយ៉ាងណា ប្រជាជនមានការសន្សំចិត្តនៅឡើយ។

ចំពោះបញ្ហាបច្ចេកទេស និងសំភារៈមន្ត្រីជំនាញ ឧបករណ៍ដែលមានសម្រាប់ការប្រើប្រាស់ក្នុងការអនុវត្តការងារនៅមានកម្រិត ហើយឧបករណ៍ខ្លះដែលត្រូវការគឺមិនមានឡើយ។ លើសពី

នេះទៅទៀត ក្នុងការគ្រប់គ្រងចម្ការពូជ គឺនៅមានការខ្វះខាតមន្ត្រីជំនាញ និងឆ្មាំដើរល្បាតក្នុងការឈរជើងប្រចាំការក្នុងតំបន់ព្រៃចម្ការពូជផ្ទាល់។

បញ្ហាគ្រោះធម្មជាតិដែលកើតមានដូចជា គ្រោះទឹកជំនន់ និងភ្លើងឆេះព្រៃយោងទៅតាមការសង្កេត និងការសម្ភាសន៍ពីមន្ត្រីរដ្ឋបាលព្រៃឈើបន្ថែមទៀត បានឲ្យដឹងថាផ្លូវទឹក ក្នុងតំបន់ព្រៃពូជមានលក្ខណៈតូចៗ មួយចំនួនបាន គោករាក់អស់ និងមួយចំនួនជាផ្លូវទឹកចាស់ ដែលតម្រូវឲ្យស្តារឡើងវិញ ព្រោះនៅពេលរដូវភ្លៀងម្តងៗ តែងតែមានគ្រោះទឹកជំនន់ ព្រោះដោយសារតែចរន្តផ្លូវទឹកហូរពុំបានលឿន។ ចំពោះភ្លើងឆេះព្រៃក៏អាចមានម្តងម្កាល ដោយសារតែតំបន់ចម្ការពូជមានដើមឈើតូច ធំដុះជិតៗគ្នា និងស្មៅងាប់ដែលអាចបង្កឲ្យមានភ្លើងឆេះព្រៃកើតឡើង ហើយបញ្ហាភ្លើងឆេះព្រៃខ្លះទៀត អាចកើតមានជាញឹកញយផងដែរ ព្រោះដោយសារតែមាន ជនខិលខូចមួយចំនួនបាន បោះកន្ទុយបារីលួចដុតដែលជាហេតុ បង្កឲ្យមានភ្លើងឆេះព្រៃ ហើយកម្លាំងដែលធ្វើការយាមល្បាត និងរដ្ឋបាលព្រៃឈើមូលដ្ឋាន ធ្វើការអន្តរាគមន៍ក្នុងការពន្លត់ផងដែរ។

ចំពោះបញ្ហាហេដ្ឋារចនាសម្ព័ន្ធវិញនៅខ្វះខាតនៅឡើយពីព្រោះ ទៅតាមផ្លូវដែលត្រូវយាមល្បាតដើមគ្រញូងគឺមានប្រឡាយ ដូចនេះត្រូវតែធ្វើការសាងសង់ស្ពានសម្រាប់ឆ្លងជំនួសស្ពានចាស់ និងបន្ថែមចំនួនស្ពានបង្កឲ្យការអន្តរាគមន៍ ក្នុងការងារផ្សេងៗដូចជាការដើរល្បាត ការងារបង្ក្រាបបទល្មើសផ្សេងៗ ដែលបានកើតមានក្នុងតំបន់ចម្ការពូជ។

**សន្និដ្ឋានជំពូក**

ទាក់ទងនឹងជំពូកទី២នេះ យើងខ្ញុំបានធ្វើការបង្ហាញអំពីលក្ខណៈទូទៅនៃស្ថានភាពភូមិសាស្ត្រ ដែលយើងខ្ញុំបានភ្ជាប់ជាមួយនឹង ទីតាំងភូមិសាស្ត្រ របាយ និងដង់ស៊ីតេប្រជាជន ប្រភេទដី អាកាសធាតុ ធនធានព្រៃឈើ និងសត្វព្រៃឈើជាដើម។ ជាមួយគ្នានេះដែរ យើងបានសិក្សាអំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងនៅក្នុងតំបន់ចម្ការពូជឈើគ្រញូង អំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលសង្កាត់រដ្ឋបាលព្រៃឈើបានអនុវត្ត និងការគ្រប់គ្រងត្រួតពិនិត្យ បង្ក្រាបបទល្មើស វិធានការអនុវត្តបន្តរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅក្នុងការអនុវត្តតំបន់ចម្ការពូជ ហើយពិនិត្យអំពីការចូលរួមរបស់ស្ថាប័នអង្គការនានា និងប្រជាជនដែលបានចូលរួមធ្វើការអភិរក្ស និងគ្រប់គ្រងតំបន់ចម្ការពូជនេះផងដែរ។ លើសពីនេះ នៅក្នុងជំពូកនេះ យើងខ្ញុំក៏បានធ្វើការបញ្ចូលអំពីភាពជោគជ័យ និងបញ្ហាជួបប្រទះនៅក្នុងចម្ការពូជដែលបានចងក្រងដោយខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តសៀមរាប។

# ជំពូកទី៣ ៖

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

# ជំពូកទី៣

# ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

## ៣.១ ភាពជោគជ័យលើការគ្រប់គ្រងចម្ការពូជឈើគ្រញូងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ

ចម្ការពូជឈើគ្រញូងគឺជាតំបន់ដែលមានការអភិរក្សយ៉ាងពិសេស និងយ៉ាងតឹងរឹងបំផុត។ ចម្ការគ្រាប់ពូជគ្រញូងគឺជា តំបន់ពិសេសមួយស្ថិតក្នុងខេត្តសៀមរាបនៃប្រទេសកម្ពុជា ដែលសម្បូរទៅដោយប្រភេទឈើគ្រញូង និងប្រភេទផ្សេងៗទៀត ដែលមានលទ្ធភាពផ្តល់នូវគ្រាប់ពូជ ជាពិសេសគ្រាប់ពូជគ្រញូង ដែលជាគ្រាប់ពូជដ៏កម្រមួយប្រភេទ និងមានតម្លៃផងដែរ។ ស្របពេលប្រភេទឈើកម្រមួយចំនួន ជាពិសេស ប្រភេទឈើគ្រញូង ប្រភេទឈើនាងនួន និងបេងបានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារកាប់បំផ្លាញ ធ្វើពាណិជ្ជកម្មខុសច្បាប់ ដោយយល់ឃើញបាតុភូតដូនេះ ខណ្ឌរដ្ឋបាលព្រៃឈើ ដែលមានផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី និងសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ជាអ្នកអនុវត្តក្នុងកិច្ចការការពារ ការបង្ការភ្លើងឆេះព្រៃ ការផ្សព្វផ្សាយដល់ប្រជាជន និងបង្ក្រាបបទល្មើសផ្សេងៗដែលកើតមានក្នុងតំបន់។

ជាក់ស្តែងចាប់តាំងពីឆ្នាំ២០០២ ចម្ការគ្រាប់ពូជគ្រញូងបានដាក់កម្លាំងយាមល្បាតចំនួន ២នាក់។ ហើយនៅឆ្នាំ២០០៤មានការកើនឡើងដល់ចំនួន ៤នាក់ រហូតដល់ឆ្នាំ២០១០ចម្ការពូជបានពង្រីកផ្ទៃដីសរុបចំនួន ១៨៨៨ ហិកតា ក្នុងកំឡុងពេលនោះដែលកម្លាំងយោធាយាមល្បាតបានបន្ថែមរហូតដល់ ១០នាក់ដែលមានកម្មករបណ្តែតចំនួន ៧នាក់ក្នុងចម្ការពូជគ្រញូង ដើម្បីធ្វើការការពារគ្រប់គ្រង និងថែរក្សាសុវត្ថិភាព និងអភិវឌ្ឍន៍ចម្ការគ្រាប់ពូជ។ ហើយមកដល់បច្ចុប្បន្ននេះ កម្លាំងយាមល្បាតមានចំនួន១៧នាក់ ដោយក្រុមឆ្មាំការពារបានធ្វើការបែងចែកក្រុមតូចៗ ដែលមានចំនួន ៧ក្រុមដែលមានទីស្នាក់ធំនៅចំកណ្តាលចម្ការគ្រាប់ពូជ និងទីស្នាក់ការតូចៗមានចំនួន ៧កន្លែងដែលមានទីតាំងផ្សេងៗគ្នានៅក្នុងចម្ការ ដែលមានការធ្វើការយាមល្បាតទាំងយប់ ទាំងថ្ងៃ ទៅតាមទិសដៅនីមួយៗ។

### ៣.១.១ ការដាំស្តារឡើងវិញនូវព្រៃឈើក្នុងចម្ការគ្រាប់ពូជគ្រញូង

ចំពោះការដាំកូនឈើក្នុងចម្ការ តាមរយៈការអនុវត្តជាក់ស្តែង និងសកម្មភាពដាំដុះកូនឈើក្នុងតំបន់ភាគច្រើនការដាំដុះរដ្ឋបាលព្រៃឈើក្នុងតំបន់ យកកូនគ្រញូងដែលបានធ្វើការដាំដុះក្នុងថ្នាល ទៅដាំបញ្ចូលក្នុងតំបន់ចម្ការគ្រញូងដែលមាន ផ្ទៃដីរាប់រយហិចតានៅជុំវិញចម្ការពូជ និង

ក្នុងចម្ការពូជ។ តំបន់នោះជាតំបន់មួយដែលមានសក្តានុពលសម្រាប់ប្រភេទគ្រញូងនេះផ្ទាល់តែម្តងព្រោះអាកាសធាតុ និងស្ថានភាពដីក្នុងតំបន់មានលក្ខណៈអំណោយផលច្រើន។

តាមរយៈការសិក្សាស្វែងយល់លើការអនុវត្តជាក់ស្តែង ក្នុងដំណើរការដាំដើមឈើស្តារឡើងវិញរបស់សង្កាត់កន្ទួតខ្នារក្រៅនៅក្នុងចម្ការគ្រាប់ពូជគ្រញូង ដែលមានរយៈពេល៥ឆ្នាំបានបង្ហាញឲ្យឃើញថា៖

តារាង ៣.១៖ ការដាំស្តារឡើងវិញនូវកូនឈើក្នុងចម្ការពូជឈើគ្រញូង

| កាលបរិច្ឆេទ | ចំនួនកូនឈើដាំ | ភាគរយ% |
|---|---|---|
| ២០១៤ | ១២០០០ | ២៨.០២% |
| ២០១៥ | ១៤៥៤៣ | ៣៣.៩៦% |
| ២០១៦ | ២៤០៨ | ៥.៦២% |
| ២០១៧ | ៧៨ | ០.១៨% |
| ២០១៨ | ១៣៧៩១ | ៣២.២០% |

ប្រភព៖ របាយការណ៍បូកសរុបការងារវិស័យព្រៃឈើ ឆ្នាំ២០១៨

ក្រាហ្វិក ៣.១៖ ការដាំស្តារឡើងវិញនូវកូនឈើក្នុងចម្ការពូជឈើគ្រញូង




យោងតាមតារាង និងក្រាហ្វិកបានបង្ហាញឲ្យឃើញថា ទាក់ទងអំពីការដាំឡើងវិញនូវព្រៃឈើក្នុងចម្ការគ្រាប់ពូជគ្រញូង យើងទទួលបានថាលទ្ធផល ចំនួនកូនឈើដែលបានដាំនៅឆ្នាំ២០១៤ មានចំនួន ១២០០០ដើម ស្មើរ ២៨.០២% នៃចំនួនកូនឈើដែលបានដាំរយៈពេល៥ឆ្នាំចុងក្រោយ ហើយក្នុងឆ្នាំនេះដែរការដាំដើមកូនឈើមានចំនួនច្រើនដោយសង្កាត់រដ្ឋបាលព្រៃឈើ

កន្ទួតខ្នារក្រៅបានធ្វើការដាំនូវទីតាំងដែលមានចន្លោះប្រហោងក្នុងចម្ការដើម្បីបំពេញ និងធ្វើការដាំកូនឈើនៅតាមដងផ្លូវ ដែលប្រភេទទាំងនោះមានប្រភេទកូនឈើគ្រញូងចំនួន ៨១១៨ដើម កូនឈើបេងចំនួន ៣២៥២ដើម និងកូនឈើទាលចំនួន ៦៣០ដើម។ ក្នុងឆ្នាំ២០១៥ មានចំនួនកូនឈើ ១៥៥៤៣ដើម ស្មើរ ៣៣.៨៦% នៃចំនួនកូនឈើដែលបានដាំរយៈពេល៥ឆ្នាំចុងក្រោយ ក្នុងឆ្នាំ២០១៥នេះផងដែរ ការដាំកូនឈើមានចំនួនច្រើនជាងគេបើប្រៀបធៀបជាមួយនឹងឆ្នាំដ៏ទៃទៀត ដោយសារតែរដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានចាប់ផ្ដើមបង្កើតនូវសួនអនុស្សាវរីយ៍ មានចំនួន ០៦ប្លុកនៅក្នុងចម្ការគ្រាប់ពូជគ្រញូង ដែលអាចឲ្យភ្ញៀវជាតិ និងអន្តរជាតិដែលបានចូលទស្សនាក្នុងចម្ការអាចចូលរួមដាំកូនឈើនៅក្នុងសួនអនុស្សាវរីយ៍នេះផងដែរ លើសពីនេះសង្កាត់កន្ទួតខ្នារក្រៅធ្វើការដាំកូនឈើបន្ថែមទៀតនៅប្រភេទកូនឈើគ្រញូងចំនួន ១៤៣៨៨ដើម និងកូនឈើនាងនួនចំនួន ០៤ដើម នៅតាមកន្លែងទីវាល ឬចន្លោះ ដើម្បីឲ្យស្របទៅតាមផែនការរបស់សង្កាត់ព្រៃឈើរបស់ខ្លួនបានរៀបចំ។ ក្នុងឆ្នាំ២០១៦ មានចំនួនកូនឈើ ២៤០៨ដើម ស្មើរ៥.៦២% នៃចំនួនកូនឈើដែលបានដាំរយៈពេល៥ឆ្នាំចុងក្រោយ ដោយក្នុងឆ្នាំនេះមានការដាំប្រភេទកូនឈើប្រណិត ដូចជា គ្រញូង បេង ធ្នង់ បន្ថែមទៀតផងដែរ ដោយក្នុងនោះមិនត្រឹមតែមានការចូលរួមដាំកូនឈើពីខាងរដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅតែប៉ុណ្ណោះទេ ប៉ុន្តែមានការចូលរួមពីសំណាក់ ប្រតិភូរាជរដ្ឋាភិបាល ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ និងក្រុមទេសចរណ៍ចូលទស្សនាក្នុងចម្ការគ្រាប់ពូជគ្រញូង។ ចំណែកក្នុងឆ្នាំ ២០១៧ មានចំនួនកូនឈើ ៧៨ដើម ស្មើរ០.១៨% នៃចំនួនកូនឈើដែលបានដាំរយៈពេល៥ឆ្នាំចុងក្រោយ ចំពោះចំនួនកូនឈើដាំក្នុងឆ្នាំនេះមានចំនួនតិចជាងគេក្នុងចំណោមឆ្នាំទាំង៥ ក្នុងនោះដែរកូនឈើទាំងអស់ត្រូវបានដាំដោយ គណៈប្រតិភូរាជរដ្ឋាភិបាល និងអន្តរជាតិ ភ្ញៀវជាតិ និងអន្តរជាតិ សិស្សានុសិស្សនៅក្នុងសួនអនុស្សាវរីយ៍នៃចម្ការគ្រាប់ពូជគ្រញូង ដោយសារតែសង្កាត់រដ្ឋបាលកន្ទួតខ្នារក្រៅបានដាំកូនឈើលើសពីផែនការរបស់ខ្លួនកាលពីឆ្នាំកន្លងទៅធ្វើឲ្យតំបន់មួយចំនួនត្រូវបានដាំបំពេញគ្រប់គ្រាន់ ដូច្នេះសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅត្រូវស្វែងរកទីតាំងថ្មីៗបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់ធ្វើការដាំទៅតាមចន្លោះប្រហោងបន្ថែមទៀត។ នៅក្នុងឆ្នាំ២០១៨ មានចំនួនកូនឈើ ១៣៧៩១ដើម ស្មើរ៣២.២០% នៃចំនួនកូនឈើដែលបានដាំរយៈពេល៥ឆ្នាំចុងក្រោយ នៅក្នុងឆ្នាំនេះចំនួនកូនឈើមានការកើនឡើងខ្ពស់វិញ ដោយសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ និងកងកម្លាំង បានធ្វើគម្រោងកំសាន្តលំហែកាយធម្មជាតិបានដាំកូនឈើចម្រុះបន្ថែមបានចំនួន ១៣៦០០ដើម រួមមាន កូនឈើធ្នង់ចំនួន ២០០០ដើម កូនឈើកកោះចំនួន ១២០០ដើម កូនឈើទាលចំនួន ១០០ដើម កូនឈើពពាលចំនួន ២០០ដើម កូនឈើ

ព្រីងចំនួន ១៨០០ដើម កូនឈើស្តៅចំនួន ២១០០ដើម កូនឈើត្រាចចំនួន ៣៥០០ដើម កូនឈើត្រសេកចំនួន ២០០ដើម និងកូនឈើស្វាយព្រៃចំនួន ២០០០ដើម។ ក្រៅពីនេះក៏មានការចូលរួមដាំពីសំណាក់គណៈប្រតិភូរាជរដ្ឋាភិបាល ភ្ញៀវជាតិ និងអន្តរជាតិ អង្គការ នៅក្នុងចម្ការផងដែរ។ ដូច្នេះតាមរយៈលទ្ធផលខាងលើយើងអាចសន្និដ្ឋានបាន ការគ្រប់គ្រងព្រៃឈើនៅក្នុងចម្ការគ្រាប់ពូជគ្រញូងរបស់សង្កាត់រដ្ឋបាលព្រៃឈើតាមរយៈការដាំស្តារឡើងវិញនូវព្រៃឈើមានដំណើរការល្អប្រសើរ ដោយសង្កាត់បានអនុវត្តទៅតាមផែនការដាក់ចេញ ស្វែងរកទីកន្លែងដាំបន្ថែម នឹងចូលរួមថែរក្សានូវព្រៃឈើបានយ៉ាងល្អនៅក្នុងតំបន់។

### ៣.១.២ ការបង្ក្រាបបទល្មើស

ជារឿយៗចម្ការគ្រាប់ពូជគ្រញូងតែងតែមានការលួចកាប់ដើមពូជគ្រញូង និងប្រភេទឈើប្រណិតដ៏ទៃទៀតពីសំណាក់ជនល្មើសដែលមកពីខាងក្រៅតំបន់ចម្ការពូជ ហើយអាចមានករណីចូលដាក់អន្ទាក់សត្វ និងធ្វើការបរបាញ់សត្វព្រៃជាដើមផងដែរ។ ទោះបីជាបទល្មើសខាងលើតែងតែកើតមាន ប៉ុន្តែមន្ត្រី និងឆ្មាំល្បាតតែងតែធ្វើការបង្ក្រាបបានជានិច្ចដោយបានឃាត់ខ្លួនជនល្មើសខ្លះត្រូវពិន័យអន្តរការណ៍ និងខ្លះឈានដល់ការបញ្ជូនខ្លួនទៅតុលាការក្នុងការដោះស្រាយផងដែរ។ ហើយមិនតែប៉ុណ្ណោះក្នុងការបង្ក្រាបបទល្មើសទាំងនេះ បានដកហូតនូវវត្ថុតាងមួយចំនួនដូចជាឈើអារ សត្វព្រៃ រណាយន្ត ជាដើម។ លើសពីនេះទៅទៀត សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានបង្កើនឆ្មាំ ការពារបន្ថែមពីលើកម្លាំងចាស់ដែលមានស្រាប់ ហើយធ្វើការល្បាត និងយាមកាមយ៉ាងតឹងរឹងបំផុតមិនឲ្យជនណាម្នាក់ចូលទៅចម្ការពូជដោយគ្មានការអនុញ្ញាតឡើយ ពីថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ។ ទាក់ទងនឹងបទល្មើសដូចជាទន្ទ្រានដីព្រៃធ្វើជាកម្មសិទ្ធិដើម្បីធ្វើកសិកម្មគឺមិនមានកើតមានទៀតនោះទេនៅក្នុងតំបន់ចម្ការគ្រាប់ពូជគ្រញូង ដោយសាររដ្ឋបាលព្រៃឈើដែលមានសង្កាត់កន្ទួតខ្នារក្រៅជាអ្នកគ្រប់គ្រងបានធ្វើផ្លូវព័ន្ធជុំវិញចម្ការគ្រាប់ពូជគ្រញូងផ្ទាល់តែម្តងដែលបានផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងបញ្ចៀសពីការទន្ទ្រានយកដីព្រៃពីសំណាក់ប្រជាជន ឬជនខិលខូច។

### ៣.១.៣ ហេដ្ឋារចនាសម្ព័ន្ធ

ជាមួយគ្នានេះផងដែរកន្លងមកនេះ រដ្ឋបាលព្រៃឈើ ដែលមានសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានធ្វើការអភិវឌ្ឍន៍តំបន់ចម្ការគ្រាប់ពូជគ្រញូងតាមរយៈការជីកស្តារប្រព័ន្ធប្រឡាយព័ទ្ធជុំវិញចម្ការពូជ ធ្វើផ្លូវលំចូលចម្ការដោយក្រាលគ្រួសក្រហម សាងសង់រោងស្នាក់ការណ៍កណ្តាលចំកណ្តាលចម្ការពូជ សាងសង់បង្គន់អនាម័យ សាងសង់ផ្ទះបាយ សាងសង់រោងយាមសម្រាប់ឆ្មាំ

ការពារក្នុងចម្ការពូជ សាងសង់ស្ពានបេតុងឆ្លងអូរ យកអាចម៍ដីមកពង្រាយធ្វើជាផ្លូវសម្រាប់ឆ្មាំដើរល្បាត រៀបបចំសួនអនុស្សាវរីយ៍សម្រាប់ឲ្យភ្ញៀវចូលរួមទស្សនាក្នុងចម្ការពូជអាចចូលរួមដាំកូនឈើក្នុងចម្ការពូជផងដែរ។ក្រៅពីនេះផងដែរ មន្ត្រីរដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ និងឆ្មាំយាមល្បាតនៅក្នុងចម្ការពូជបានប្រមូលនូវគ្រាប់ពូជគ្រញូង និងប្រភេទគ្រាប់ពូជប្រណិតផ្សេងៗទៀត ដើម្បីធ្វើការចែកចាយនូវគ្រាប់ពូជទាំងនេះ ទៅទូទាំងប្រទេស ក៏ដូចជាទុកសម្រាប់ធ្វើការបណ្តុះក្នុងថ្នាលរបស់ចម្ការពូជសម្រាប់ដាំបន្ថែមក្នុងតំបន់ចម្ការពូជ។

**៣.១.៤ ការការពារភ្លើងព្រៃ**

ទាក់ទងនឹងការការពារភ្លើងព្រៃ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានរៀបចំប្រឡាយមួយខ្សែសម្រាប់ប្រព័ន្ធការពារ ដែលមានរាងជាប៉ារ៉ាបូល ទទឹង ១ម និងជម្រៅ ១ម ដែលមានប្រវែងសរុបរហូតដល់១២.៧០០ម។ គោលបំណងនៃការបង្កើតនេះគឺ ការពារសម្រាប់ការពារពីការទន្ទ្រានចូលយកដីព្រៃពីប្រជាជន និងផ្លូវសម្រាប់ការពារភ្លើងដែលឆ្លងចូលទៅក្នុងព្រៃចម្ការពូជ។ ចំពោះវិធានការផ្សេងៗទៀតដូចជា ធ្វើការសម្អាតស្មៅ នៅក្នុងអំឡុងខែវិច្ឆិការ និងខែធ្នូ ដោយប្រើភ្លើងធ្វើការដុតសំអាតតាមប្រព័ន្ធ និងតាមព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង គោលបំណងគឺទប់ស្កាត់កុំឲ្យមានបាតុភូតភ្លើងព្រៃដែលកើតមានចៃដន្យ។ ទោះជាយ៉ាងណាភ្លើងអាចឲ្យយើងធ្វើការគ្រប់គ្រងបានបង្ការ ដោយមិនបង្កឆេះទៅផ្នែកដ៏ទៃទៀតនៃព្រៃដោយប្រើឧបករណ៍ផ្សេងៗជាពិសេស ម៉ូតូដែលបានបំពាក់ម៉ាស៊ីនបាញ់ទឹក និងអមដោយកម្លាំងមនុស្សផងដែរសម្រាប់ជួយពន្លត់។

**៣.១.៥ ការអប់រំផ្សព្វផ្សាយ**

ក្រៅពីការងារផ្សេងៗនៅក្នុងចម្ការគ្រាប់ពូជគ្រញូង មន្ត្រីរដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅបានធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាជនក្នុងសហគមន៍ ពីព្រោះការផ្សព្វផ្សាយក្នុងតំបន់ គឺជាកម្មវត្ថុមួយក្នុងកម្មវត្ថុចំបងនានាក្នុងការអភិរក្សតំបន់ ដែលធ្វើការការពារ និងអភិរក្សក្នុងតំបន់មាននិរន្តរភាព និងមានប្រសិទ្ធភាពខ្ពស់ បើមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋានផងដែរ។ សកម្មភាពធ្វើការផ្សព្វផ្សាយ គឺធ្វើឡើងដោយមានការកោះហៅប្រជាជនឲ្យមកជួបជុំគ្នានៅកន្លែងកំណត់មួយដោយស្តាប់មតិណែនាំរបស់ថ្នាក់ដឹកនាំស្រុក ឃុំ និងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើលើច្បាប់ លិខិតបទដ្ឋាននានា និងប្រយោជន៍នៃការអភិរក្សធនធានធម្មជាតិជាដើម។ លើសពីនេះទៅទៀត មន្ត្រីរដ្ឋបាលព្រៃឈើបានធ្វើការផ្សព្វផ្សាយផ្សេងៗទៀតតាមរយៈ ផូស្ទ័រ រូបភាព ដែលទាក់ទងការអភិរក្សក្នុងតំបន់ និងពាក្យស្លោកផ្សេងៗ ដែលទាក់ទងនឹងការអភិរក្សព្រៃឈើ និងសត្វព្រៃនៅក្នុងតំបន់។ ក្រៅពីនេះមានការធ្វើបដាដាក់នៅតាមដើមឈើ តាមដងផ្លូវធ្វើដំណើរចូលទៅក្នុងព្រៃ ដោយ

បង្ហាញពីការហាមប្រាមក្នុងតំបន់ និងបានដកស្រង់យកច្បាប់នៃមាត្រសំខាន់ៗដែលបានចែងក្នុងច្បាប់ព្រៃឈើ យកមកដាក់បង្ហាញផ្សព្វផ្សាយ។

## ៣.២ បញ្ហាប្រឈម និងដំណោះស្រាយ

### ៣.២.១ បញ្ហាប្រឈម

ទោះបីជាមានគោលនយោបាយគ្រប់គ្រងល្អយ៉ាងណារបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ក៏ប៉ុន្តែសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅនូវតែមានភាពអវិជ្ជមាន ឬបញ្ហាប្រឈមមួយចំនួនកើតឡើងក្នុងការគ្រប់គ្រងចម្ការគ្រាប់ពូជគ្រញូងទន្ទឹមគ្នាផងដែរ។ ជាមួយដំណើរការកែលំអលើចំណុចខ្វះខាតនៃការគ្រប់គ្រងនៃចម្ការពូជរបស់សង្កាតរដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ក៏បានជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា៖

#### ៣.២.១.១ កម្រិតវប្បធម៌ និង ជំនាញបច្ចេកទេសរបស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ

**ក. កម្រិតវប្បធម៌**

តាមលទ្ធផលដែលទទួលបានពីការស្រាវជ្រាវអំពីចំណេះដឹងកម្រិតវប្បធម៌ របស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើបានបង្ហាញឲ្យឃើញថា៖

តារាង ៣.២៖ កម្រិតវប្បធម៌របស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ

| កម្រិតវប្បធម៌របស់មន្ត្រី | ចំនួន | ភាគរយ% |
|---|---|---|
| បរិញ្ញាបត្ររង | ០២ | ៤០% |
| ថ្នាក់ទី៩ថ្មី | ០២ | ៤០% |
| បឋម | ០១ | ២០% |

ប្រភព៖ របាយការណ៍បូកសរុបការងារវិស័យព្រៃឈើ ឆ្នាំ២០១៨

ក្រាហ្វិក ៣.២៖ កម្រិតវប្បធម៌របស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ




យោងតាមក្រាហ្វិកបានបង្ហាញឲ្យឃើញថា កម្រិតវប្បធម៌របស់មន្ត្រីរដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅត្រឹមថ្នាក់បរិញ្ញាបត្ររងមានចំនួន ២រូប ស្មើរ៤០% និងមន្ត្រីមានកម្រិតវប្បធម៌ត្រឹមថ្នាក់ទី៩ថ្មីមានចំនួន ២រូប ស្មើរ៤០% និងមន្ត្រីមានកម្រិតវប្បធម៌ត្រឹមថ្នាក់បឋមមានចំនួន ១រូប ស្មើរ២០%។ តាមរយៈលទ្ធផលខាងលើយើងអាចសន្និដ្ឋានបានឲ្យបានដឹងថា កម្រិតវប្បធម៌របស់មន្ត្រីសង្កាត់កន្ទួតខ្នារក្រៅនៅមានកម្រិតនៅឡើយ ពីព្រោះកម្រិតសិក្សាគាត់មិនបានទទួលបានការពិសោធន៍នានា ឬស្រាវជ្រាវអំពីការពារព្រៃឈើ ដោយសារមន្ត្រីដែលមានឱកាសទទួលបានការសិក្សាខ្ពស់បំផុតត្រឹមបរិញ្ញាបត្ររង និងក្រៅពីនេះមន្ត្រីទទួលបានការអប់រំត្រឹមថ្នាក់ទី៩ថ្មី និងបឋមតែប៉ុណ្ណោះ។

**ខ. ជំនាញបច្ចេកទេស**

តាមលទ្ធផលដែលទទួលបានពីការស្រាវជ្រាវអំពីជំនាញបច្ចេកទេស របស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើបានបង្ហាញឲ្យឃើញថា៖

តារាង ៣.៣៖ ជំនាញបច្ចេកទេសរបស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ

| ជំនាញបច្ចេកទេសរបស់មន្ត្រី | ចំនួន | ភាគរយ% |
|---|---|---|
| បសុព្យាបាល | ០១ | ២០% |
| រុក្ខកម្ម | ០១ | ២០% |
| បច្ចេកវិទ្យា+គ្រប.កសក | ០១ | ២០% |
| គ្មានជំនាញ | ០២ | ៤០% |

ប្រភព៖ របាយការណ៍បូកសរុបការងារវិស័យព្រៃឈើ ឆ្នាំ២០១៨

ក្រាហ្វិក ៣.៣៖ ជំនាញបច្ចេកទេសរបស់មន្ត្រីនៃសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ




យោងតាមតារាង និងក្រាហ្វិក បានបង្ហាញឲ្យឃើញថា មន្ត្រីនៅក្នុងសង្កាត់រដ្ឋបាលព្រៃឈើខ្នារក្រៅ មន្ត្រីមានជំនាញបសុពេទ្យចំនួន ១រូប ស្មើរ២០% មន្ត្រីមានជំនាញរុក្ខកម្មចំនួន ១រូប ស្មើរ២០% មន្ត្រីបច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្មចំនួន ១រូប ស្មើរ២០% និងមន្ត្រីដែលគ្មានជំនាញបច្ចេកទេសចំនួន ២រូប ស្មើរ៤០%។ តាមរយៈជំនាញបច្ចេកទេសខាងលើ យើងសង្កេតឃើញថាមន្ត្រីនៅសង្កាត់ព្រៃឈើកន្ទួតខ្នារក្រៅ ដែលមានជំនាញដែលទាក់ទងជាមួយនឹងព្រៃឈើគឺមានតែមួយរូបប៉ុណ្ណោះក្នុងចំណោម៥រូប ដែលមន្ត្រីផ្សេងទៀតគឺមានជំនាញទាក់ទងនឹងបសុពេទ្យ ការងារបច្ចេកវិទ្យាផ្នែកកសិកម្ម និងគ្មានជំនាញ ដែលជំនាញទាំងអស់នេះមិនមានជាប់ទាក់ទងជាមួយការការពារព្រៃឈើ។ កត្តាទាំងអស់នេះហើយដែលជាមូលហេតុដែលបណ្តាលឲ្យមានការគ្រប់គ្រងធនធានព្រៃឈើនៅក្នុងចម្ការពូជជួបប្រទះបញ្ហា ការសិក្សាស្រាវជ្រាវនៅមានកម្រិត និងការចងក្រងទិន្នន័យអំពីពត៌មានព្រៃឈើ និងសត្វព្រៃពុំមានភាពច្បាស់លាស់ ដោយសារចំណេះដឹងរបស់មន្ត្រីគ្រប់គ្រងនៅទីនោះនៅមានកម្រិត និងមិនសូវមានជំនាញដែលជាប់ពាក់ព័ន្ធជាមួយការងារព្រៃឈើ។

### ៣.២.១.២ បញ្ហាផ្សេងៗ

#### ក. គ្រាប់ពូជផ្តល់ផលតិច

ក្នុងចម្ការគ្រាប់ពូជគ្រញូងសម្បូរទៅដោយដើមមេច្រើន ប៉ុន្តែការផ្តល់ផលតិច ដោយសារដើមមេខ្លះពុំសូវធននឹងជម្ងឺ ដែលធ្វើឲ្យការប្រមូលគ្រាប់ពូជបានតិចតួច និងមិនអាចធ្វើការចែកចាយបានច្រើនទៅតំបន់ផ្សេងៗនៅក្នុងប្រទេសកម្ពុជាតាមតម្រូវការបាន។ ជាពិសេស គ្រាប់ពូជ

ដែលប្រមូលបាននោះ យកមកបណ្ដុះសម្រាប់ដាំក្នុងចម្ការគ្រាប់ពូជគ្រញូងមិនបានចំនួនច្រើនផង ដែរ។ កត្តាទាំងនេះធ្វើឲ្យមានការរាំងស្ទះនូវការផ្គត់ផ្គង់ និងចែកចាយបន្តនូវគ្រាប់ពូជដោយសារ ចំនួនគ្រាប់ពូជនៅមានកម្រិត។

### ខ. កង្វះនូវមន្ត្រី និងឆ្មាំដើរល្បាតនៅក្នុងចម្ការគ្រាប់ពូជគ្រញូង

ជាក់ស្ដែងនូវពេលបច្ចុប្បន្ននេះចំនួនមន្ត្រីក្នុងសង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្នារក្រៅដែលគ្រប់គ្រង ចម្ការពូជមានចំនួន ៥រូប និងឆ្មាំដើរល្បាតមានចំនួន ១៧រូប ប៉ុន្តែចំនួនមន្ត្រី និងឆ្មាំដើរល្បាតនៅមិន ទាន់គ្រប់គ្រាន់ក្នុងការគ្រប់គ្រងនៅក្នុងតំបន់ចម្ការគ្រាប់ពូជគ្រញូងទាំងមូលបាននៅឡើយនោះទេ ដោយសារពុំមានមន្ត្រីប្រចាំការក្នុងការមើលការខុសត្រូវ និងគ្រប់គ្រងនៅក្នុងចម្ការពូជ។ ជាមួយ នេះដែល ដោយឆ្មាំដើរល្បាតមានចំនួនតិចតួចពុំមានលទ្ធភាពគ្រប់គ្រាន់ប្រមូលគ្រាប់ពូជបានអស់ ដែលបណ្ដាលឲ្យខូចខាតនូវគ្រាប់ពូជមួយចំនួន និងមិនអាចមើលល្បាតបានអស់នៅគោលដៅខ្លះ ដែលជាមូលហេតុកើតនូវការឆ្លៀតឪកាសពីជនខិលខូចក្នុងការប្រព្រឹត្តបទល្មើសព្រៃឈើ និងសត្វ ព្រៃជាដើម។

### គ. ហេដ្ឋារចនាសម្ព័ន្ធ

នៅក្នុងចម្ការគ្រាប់ពូជគ្រញូង ហេដ្ឋារចនាសម្ព័ន្ធគឺនៅមានកម្រិតនៅឡើយ គឺនៅតាមផ្លូវ ដែលត្រូវយាមល្បាតគឺមាននៅប្រឡាយ ដូចនេះតម្រូវមានការសាងសង់ស្ពានបន្ថែមសម្រាប់ឆ្លង ជំនួសស្ពានចាស់ ដើម្បីជួយសម្រួលដល់ឆ្មាំក្នុងការអន្តរាគមន៍ ក្នុងការងារផ្សេងៗដូចជាការងារដើរ ល្បាត ការងារបង្ក្រាបបទល្មើសផ្សេងៗ ដែលបានកើតមាននៅក្នុងតំបន់ចម្ការគ្រាប់ពូជ។ ជាមួយ គ្នានេះដែល ត្រពាំង និងប្រព័ន្ធប្រឡាយព័ទ្ធជុំវិញចម្ការគ្រាប់ពូជគ្រញូង រាក់អស់មិនបានស្ដារឲ្យ បានជ្រៅធ្វើឲ្យវខ្វះប្រភពទឹកសម្រាប់សត្វព្រៃ ក៏ដូចជាសម្រាប់ទុកជួយសម្រួលក្នុងការបង្ក្រាបភ្លើង ឆេះព្រៃជាដើម។

### ឃ. កង្វះថវិការ និងសម្ភារៈសម្រាប់ប្រើប្រាស់

បញ្ហាដែលធ្វើឲ្យរាំងស្ទះក្នុងការអភិវឌ្ឍន៍តំបន់ចម្ការគ្រាប់ពូជគ្រញូង គឺកង្វះថវិការក្នុងការ ប្រើប្រាស់សម្រាប់ទ្រទ្រង់គម្រោងអភិវឌ្ឍន៍ចម្ការទាំងមូល និងជីវភាពកម្មករប្រចាំថ្ងៃ។ ជាក់ស្ដែង សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅមានគម្រោងអភិវឌ្ឍន៍តំបន់នេះឲ្យក្លាយជាតំបន់ទេសចរណ៍ សម្រាប់ភ្ញៀវអាចចូលទស្សនានូវព្រៃឈើ និងសត្វព្រៃ ដោយមានការធ្វើផ្ទះស្នាក់លំហែកាយ តំបន់ ទំនាបឲ្យក្លាយជាប្រឡាយធំ ធ្វើផ្លូវសម្រាប់ដើរកំសាន្ត ប៉ុន្តែគម្រោងនេះមិនទាន់អាចដំណើរការទៅ

បាននៅឡើយទេ ដោយសារសង្កាត់មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអភិវឌ្ឍន៍ ដូច្នេះត្រូវស្នើរទៅកាន់ថ្នាក់លើ ឬស្វែងរកដៃគូផ្សេងក្នុងការចូលរួមគម្រោងមួយនេះឲ្យកើតចេញជារូបរាង។

**ង. បទល្មើសផ្សេងៗ**

បញ្ហាបទល្មើសមួយចំនួនតែងតែកើតមានឡើងនៅក្នុងចម្ការគ្រាប់ពូជគ្រញូងដូចជា ការលួចកាប់ឈើគ្រប់ប្រភេទជាពិសេសប្រភេទឈើគ្រញូង ដែលជនល្មើសតែងតែចូលមកធ្វើសកម្មភាពលួចកាប់នៅពេលថ្ងៃ ឬយប់ដោយប្រើប្រាស់នូវឧបករណ៍ខុសច្បាប់មួយចំនួនដែលមន្ត្រី និងឆ្មាំល្បាតបង្ក្រាបដូចជា រណាយន្តជាដើម។ ក្រៅពីបទល្មើសព្រៃឈើ បញ្ហាទាក់ទងនឹងបទល្មើសសត្វព្រៃតែងតែកើតមានផងដែរ ជាក់ស្តែងដូចជាជនល្មើសលួចចូលចម្ការគ្រាប់ពូជគ្រញូងដើម្បីដុតព្រៃចាប់សត្វ ការលបលួចដាក់អន្ទាក់សត្វ ការបំពុលសត្វព្រៃ ការធ្វើសំរ៉ងចាប់សត្វ ដែលធ្វើឲ្យមានការប៉ះពាល់ដល់ធនធានសត្វព្រៃដែលរស់នៅក្នុងតំបន់ចម្ការ ដែលជាប្រភេទសត្វកម្រ និងអាចបង្កជាភ្លើងឆេះព្រៃកើតឡើងក្នុងករណីជនល្មើសធ្វើការដុតព្រៃចាប់សត្វជាដើម។

**ច. គ្រោះធម្មជាតិ**

ក្រៅពីបញ្ហាប្រឈមដែលកើតមានខាងលើនេះ បញ្ហាគ្រោះធម្មជាតិ ដូចជាទឹកជំនន់ ភ្លើងឆេះព្រៃនិងខ្យល់បក់បោក តែងតែមានការកើតឡើងជានិច្ចដែលធ្វើឲ្យប្រភេទព្រៃឈើប្រណិតផ្សេងៗ និងសត្វព្រៃដែលរស់នៅក្នុងចម្ការគ្រាប់ពូជរងការខូចខាត បាត់បង់ នឹងត្រូវបំផ្លាញផងដែរ។ យោងតាមការសិក្សា និងការសម្ភាសន៍ពីមន្ត្រីរដ្ឋបាលព្រៃឈើបន្ថែមទៀតបញ្ហាគ្រោះទឹកជំនន់កើតឡើងដោយសារក្នុងតំបន់ចម្ការមានលក្ខណៈតូចៗ មួយចំនួនបានគោករាក់អស់ និងមួយចំនួនជាផ្លូវទឹកចាស់ ដែលតម្រូវឲ្យមានការស្តារឡើងវិញ ព្រោះពេលភ្លៀងម្តងៗ តែងតែមានគ្រោះទឹកជំនន់ដោយសារចរន្តផ្លូវទឹកហូរពុំបានលឿន។

**៣.២.២ ដំណោះស្រាយ**

បញ្ហានៃការគ្រប់គ្រងក្នុងចម្ការពូជនៅមានកម្រិត និងកង្វះធនធានមនុស្ស កើតឡើងដោយសារកត្តាខាងក្នុង និងកត្តាខាងក្រៅ។ កត្តាខាងក្នុង គឺការតាមដាន និងធ្វើសេចក្តីរាយការណ៍សកម្មភាពអាណាធិបតេយ្យព្រៃឈើក្នុងចម្ការពូជពុំសូវជិតដល់ ដោយសារតែកង្វះធនធានមនុស្សដែលបង្កឲ្យមានមន្ត្រីមានសមត្ថភាពពុំមានគ្រប់គ្រាន់ ក្នុងការធ្វើការទប់ស្កាត់ និងបង្ក្រាបបទល្មើសដែលបានកើតមានក្នុងតំបន់ចម្ការគ្រាប់ពូជគ្រញូង បូករួមជាមួយនឹងកង្វះនូវមធ្យោបាយ និងសម្ភារៈបច្ចេកទេសមិនមានគ្រប់គ្រាន់តាមតម្រូវការរបស់អង្គភាព។ លើសពីនេះទៅទៀតមានកត្តាខាងក្រៅមួយចំនួនទៀតដែលជះផលអាក្រក់ដល់ការគ្រប់គ្រងចម្ការពូជ រួមមានការចូលរួម

ពីសាធារណៈជននៅតំបន់ក្នុងការគ្រប់គ្រងព្រៃឈើនៅមានកម្រិត ការកើនឡើងចំនួនប្រជាជនមូលដ្ឋាន និងតម្រូវការប្រើប្រាស់ធនធានព្រៃឈើ និងដីសម្រាប់ធ្វើកសិកម្មមានការកើនឡើងនៅក្នុងតំបន់ចម្ការគ្រាប់ពូជគ្រញូង និងការធ្វើសកម្មភាពអាណាធិបតេយ្យមួយចំនួនទៀតដូចជា កាប់ឈើ និងបរបាញ់សត្វព្រៃ។

ដោយស្វែងយល់ឃើញពីបញ្ហានានា ដំណោះស្រាយគួរចែកចែញជា ២ ផ្នែកគឺ ដំណោះស្រាយខាងក្នុង និងដំណោះស្រាយខាងក្រៅដែលតម្រូវឲ្យមានការចូលរួមពីសំណាក់ រដ្ឋាភិបាល ស្ថាប័នអង្គការដែលពាក់ព័ន្ធ និងប្រជាជនផងដែរ។

**ក. ដំណោះស្រាយផ្ទៃក្នុងរបស់ចម្ការគ្រាប់ពូជឈើគ្រញូង**

- ជម្រុញ និងលើកទឹកចិត្តមន្ត្រីឲ្យមានការទទួលបានការសិក្សាថ្នាក់បន្តដើម្បីបង្កើននូវសមត្ថភាពទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀត ដែលធ្វើឲ្យការគ្រប់គ្រងធនធានព្រៃឈើនៅក្នុងចម្ការគ្រាប់ពូជកាន់តែមានភាពជោគជ័យ។
- ផ្តល់ឱកាសដល់មន្ត្រី នូវវគ្គបណ្តុះបណ្តាលអប់រំចំណេះដឹងទាក់ទិននឹងការគ្រប់គ្រងធនធានព្រៃឈើដល់មន្ត្រីឲ្យបានកាន់តែច្រើន ពីព្រោះរាល់ជំនាញដែលពួកគាត់មានគឺមិនមានជាប់ពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងធនធានព្រៃឈើនោះទេ។ ដូច្នេះរដ្ឋបាលព្រៃឈើ ឬក៏ស្ថាប័នអង្គការផ្សេងៗ ដែលជាប់ពាក់ព័ន្ធត្រូវចូលរួមក្នុងការជួយបណ្តុះបណ្តាលមន្ត្រីផងដែរ។
- ហ្វឹកហាត់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ក៏ដូចជាឆ្មាំដើរល្បាតឲ្យបានត្រឹមត្រូវ ដោយបង្កើនឲ្យមានការអនុវត្តន៍នូវផែនការរបស់ចម្ការពូជទៅតាមដំណាក់កាល និងលំហូរនៃការងារតាមតួនាទីនីមួយៗ។ លើសពីនេះត្រូវមានការតាមដានជាប្រចាំនៃលទ្ធផលការងាររបស់មន្ត្រី និងឆ្មាំម្នាក់ៗ និងត្រូវផ្តល់ជាជំនួយស្មារតី ឬបច្ចេកទេសការងារមួយចំនួន។
- បន្ថែមមន្ត្រីប្រចាំការគ្រប់គ្រងនៅក្នុងចម្ការពូជ និងឆ្មាំដើរល្បាតបន្ថែមក្នុងចម្ការគ្រាប់ពូជគ្រញូងទៅតាមគោលដៅ ដើម្បីគ្រប់គ្រងទទួលខុសត្រូវ និងការពារពីបទល្មើសផ្សេងដែលអាចកើតមានឡើងនៅក្នុងចម្ការ ពីព្រោះសព្វថ្ងៃកំពុងមានការខ្វះខាតនូវមន្ត្រី និងឆ្មាំនៅឡើយ។
- ត្រូវស្វែងរកអ្នកជំនាញដើម្បីធ្វើការសិក្សាអំពីដើមមេ ទាក់ទងមូលហេតុដែលធ្វើឲ្យដើមមេមួយចំនួនផ្តល់ផលគ្រាប់ពូជតិច និងពុំសូវមានសុខភាពល្អ ដើម្បីកែប្រែ និងធ្វើការព្យាបាលដោះស្រាយបញ្ហានោះឲ្យបានប្រសើរឡើង។

- សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅត្រូវស្វែងរកជំនួយពីរដ្ឋបាលព្រៃឈើ ស្ថាប័នអង្គការផ្សេងៗដើម្បីទ្រទ្រង់បន្ថែម តាមរយៈជាថវិកា សម្ភារៈ ជំនាញបច្ចេកទេសជាដើម ដើម្បីធ្វើការដោះស្រាយរាល់បញ្ហាដែលកើតមាននៅក្នុងចម្ការគ្រាប់ពូជគ្រញូង។

**ខ. ដំណោះស្រាយខាងក្រៅរបស់ចម្ការគ្រាប់ពូជឈើគ្រញូង**

- រាជរដ្ឋាភិបាលគួរចូលរួមអភិវឌ្ឍន៍នូវហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដែលកំពុងជួបប្រទះនូវបញ្ហានៅក្នុងចម្ការគ្រាប់ពូជគ្រញូង ដើម្បីជួយសម្រួលឲ្យចម្ការគ្រញូងមានហេដ្ឋា-រចនាមួយល្អ។
- រដ្ឋាភិបាល ក៏ដូចជា មន្ត្រីរដ្ឋបាលព្រៃឈើ អាជ្ញាធរ និងស្ថាប័នអង្គការនានាដែលពាក់ព័ន្ធគួរបង្កើតកម្មវិធីផ្សេងៗក្នុងការផ្សព្វផ្សាយ និងអប់រំដល់ប្រជាជនមូលដ្ឋានអំពីការការពារព្រៃឈើ និងការពារសត្វព្រៃជាដើម។
- ប្រជាជនមូលដ្ឋានគួរចូលរួមអភិរក្សតំបន់ចម្ការគ្រាប់ពូជគ្រញូងតាមរយៈ ការដាំដើមឈើ រាយការណ៍រាល់បទល្មើសផ្សេងៗដែលកើតមានក្នុងចម្ការពូជដល់មន្ត្រីរដ្ឋបាលព្រៃឈើ អាជ្ញាធរ ជាដើម។
- រដ្ឋាភិបាលគួរចូលរួមរឹតបន្តឹងច្បាប់បន្ថែមទៀតទាក់ទងនឹងការពារព្រៃឈើ និងសត្វព្រៃដើម្បីលុបបំបាត់នូវសកម្មភាពបទល្មើសផ្សេងពីសំណាក់ជនខិលខូច។
- ស្វែងរកដៃគូសហការណ៍ក្នុងការចូលរួមការពារអភិរក្ស និងទ្រទ្រង់តំបន់ចម្ការគ្រាប់ពូជគ្រញូងនេះឲ្យបានល្អប្រសើរ។

## សន្និដ្ឋានជំពូក

សរុបសេចក្តីមកវិញ ជំពូកទីបីនេះគឺជាជំពូកដែលមានអត្ថប្រយោជន៍យ៉ាងខ្លាំងសំរាប់ការសិក្សា និងការគ្រប់គ្រងធនធានព្រៃឈើនៅក្នុងតំបន់ចម្ការពូជឈើគ្រញូងដែលធ្វើការគ្រប់គ្រងដោយសង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ដោយពួកយើងបានធ្វើការវិភាគយ៉ាងម៉ត់ចត់ទៅលើសមិទ្ធិផលនានា ជាពិសេសទាក់ទងនឹងការដាំស្តារឡើងវិញនៃព្រៃឈើ និងការបង្ក្រាបបទល្មើសដែលសង្កាត់រដ្ឋបាលព្រឈើបានសម្រេចបាននៅក្នុងចម្ការពូជ ធ្វើការពិភាក្សាទៅលើបញ្ហាប្រឈមដែលកើតមាននៅក្នុងចម្ការពូជ និងស្វែងរកដំណោះស្រាយជាច្រើនដែលអាចធ្វើជាស្ពានក្នុងការគ្រប់គ្រងនិងយកទៅដោះស្រាយនូវបញ្ហាដែលកើតមានឡើងនៅក្នុងចម្ការពូជឈើគ្រញូង ឲ្យមានប្រសិទ្ធិភាព និងកាត់បន្ថយនូវបញ្ហាក៏ដូចជាឧបសគ្គដែលធ្វើឲ្យមានភាពយឺតយ៉ាវក្នុងការគ្រប់គ្រងនិងអភិរក្ស។ ក្រៅពីនេះគេអាចយកដំណោះស្រាយទាំងនេះ ទៅដោះស្រាយបញ្ហាគ្រប់គ្រងធនធានព្រៃឈើដែលកើតមានតំបន់ផ្សេងទៀត ដែលជួបនូវបញ្ហាស្រដៀង ឬដូចគ្នាទៅនឹងបញ្ហាដែលកើតមានឡើងនៅក្នុងតំបន់ចម្ការពូជឈើគ្រញូងស្ថិតក្រោមការគ្រប់គ្រងរបស់សង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្នារក្រៅនេះផងដែរ។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានចុះស្រាវជ្រាវ និងធ្វើការសិក្សាអង្កេតស្តីពី ការគ្រប់គ្រងធនធានព្រៃឈើនៅក្នុងចម្ការពូជឈើគ្រញូងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅមួយរយៈពេលកន្លងមកអាចសន្និដ្ឋានដូចខាងក្រោម៖

ចម្ការពូជឈើគ្រញូងមានការប្រែប្រួលទំហំផ្ទៃដីចម្ការពូជមាន ៣ដំណាក់កាលដែលដំណាក់កាលទី១ មានចំនួន ៥០ហិចតា តាមប្រកាសលេខៈ ៣៣៤ ប្រក.ស.ក.ស ចុះថ្ងៃទី១៨ ខែតុលា ២០០៤ ស្តីពីការបង្កើតតំបន់ប្រភពគ្រាប់ពូជគ្រញូង និងធ្នង់ ក្នុងខេត្តសៀមរាប និងកើនដល់ ២៥០ហិចតា នៅចុងឆ្នាំ ២០១០ ចម្ការពូជឈើគ្រញូង បានពង្រីបន្ថែមទំហំ ១៨៨៨ ហិចតា តាមប្រកាសលេខៈ ៦៨៥ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នៅក្នុងតំបន់ចម្ការពូជឈើគ្រញូងក្រៅពីប្រភពពូជគ្រញូង មានគ្រាប់ពូជដ៏ទៃទៀតសម្រាប់ចែកចាយ និងផ្គត់ផ្គង់ដូចជា នាងនួន ដៃខ្លា សុក្រម បេង ធ្នង់ ធ្នឹក ធ្នឹករាំង កកោះ ច្រេស ជាដើម។ គ្រាប់ពូជទាំងអស់នេះអាចធ្វើការចែកចាយទៅកាន់ស្ថាប័នផ្សេងៗទៀត ដែលត្រូវការគ្រាប់ពូជទាំងនោះធ្វើការដាំដុះ។ លើសពីនេះទៅទៀត មានការសាងសង់នូវទីស្នាក់កាល នៅចំកណ្តាលតំបន់ប្រភពពូជឈើគ្រញូង និងមានទីស្នាក់កាលចល័តចំនួន ៧កន្លែងមានទីតាំងផ្សេងៗគ្នាសម្រាប់ធ្វើការយាមល្បាតនៅពេលយប់។ ជាមួយគ្នាដែរ ចំពោះវិធានការសំខាន់ៗ ក្នុងការអភិរក្សតំបន់ចម្ការពូជឈើគ្រញូង សង្កាត់រដ្ឋបាលកន្ទួតខ្នារក្រៅ បានកំណត់តំបន់ជាច្រើនផ្នែកក្នុងតំបន់ចម្ការ ជាពិសេសតំបន់ដែលមានដើមគ្រញូងច្រើនធ្វើការដើរល្បាតជារៀងរាល់ថ្ងៃ និងយប់ កំណត់ដើមមេពូជថ្មីៗតាមគោលការណ៍ដែលកំនត់ ការបង្ការភ្លើងព្រៃ ការដាំបញ្ចូលកូនឈើបន្ថែម ការរៀបចំប្រព័ន្ធការពារភ្លើងឆេះ និងការឆ្លងចូលរបស់មនុស្ស ធ្វើការផ្សព្វផ្សាយដល់ប្រជាជន និងសកម្មភាពផ្សេងៗ។ ក្រៅពីនេះ ប្រជាជនមួយចំនួនធំដែលរស់នៅជុំវិញតំបន់ចម្ការពូជឈើគ្រញូង បានយល់ដឹងច្រើនអំពីសារៈសំខាន់នៃព្រៃឈើដែលនៅជុំវិញខ្លួន ពីព្រោះវាជាជម្រកសត្វព្រៃ និងតំបន់ដែលមានដុះប្រភេទឈើកម្រជាច្រើន ជាពិសេសប្រភេទឈើគ្រញូង នឹងបានចូលរួមស្តារ និងអភិរក្សជាមួយស្ថាប័នជំនាញផងដែរ។ ក្នុងដែនគ្រប់គ្រងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ កាលពីមុនគឺសម្បូរទៅធនធានជីវៈចម្រុះជាច្រើនប្រភេទ ដែលមានទំនាក់ទំនងគ្នាជាប្រព័ន្ធអេកូឡូស៊ីបានយ៉ាងប្រសើរ។ តែក្រោយមកព្រៃឈើត្រូវទទួលបានរងនូវការគំរាមគំហែង និងកាប់បំផ្លាញដោយសកម្មភាពអាណាធិបតេយ្យរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងអ្នកមានអំណាច។ នាពេលបច្ចុប្បន្នប្រភេទព្រៃឈើ ដែលស្ថិតនៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ

មួយផ្នែកតូចរងការរេចរឹល និងមួយផ្នែកទៀតក៏បានរក្សានូវរចនាសម្ព័ន្ធព្រៃបានផងដែរ។ ទោះបីជាយ៉ាងនេះក្តីក៏នៅតែមានសកម្មភាពកាប់បំផ្លាញបន្តបន្ទាប់ដែលកំពុងជះឥទ្ធិពលអវិជ្ជមានទៅដល់វិស័យព្រៃឈើ មានដូចជា ការលួចធ្វើអាជីវកម្ម បញ្ហាភ្លើងឆេះព្រៃ ការប្រើប្រាស់ផលនិងអនុផលព្រៃឈើលើសពីកម្រិតលូតលាស់របស់ព្រៃឈើ ប៉ុន្តែក្នុងចំណោមបញ្ហាធំៗទាំង ០៣បានរៀបរាប់ខាងលើគឺមានតែការលួចធ្វើអាជីវកម្មដែល ជាបុព្វហេតុ ធ្វើឲ្យគម្របព្រៃឈើរបស់ចម្ការគ្រាប់ពូជគ្រញូងមានការថយចុះ។ សកម្មភាពអនុវត្តន៍យុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើរបស់សង្កាត់រដ្ឋព្រៃឈើកន្ទួតខ្នារក្រៅ មិនល្អដោយសារមាន កត្តាមួយចំនួនជាឧបសគ្គចំពោះដំណើរការអនុវត្តន៍សកម្មភាពដោយសារការខ្វះខាត ថវិកា ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ មធ្យោបាយ បច្ចេកទេស និងមន្ត្រី ដែលនេះជាបញ្ហាពិបាកមួយចំពោះយុទ្ធសាស្ត្រនៃការគ្រប់គ្រងព្រៃឈើ។ កម្រិតជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋានមួយចំនួនក្នុងដែនគ្រប់គ្រងរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ នៅតែជាបញ្ហាចោទចំពោះការគ្រប់គ្រងព្រៃឈើ។ មូលហេតុដែល នៅតែបង្កឲ្យមាន សកម្មភាពអាណាធិបតេយ្យលើវិស័យព្រៃឈើ គឺមានកត្តាខាងក្នុង និងខាងក្រៅវិស័យព្រៃឈើមានដូចជា៖

o កត្តាខាងក្រៅ

- តម្រូវការនៃការប្រើប្រាស់ធនធានព្រៃឈើរបស់ប្រជាជននៅក្បែរតំបន់មានការកើនឡើង
- ជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងតំបន់សិក្សាមួយភាគធំនៅមានកម្រិត
- ការចូលរួមពីសាធារណៈជននៅតំបន់ ក្នុងការគ្រប់គ្រងព្រៃឈើនៅមានកម្រិត

o កត្តាខាងក្នុង

- ការតាមដាន និងធ្វើសេចក្តីរាយការណ៍សកម្មភាពអាណាធិបតេយ្យព្រៃឈើ សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅពុំមានភាពជិតដល់
- ការទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗនៅមានកម្រិតរបស់មន្ត្រីរដ្ឋបាលព្រៃឈើ និងអាជ្ញាធរដែនដីក្នុងតំបន់
- ថវិកា មធ្យោបាយ និងសម្ភារៈបច្ចេកទេសមិនទាន់មានគ្រប់គ្រាន់តាមតម្រូវការរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ
- នៅខ្វះធនធានមនុស្ស ហើយមន្ត្រីមានសមត្ថភាពរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅពុំទាន់មានគ្រប់គ្រាន់។

## ការផ្តល់អនុសាសន៍

ឆ្លងតាមរយៈនៃការសិក្សាកន្លងមកយើងអាច ឃើញនូវបញ្ហាឧបសគ្គ និងចំណុចខ្វះខាតមួយចំនួនដែលមានឥទ្ធិពលទៅដល់ការងារគ្រប់គ្រងកន្លងមក និងអាចឲ្យមានអនុសាសន៍មួយចំនួន ដើម្បីជម្រុញការងារគ្រប់គ្រងធនធានព្រៃឈើ ក្នុងដែនសមត្ថកិច្ចរបស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ ឲ្យកាន់តែមានភាពល្អប្រសើរ និងមានប្រសិទ្ធភាពដូចខាងក្រោម៖

- សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ គួរមានមន្ត្រីជំនាញនៅប្រចាំការគ្រប់គ្រងក្នុងតំបន់ចម្ការគ្រាប់ពូជគ្រញូងជាប្រចាំដើម្បីក្តោបនូវពត៌មានរួម និងស្ថានភាពរួម
- គួរដាក់បន្ថែមនូវទីស្នាក់ចល័ត និងឆ្មាំដើរល្បាតចំនួន ០៧នាក់បន្ថែមទៀត ដើម្បីយាមល្បាតផ្ទៃដីចម្ការគ្រាប់ពូជគ្រញូងមានទំហំធំរហូតដល់ ១៨៨៨ហិកតា។
- គួរជម្រុញឲ្យមន្ត្រីជំនាញដែលមានកម្រិតសិក្សាត្រឹមបឋមរុក្ខកម្មឲ្យទៅសិក្សាបន្ថែមទៀត ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគាត់ទៅលើការគ្រប់គ្រងធនធានព្រៃឈើឲ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ និងធានានិរន្តរភាពព្រៃឈើ
- គួរធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ចម្ការគ្រាប់គ្រញូងតាមរយៈ ការជួសជុល និងស្តារឡើងវិញនូវត្រពាំង ប្រឡាយដែលហូរកាត់ជុំវិញចម្ការគ្រាប់ពូជគ្រញូងដើម្បីជៀសវាងការលិចលង់រហូតបង្ករជាទឹកជំនន់ជាដើម។
- គួរតែជំរុញឲ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៅនឹងចម្ការគ្រាប់ពូជគ្រញូងឲ្យបានកាន់តែច្រើនពីព្រោះវាជាប្រភេទព្រៃធម្មជាតិ។
- គួរតែពិនិត្យម៉ត់ចត់នៃពេលវេលាប្រមូលគ្រាប់ពូជនៅក្នុងចម្ការ ពីព្រោះដើមខ្លះមានផ្លែផ្កាមិនទៀតទាត់ និងការប្រមូលគ្រាប់ពូជសម្រាប់ដើមខែនីមួយៗ ខុសគ្នា
- សម្ភារៈក្នុងការប្រើប្រាស់ប្រមូលគ្រាប់ពូជ គួរតែមានការឧបត្ថម្ភបន្ថែមពីលើឧបករណ៍ដែលស្រាប់ដើម្បីជួយសម្រួល និងពន្លឿនការប្រមូលគ្រាប់ពូជឲ្យទាន់ពេលវេលា។
- ចំពោះទាហាន និងឆ្មាំល្បាតដែលយាមកាមគួរតែបណ្តុះបណ្តាលឲ្យគ្រប់ចំពោះការយាមល្បាតក្នុងចម្ការគ្រាប់ពូជគ្រញូង។
- យកចិត្តទុកដាក់ទប់ស្កាត់ និងចាត់វិធានការណ៍ការពារភ្លើងឆេះព្រៃ
- គួរតែរឹតបណ្តឹងការអនុវត្តន៍ច្បាប់បន្ថែមទៀតក្នុងគោលបំណងលុបបំបាត់ឲ្យអស់នូវសកម្មភាពអាណាធិបតេយ្យព្រៃឈើ និងសត្វព្រៃដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- ធ្វើការអនុវត្តការផ្សព្វផ្សាយបន្ត អំពីសារៈសំខាន់របស់តំបន់ចម្ការគ្រាប់ពូជគ្រញូង និងជម្រុញឲ្យប្រជាជនចូលរួមសកម្មភាពផ្សេងៗ ដើម្បីអភិរក្សតំបន់ចម្ការគ្រាប់ពូជគ្រញូង។
- ការលើកទឹកចិត្តទាហាន និងឆ្មាំល្បាត ក្នុងការការពារតំបន់ចម្ការតាមរយៈប្រាក់រង្វាន់ជាដើម។
- សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ គួរស្វែងរកដៃគូរអភិវឌ្ឍន៍នានា ដើម្បីជួយដល់ការការពារធនធានព្រៃឈើ និងបង្កើតគម្រោងអភិវឌ្ឍន៍ផ្សេងៗនៅក្នុងចម្ការ។

# ឯកសារយោង

## ឯកសារយោង


- កម្មវិធីព្រៃឈើជាតិ២០១០-២០២៩
- ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២)
- គោលការណ៍ណែនាំសម្រាប់គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- សេចក្តីណែនាំការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០៥)
- វន មុនិន្ទរុក្ខវប្បកម្ម២ ការងារថែទាំនិងគ្រប់គ្រងព្រៃឈើ
- ធនធានគំរបព្រៃឈើកម្ពុជាឆ្នាំ ២០០៤
- គោលការណ៍ណែនាំសំរាប់ប្រព័ន្ធនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន
- របាយការណ៍ស្តីពីស្ថិតិប្រជាពលរដ្ឋប្រចាំ ខែ មេសា ឆ្នាំ២០១៩ នៅឃុំយុនរាមខេត្តសៀមរាប
- ឡាំ វ៉ៃ ១៩៩៨,កសិរុក្ខកម្ម,ឯកសារបង្រៀននៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សារណា "សិក្សាលើការអភិរក្សតំបន់ប្រភពគ្រាប់ពូជនៅនឹងកន្លែងនៃប្រភេទគ្រញូងក្នុងឃុំយុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប"
- សារណា "សិក្សាពីស្ថានភាពនៃការគ្រប់គ្រងធនធានព្រៃឈើរបស់សង្កាត់រដ្ឋបាលព្រៃឈើរំដោះស្រែព្រីងនៃផ្នែករដ្ឋបាលព្រៃឈើជាំក្សាន្ត នៅក្នុងតំបន់ព្រៃការពារព្រះវិហារ ខេត្តព្រះវិហារ"
- ធ្វើការសម្ភាសន៍ជាមួយនាយសង្កាត់រដ្ឋបាលព្រៃឈើ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៩
- ធ្វើការសម្ភាសន៍ជាមួយនាយរងខណ្ឌរដ្ឋបាលព្រៃឈើ នៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៩
- របាយការណ៍បូកសរុបលទ្ធផលការងារវិស័យព្រៃឈើប្រចាំ ឆ្នាំ២០១៨ របស់ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប
- សកម្មភាពអនុវត្តន៍ការងារក្នុងចំការពូជឈើគ្រញូង ១៨៨៨ ហិកតា របស់សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្នារក្រៅ
- លទ្ធភាពការងារវិស័យព្រៃឈើឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៩ របស់ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប
- ប្រកាសស្តីពីការបង្កើតតំបន់ស្តារនិងអភិវឌ្ឍន៍ព្រៃឈើ "បន្ទាយស្រី" ស្ថិតនៅស្រុកបន្ទាយស្រី និងស្រុកស្វាយលើ ខេត្តសៀមរាប
- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១ ៖ ផែនទីចម្ការពូជឈើត្រញូងទំហំ ១៨៨៨ ហិកតា







## ឧបសម្ព័ន្ធ ២ ៖ ការចូលរួមសហការលើការគ្រប់គ្រងព្រៃឈើក៏ដូចជាក្នុងចម្ការពូជឈើគ្រញូង

សកម្មភាពចូលរួមពីមន្ត្រីរដ្ឋបាលព្រៃឈើ  អង្គការនានា និងប្រជាពលរដ្ឋ









សកម្មភាពដោះលែងសត្វក្នុងចម្ការពូជឈើគ្រញូង










– បញ្ហាជនខិលខូចចូលដុតក្នុងចម្ការពូជឈើក្រញូងដើម្បីទន្ទ្រានយកដី





- **សកម្មភាពការបង្ក្រាបបទល្មើសនានារបស់សង្កាត់រដ្ឋបាលព្រៃកន្ទួតខ្នាររក្រៅ**

ការញុះញង់ប្រជាពលរដ្ឋទន្ទ្រានដីព្រៃរដ្ឋ



| ការប្រើប្រាស់រណាយន្តអាណាធិបតេយ្យ | ការឃាត់ខ្លួនជនល្មើសលួចកាប់ឈើទាំងយប់ |
| --- | --- |
|  |  |

## ឧបសម្ព័ន្ធ ៣ ៖ សកម្មភាពចុះកម្មសិក្សាក្នុងតំបន់ចម្ការពូជឈើក្រញូង

សកម្មភាពធ្វើការសម្ភាសន៍នាយរងខណ្ឌ នៃខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប




សកម្មភាពធ្វើការសម្ភាសន៍នាយសង្កាត់ នៃសង្កាត់រដ្ឋបាលព្រៃឈើ កន្ទួតខ្នារក្រៅ



សកម្មភាពជួបសម្ភាសន៍ជាមួយមេឃុំនៃឃុំឃុនរាម





សកម្មភាពសម្ភាសន៍ និងការនាំចុះកម្មសិក្សាក្នុងចម្ការគ្រញូងរបស់មន្ត្រីឆ្មាំយាមល្បាត










# កម្រងឯកសារនានា

ឧបសម្ព័ន្ធ(១)

**រចនាសម្ព័ន្ធផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី**

លោក អ៊ឹង ឌុធារ៉ា នាយផ្នែក

លោក ជ្រុក គីមទើង នាយរងផ្នែក

លោក លី សុផា នាយរងផ្នែក

លោក ឡាយ សុផល មន្ត្រី
លោក ឡឹង សុខា មន្ត្រី
លោក ឡឿន សុផា មន្ត្រី

**សរព.កន្ទួតខ្សារក្រៅ**
លោក សេង លន នាយសង្កាត់
លោក ហង្ស ជំនិតរិទ្ធី នាយរងសង្កាត់
លោក ស៊ិន ណាវុធ នាយរងសង្កាត់
លោក វ៉ាន់ សាវុធ មន្ត្រី
លោកស្រី យិន សុឡាំ មន្ត្រី

**សរព.បន្ទាយស្រី**
លោក ខិ ចាន់ប៊ុណ្ណារិទ្ធិ នាយសង្កាត់
លោក ស ទូច មន្ត្រី

**សរព.ប្រាសាទបាគង**
លោក យឹម ស៊ីវ៉ន នាយសង្កាត់
លោក យ៉េង សារ៉ា នាយរងសង្កាត់
លោក ដួង សារឿន នាយរងសង្កាត់
លោក វ៉េង លី មន្ត្រី

**សរព.អង្គរធំ**
លោក សុខ សុជាត នាយរងសង្កាត់
លោក ឃ្លោក សុខន មន្ត្រី

បានឃើញ និង ឯកភាព
នាយផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី

ថ្ងៃ ... ខែ ... ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមរាប, ថ្ងៃទី ១៤ ខែ ... គ.ស២០១២
រៀបចំដោយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**របាយការណ៍**
**ស្តីពី**
**ស្ថិតិប្រជាពលរដ្ឋប្រចាំ ខែ មេសា ឆ្នាំ២០១៩**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | | | ចំនួនប្រជាពលរដ្ឋ | | | | | | ចំនួនប្រជាពលរដ្ឋ១៨ឆ្នាំឡើង | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | អចិន្ត្រៃយ៍ | បណ្ដោះអាសន្ន | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | |
| | | | | | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ |
| ១ | **ឈូកស** | ២៣០ | ២៣០ | ០ | ១០០៧ | ៥១៤ | ១០០៧ | ៥១៤ | ០ | ០ | ៦២៤ | ៣២៣ | ៦២៤ | ៣២៣ | ០ | ០ | |
| ២ | **គំព្រាហ្ម** | ៥៧៥ | ៤៤៤ | ១៣១ | ២៦៣៥ | ១៣៣១ | ២១៣០ | ១០៥៩ | ៥០៥ | ២៧២ | ១៥៧៩ | ៧៧៦ | ១៣២៧ | ៦៨០ | ២៥២ | ៨៦ | |
| ៣ | **ឃុនរាម** | ១៩៤ | ១៩៤ | ០ | ៩៩០ | ៤៨២ | ៩៩០ | ៤៨២ | ០ | ០ | ៥៨៧ | ២៩៥ | ៥៨៧ | ២៩៥ | ០ | ០ | |
| ៤ | **ខ្នារទ្វោស** | ១៤៧ | ១៤៧ | ០ | ៦៨៦ | ៣៧៤ | ៦៨៦ | ៣៧៤ | ០ | ០ | ៣៦៥ | ១៩៧ | ៣៦៥ | ១៩៧ | ០ | ០ | |
| ៥ | **ទួលគ្រួស** | ១៤៤ | ១៤៤ | ០ | ៨៧២ | ៤២៥ | ៨៧២ | ៤២៥ | ០ | ០ | ៥១៩ | ២៥៧ | ៥១៩ | ២៥៧ | ០ | ០ | |
| ៦ | **ត្រពាំងថ្ម** | ២៨៦ | ២៨៦ | ០ | ១១០០ | ៥១៤ | ១១០០ | ៥១៤ | ០ | ០ | ៥៨៥ | ២៨៨ | ៥៨៥ | ២៨៨ | ០ | ០ | |
| ៧ | **ពើងធំត្រ** | ១៥៦ | ១៥៦ | ០ | ៥៧០ | ៣០២ | ៥៧០ | ៣០២ | ០ | ០ | ៣៤៤ | ២០៤ | ៣៤៤ | ២០៤ | ០ | ០ | |
| សរុបរួម | | ១៧៣២ | ១៦០១ | ១៣១ | ៧៩៦០ | ៣៩៤២ | ៧៣៥៥ | ៣៦៧០ | ៥០៥ | ២៧២ | ៤៦៥៣ | ២៣៨០ | ៤៤០១ | ២២៤៤ | ២៥២ | ៨៦ | |

បញ្ជាក់៖ ចំពោះភូមិដែលមិនមានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃប្រជាពលរដ្ឋនៅក្នុងភូមិនោះត្រូវបូកសងបញ្ចូលទៅក្នុងភូមិដែលមានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃ

បានឃើញនិងឯកភាព
ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩
មេភូមិឃុនរាម

អ្នកធ្វើតារាង
ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩
ស្មៀន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសៀមរាប
ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប
ផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី

## ស្ថានភាពមន្ត្រីរាជការឆ្នាំ២០១៨ របស់ផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨

| ល.រ | អត្តលេខ | គោត្តនាម និងនាម | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | ថ្ងៃ ខែ ឆ្នាំ បម្រើការងារ | ថ្ងៃ ខែ ឆ្នាំ កាំប្រាក់ចុងក្រោយ | កាំប្រាក់ | ឋានៈ | កម្រិតបច្ចេកទេស | ជំនាញបច្ចេកទេស | [illegible] | ពិការ | ឋានន្តរស័ក្តិ | លេខទូរស័ព្ទ | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| I.ផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី | | | | | | | | | | | | | | | |
| 1 | 1741700046 | អ៊ឹង វុធារ៉ា | ប្រុស | 15.07.74 | 31.08.98 | 13.04.18 | ក.2.1 | នាយផ្នែក-បន្ទាយស្រី | បរិញ្ញាបត្រ | រុក្ខកម្ម | | | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | 012 917 197 | |
| 2 | 1680800815 | ជ្រូក គឹមវ៉េង | ប្រុស | 13.09.68 | 07.08.92 | 13.04.16 | ខ.2.4 | នាយរងផ្នែក-បន្ទាយស្រី | មធ្យម | រុក្ខវប្បកម្ម | | | មន្ត្រីបច្ចេកទេសមធ្យម | 097 967 2961 | |
| 3 | 1760400005 | លី សុផា | ប្រុស | 01.05.76 | 04.60.98 | 01.07.18 | គ.7 | នាយរងផ្នែក-បន្ទាយស្រី | បឋម | រុក្ខវប្បកម្ម | | | មន្ត្រីបច្ចេកទេស បឋម | 097 696 9464 | |
| 4 | 1721700054 | ឡាយ សុផល | ប្រុស | 21.11.72 | 01.11.89 | 01.07.18 | ខ.2.3 | មន្ត្រីផ្នែក-បន្ទាយស្រី | បរិញ្ញាបត្រ | គ្រប់គ្រងទូទៅ | | | មន្ត្រីបច្ចេកទេសមធ្យម | 097 442 2786 | |
| 5 | 1800800420 | ឈឿន សុធា | ប្រុស | 01.07.80 | 20.90.05 | 01.07.18 | ខ.3.2 | មន្ត្រីផ្នែក-បន្ទាយស្រី | មធ្យម | រុក្ខវប្បកម្ម | | | មន្ត្រីបច្ចេកទេសមធ្យម | 097 906 7960 | |
| 6 | 1661700008 | ឡឹង សុខា | ប្រុស | 07.06.66 | 23.11.87 | 13.04.16 | គ.9 | មន្ត្រីផ្នែក-បន្ទាយស្រី | ថ្នាក់ទី១០ថ្មី | គណនេយ្យ ហិរញ្ញវត្ថុ | | | លេខាធិការរដ្ឋបាល | 012 644 442 | |
| I.១.សង្កាត់រដ្ឋបាលព្រៃឈើបន្ទាយស្រី | | | | | | | | | | | | | | | |
| 10 | 1700600030 | ខិ ចាន់បុណ្ណារិទ្ធ | ប្រុស | 15.12.70 | 02.08.94 | 13.04.16 | ក.2.2 | នាយសង្កាត់-បន្ទាយស្រី | បរិញ្ញាបត្រជាន់ខ្ពស់ | រុក្ខកម្ម | | | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | 017 602 250 | |
| 11 | 1752100058 | ស ទូច | ប្រុស | 09.10.75 | 24.07.95 | 13.04.16 | គ.9 | មន្ត្រីសង្កាត់-បន្ទាយស្រី | មធ្យម | រុក្ខវប្បកម្ម | | | មន្ត្រីបច្ចេកទេស បឋម | 017 576 521 | |
| I.២.សង្កាត់រដ្ឋបាលព្រៃឈើប្រាសាទបាគង | | | | | | | | | | | | | | | |
| 12 | 1701700092 | យឹម ស៊ីវិន | ប្រុស | 10.02.70 | 29.12.92 | 13.04.14 | ក.3.2 | នាយសង្កាត់-ប្រា.បាគង | បរិញ្ញាបត្រ | បច្ចេកវិទ្យា+គ្រប.កសក (ផ្នែកព្រៃឈើ) | | | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | 012 691 269 | |
| 13 | 1731200649 | ឃើង សារ៉ាំ | ប្រុស | 01.11.73 | 01.07.97 | 13.04.16 | ខ.2.4 | នាយរងសង្កាត់-ប្រា.បាគង | មធ្យម | រុក្ខវប្បកម្ម | | | មន្ត្រីបច្ចេកទេសមធ្យម | 099 700 707 | |
| 14 | 1780800073 | ដួង សារឿន | ប្រុស | 07.01.78 | 04.06.98 | 01.07.18 | គ.7 | នាយរងសង្កាត់-ប្រា.បាគង | បរិញ្ញាបត្រ | វិទ្យាសាស្ត្រកសិកម្ម | | | លេខាធិការរដ្ឋបាល | 088 849 8777 | |
| 15 | 1761200020 | ផង់ លី | ប្រុស | 25.11.76 | 14.10.95 | 13.04.16 | គ.8 | មន្ត្រីសង្កាត់-ប្រា-បាគង | មធ្យមសិក្សាកំ២ | គ្មាន | | | លេខាធិការរដ្ឋបាល | 097 599 9765 | |
| I.៣.សង្កាត់រដ្ឋបាលព្រៃឈើកន្ទួតខ្វាវក្រៅ | | | | | | | | | | | | | | | |
| 15 | 1662100308 | សេង លន | ប្រុស | 10.01.66 | 29.04.87 | 13.04.16 | គ.7 | នាយសង្កាត់-កន្ទួតខ្វាវក្រៅ | ថ្នាក់ទី៩ ថ្មី | គ្មាន | | | លេខាធិការរដ្ឋបាល | 097 760 3720 | |
| 16 | 1711200228 | ស៊ិន ណារុធ | ប្រុស | 01.07.71 | 23.03.93 | 13.04.16 | ខ.2.4 | នាយរងសង្កាត់-កន្ទួតខ្វាវក្រៅ | បរិញ្ញាបត្ររង | បសុព្យាបាល | | | មន្ត្រីបច្ចេកទេសមធ្យម | 088 593 5555 | |
| 17 | 1741200324 | ហង្ស ជំនិតរិទ្ធី | ប្រុស | 07.03.74 | 30.07.95 | 13.04.16 | គ.8 | នាយរងសង្កាត់-កន្ទួតខ្វាវក្រៅ | បឋម | រុក្ខកម្ម | | | មន្ត្រីបច្ចេកទេស បឋម | 097 744 6526 | |
| 18 | 2680600148 | យិន សុឡាំ | ស្រី | 09.06.68 | 12.10.87 | 13.04.16 | គ.9 | មន្ត្រីសង្កាត់-កន្ទួតខ្វាវក្រៅ | ថ្នាក់ទី៩ថ្មី | គ្មាន | | | លេខាធិការរដ្ឋបាល | 088 352 4506 | |
| 19 | 1680500268 | ភិន់ សារុធ | ប្រុស | 12.09.68 | 11.11.86 | 13.04.16 | គ.9 | មន្ត្រីសង្កាត់-កន្ទួតខ្វាវក្រៅ | បរិញ្ញាបត្ររង | បច្ចេកវិទ្យា+គ្រប.កសក (ផ្នែកព្រៃឈើ) | | | លេខាធិការរដ្ឋបាល | 097 734 6742 | |
| I.៤.សង្កាត់រដ្ឋបាលព្រៃឈើអង្គរធំ | | | | | | | | | | | | | | | |
| 17 | 1660800458 | សុខ សុជាត | ប្រុស | 14.02.66 | 06.03.90 | 13.04.18 | ខ.2.4 | នាយរងសង្កាត់-អង្គរធំ | បរិញ្ញាបត្រ | បច្ចេកវិទ្យា+គ្រប.កសក (ផ្នែកព្រៃឈើ) | | | មន្ត្រីបច្ចេកទេសមធ្យម | 017 684 869 | |
| 18 | 1691700061 | ឈ្លាក សុខន | ប្រុស | 10.10.69 | 31.12.87 | 13.04.18 | គ.8 | មន្ត្រីសង្កាត់-អង្គរធំ | បឋម | រុក្ខវប្បកម្ម | | | មន្ត្រីបច្ចេកទេស បឋម | 012 551 961 | |

ថ្ងៃ.[illegible].ឆ្នាំច សំរឹទ្ធិស័ក ឆ្នាំ២៥៦២
សៀមរាប,ថ្ងៃទី...១៥........ខែ...ធ្នូ..........ឆ្នាំ២០១៨
**អ្នកធ្វើតារាង**

[signature]
ឡាយ សុផល

បានឃើញ និង ឯកភាព
**នាយផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី**

[signature]
អ៊ឹង វុធារ៉ា

## តារាងស្ថិតិយន្ត យានយន្តនិងវត្ថុតាងល្មើសគ្រប់ប្រភេទដែលបានចាប់ឃាត់
## របស់ផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី ឆ្នាំ២០១៨

| លេខរៀង | ឈ្មោះជនល្មើស | វត្ថុតាងល្មើស | | | | | | | | | | | | | | ថ្ងៃខែឆ្នាំ ចាប់ឃាត់ | អ្នកថែរក្សា | កន្លែងថែរក្សា | សេចក្តីសំរេច/សាលក្រម | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ក្រញូង | ក្រាក់ក្រញូង | ធ្នង់ត្រ | បេងតាង | លេខ១ | លេខ២ | លេខ៣/ព្រៃ | សត្វព្រៃ | មូល ១ | មូលលេខ២ | ម៉ូតូ | ដីព្រៃ | គោយន្ត | រថយន្ត | | | | គ្មាន | មាន | លេខ | ថ្ងៃខែឆ្នាំ | |
| 1 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 |
| I.ពិន័យអន្តរការណ៍ | | | | | | | | | | | | | | | | | | | | | | | |
| 1 | គ៊ុន សិទ្ធិ | | | | | | | | រមៀក ៨ជាប្ | | | | | | | 08.01.18 | អ៊ឹម វុណា | ឃរក.បន្ទាយស្រី | | ✓ | 420 ព.ឧឧព | 09-02-18 | |
| 2 | សុខ លាភី | | | | | | 1.413 | | | | | | | | 1 | 20.01.18 | សេង ឈន | សរក.កណ្តាលស្ទឹង ១ | | ✓ | 421 ព.ឧឧព | 09-02-18 | |
| 3 | លី ស៊ៀន | | | | | | 1.440 | | | | | | | | 1 | 20.01.18 | សេង ឈន | សរក.កណ្តាលស្ទឹង ១ | | ✓ | 422 ព.ឧឧព | 09-02-18 | |
| 6 | សៅ យ៉ាន់ពៅ | | | | | 0.440 | | | | | | 1 | | | | 22.01.18 | លី សួគ | ឃរក.បន្ទាយស្រី | | ✓ | 837 ព.ឧឧព | 03-04-18 | |
| 7 | ម៉ិន សុផល | | | | | 0.564 | | | | | | | | | 1 | 25.03.18 | លី សួគ | ឃរក.បន្ទាយស្រី | | ✓ | 1003 ព.ឧឧព | 27-04-18 | |
| 9 | សោក ប៉ុ | | | | | | 1.280 | | | | | | | | 1 | 26.04.18 | លី សួគ | ឃរក.បន្ទាយស្រី | | ✓ | 1131 ព.ឧឧព | 18-05-18 | |
| 10 | ប៊ុន ហេង | | | | | | | 4.141 | | | | | | | 1 | 18.05.18 | លី សួគ | ឃរក.បន្ទាយស្រី | | ✓ | 1309 ព.ឧឧព | 14-06-18 | |
| 11 | រី ឡុង | | | | | | | 4.850 | | | | | | | 1 | 29.05.18 | លី សួគ | ឃរក.បន្ទាយស្រី | | ✓ | 1310 ព.ឧឧព | 14-06-18 | |
| 12 | មុំ ស៊ីនហេង | | | | | 0.337 | 0.540 | | | | | | | | 1 | 20.06.18 | លី សួគ | ឃរក.បន្ទាយស្រី | | ✓ | 1510 ព.ឧឧព | 16-07-18 | |
| 14 | ឡេង ឈើរ | | | | | 0.432 | | | | | | | | | 1 | 19.07.18 | លី សួគ | ឃរក.បន្ទាយស្រី | | ✓ | 1705 ព.ឧឧព | 14-08-18 | |
| 15 | សឿន អូន | | | | | | 0.810 | | | | | | | | 1 | 07.08.18 | សេង ឈន | សរក.កណ្តាលស្ទឹង ១ | | ✓ | 1772 ព.ឧឧព | 20-08-18 | |
| 16 | សុខ ណេម | | | | | | 1.462 | | | | | | | | 1 | 28.08.18 | អ៊ឹម វុណា | ឃរក.បន្ទាយស្រី | | ✓ | 2159 ព.ឧឧព | 04-10-18 | |
| 17 | ផាត់ គង់ | | | | | | 0.720 | | | | | | | | 1 | 29.08.18 | ជេង លី | ឃរក.បន្ទាយស្រី | | ✓ | 2161 ព.ឧឧព | 04-10-18 | |
| 18 | ឯក ពៅ | | | | | | 0.525 | | | | | | | | 1 | 20.08.18 | ជេង លី | ឃរក.បន្ទាយស្រី | | ✓ | 2160 ព.ឧឧព | 04-10-18 | |
| សរុប I | | 0.000 | 0.000 | 0.000 | 0.000 | 1.773 | 8.190 | 8.991 | 0.000 | 0.000 | 0.000 | 1.000 | 0.000 | 0.000 | 12.000 | | | | | | | | |
| II.តុលាការ | | | | | | | | | | | | | | | | | | | | | | | |
| 4 | អជ្ញាតជន | | 0.333 | | | | | | | | | | | | 1 | 01.02.18 | ឈឹម សាត់ | ឃរក.បន្ទាយស្រី | | | | | |
| 5 | អជ្ញាតជន | | | | 0.487 | | | | | | | | | | 1 | 22.01.18 | អ៊ឹម វុណា | ឃរក.បន្ទាយស្រី | | | | | |
| 8 | អជ្ញាតជន | | | | | | | | | | | | 9.263 | | | 26.03.18 | សេង ឈន | សរក.កណ្តាលស្ទឹង ១ | | | | | EXCAVATOR 1 |
| 13 | ស៊ីង ឡេង,ឆាង សុគារ,ព្រែក គន្លី | | | | | | | | | | | | 3.104 | | 1 | 13.07.18 | បណ្ឌ ជំនិតរិទ្ធិ | សរក.កណ្តាលស្ទឹង ១ | | | | | EXCAVATOR 1 |
| 19 | ពក ម៉េង, គិន ឆុង | | | | | | | | | | | 1 | 3 | | 1 | 21.09.18 | លី សួគ | ឃរក.បន្ទាយស្រី | | | | | |
| 20 | អជ្ញាតជន | | | | | | | | | | | | 72 | | | 19.09.18 | សេង ឈន | សរក.កណ្តាលស្ទឹង ១ | | | | | |
| 21 | ផែន ធឿន, សាម៉ុន ឆាន់ | | | | | | | | ក្រាន់ព្រៃ១០ ក្បាល | | | 1 | | | | 06.10.18 | សេង ឈន | សរក.កណ្តាលស្ទឹង ១ | | | | | |
| សរុប II | | 0.000 | 0.333 | 0.000 | 0.487 | 0.000 | 0.000 | 0.000 | 0.000 | 0.000 | 0.000 | 2.000 | 87.367 | 0.000 | 4.000 | | | | | | | | |
| សរុបរួម I+II | | 0.000 | 0.333 | 0.000 | 0.487 | 1.773 | 8.190 | 8.991 | 0.000 | 0.000 | 0.000 | 3.000 | 87.367 | 0.000 | 16.000 | | | | | | | | |

បានឃើញ និង ពិនិត្យត្រឹមត្រូវ
**នាយផ្នែករដ្ឋបាលព្រៃឈើបន្ទាយស្រី**

ហ៊ុន សុភាក់

ថ្ងៃ... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប,ថ្ងៃទី១៥ ខែ ធ្នូ ព.ស ២០១៨
អ្នកធ្វើតារាង

ឡាយ សុភ័ស